**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# តួនាទី និងការទទួលខុសត្រូវ
# សម្រាប់ការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា

## Roles and Responsibilities
## for Agricultural Extension in Cambodia




**រៀបចំដោយ :** កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

**ឧបត្ថម្ភដោយ:** រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម (IFAD)

**ភ្នំពេញ ខែ កក្កដា ឆ្នាំ ២០១៧**

# មាតិកា

ទំព័រ


អារម្ភកថា.....5
សេចក្តីថ្លែងអំណរគុណ .....6
១.ប្រវត្តិផ្សព្វផ្សាយកសិកម្មនៅកម្ពុជា .....8
២.លក្ខណៈពិសេសនៃគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា .....9
ការផ្សព្វផ្សាយតាមបែបពហុនិយម .....10
ការផ្សព្វផ្សាយតាមតម្រូវការ.....10
ភាពទទួលខុសត្រូវ.....10
៣.ចក្ខុវិស័យ គោលបំណង និងគោលដៅ .....10
គោលបំណង .....11
គោលដៅ.....11
៤.អភិក្រម និងយុទ្ធសាស្ត្រ.....11
៥.រចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវលើការផ្សព្វផ្សាយកសិកម្ម .....12
យន្តការ និងរចនាសម្ព័ន្ធផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិ.....13
យន្តការ និងរចនាសម្ព័ន្ធផ្សព្វផ្សាយកសិកម្មនៅថ្នាក់ក្រោមជាតិ .....13
៥.១.គណៈកម្មាធិការប្រឹក្សាយោបល់ផ្សព្វផ្សាយកសិកម្ម.....13
៥.២.អនុគណៈកម្មាធិការបច្ចេកទេសកសិកម្មថ្នាក់ជាតិ.....14
៥.៣.ក្រុមផ្សព្វផ្សាយកសិកម្ម និងទឹក (ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក).....15
៥.៤.តួនាទី និងភារកិច្ចនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ជាលេខាធិការដ្ឋាន .....16
១.ប្រធាននាយកដ្ឋាន.....19
២.អនុប្រធាននាយកដ្ឋាន.....19
៥.៤.១.ការិយាល័យ រដ្ឋបាល ផែនការ គណនេយ្យ និងសហប្រត្តិបត្តិការអន្តរជាតិ(រ.ផ.គ.ស.អ).....20
១. ប្រធានការិយាល័យ (រ.ផ.គ.ស.អ) .....20
២. អនុប្រធានការិយាល័យទទួលបន្ទុករដ្ឋបាល .....20
៣. អនុប្រធានការិយាល័យទទួលបន្ទុកផែនការ.....21
៤. អនុប្រធានការិយាល័យទទួលបន្ទុកគណនេយ្យ .....21
៥. អនុប្រធានការិយាល័យទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិ .....21
៦. មន្ត្រីទទួលបន្ទុកផ្នែករដ្ឋបាល.....22
៧. មន្ត្រីទទួលបន្ទុកផ្នែកផែនការ .....22
៨. មន្ត្រីទទួលបន្ទុកផ្នែកគណនេយ្យ.....22
៩. មន្ត្រីទទួលបន្ទុកផ្នែកសហប្រត្តិបត្តិការអន្តរជាតិ .....22
៥.៤.២.ការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស.....23
១. ប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស.....23
២. អនុប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស.....24

៣.មន្ត្រីទទួលបន្ទុកផ្នែកការគ្រប់គ្រងការបណ្តុះបណ្តាល ......24
៤.មន្ត្រីទទួលបន្ទុកផ្នែកយេនឌ័រ និងការអភិវឌ្ឍន៍......25
៥.មន្ត្រីទទួលបន្ទុកផ្នែកគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងអភិវឌ្ឍន៍ធនធានមនុស្ស......25
៦.មន្ត្រីទទួលបន្ទុកផ្នែករដ្ឋបាល និងគណនេយ្យ ......26
៥.៤.៣.ការិយាល័យការអប់រំ និងផ្សព្វផ្សាយកសិកម្ម ......26
១.ប្រធានការិយាល័យអប់រំ និងផ្សព្វផ្សាយកសិកម្ម ......27
២.អនុប្រធានការិយាល័យអប់រំ និងផ្សព្វផ្សាយកសិកម្ម ......27
៣.មន្ត្រីទទួលបន្ទុកផ្នែកផ្សព្វផ្សាយតាមប្រព័ន្ធសាធារណៈ ......28
៤.មន្ត្រីទទួលបន្ទុកផ្នែកបោះពុម្ព ......28
៥.មន្ត្រីទទួលបន្ទុកផ្នែករដ្ឋបាល និងបណ្ណាល័យ ......29
៦.មន្ត្រីទទួលបន្ទុកផ្នែកពិព័រណ៍ផលិតផលកសិកម្ម ......29
៥.៤.៤.ការិយាល័យប្រព័ន្ធកសិកម្ម និងសេដ្ឋកិច្ចកសិកម្ម ......29
១.ប្រធានការិយាល័យប្រព័ន្ធកសិកម្ម និងសេដ្ឋកិច្ចកសិកម្ម......30
២.អនុប្រធានការិយាល័យ ប្រព័ន្ធកសិកម្ម និងសេដ្ឋកិច្ចកសិកម្ម ......30
៣.មន្ត្រីទទួលបន្ទុកផ្នែកប្រព័ន្ធកសិកម្ម......31
៤.មន្ត្រីទទួលបន្ទុកផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មានកសិកម្ម (FSMIS) ......31
៥.មន្ត្រីទទួលបន្ទុកផ្នែកសេដ្ឋកិច្ចកសិកម្ម ......31
៦.មន្ត្រីទទួលបន្ទុកផ្នែករដ្ឋបាល......32
៥.៤.៥.មជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្ម តាស្អាង (ខេត្តស្វាយរៀង)......32
៥.៤.៦.មជ្ឈមណ្ឌលបណ្តុះបណ្តាលកសិករគំរូតំបន់អភិវឌ្ឍន៍ខាងលិច រាជធានីភ្នំពេញ (ខេត្តកំពង់ស្ពឺ)33
៥.៥.មុខងារគាំទ្រ និងសម្របសម្រួលរបស់អង្គភាពពាក់ព័ន្ធក្នុង ការងារផ្សព្វផ្សាយកសិកម្ម......34
៥.៥.១.តួនាទី និងភារកិច្ចគ្រឹះស្ថានអប់រំ និងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ កសិកម្មកម្ពុជា ......35
៥.៥.២.តួនាទី និងភារកិច្ចអង្គភាពជំនាញពាក់ព័ន្ធ......37
៥.៥.៣.តួនាទី និងភារកិច្ចអង្គភាពគាំទ្រ និងសម្របសម្រួល......37
៥.៦.តួនាទី និងភារកិច្ចរបស់អង្គភាពនៅថ្នាក់ក្រោមជាតិ ......38
៥.៦.១.តួនាទី និងភារកិច្ចរបស់ក្រុមការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មរាជធានី-ខេត្ត......38
៥.៦.២.តួនាទី និងភារកិច្ចរបស់ក្រុមគាំទ្របច្ចេកទេសកសិកម្មស្រុក......39
៥.៦.៣.មុខងារសម្របសម្រួល គ្រប់គ្រង និងគាំទ្ររបស់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត ......39
១.ប្រធានមន្ទីរ ......40
២.អនុប្រធានមន្ទីរ ......40
៥.៦.៤.ការិយាល័យផ្សព្វផ្សាយកសិកម្ម រាជធានី-ខេត្ត......41
១.ប្រធានការិយាល័យផ្សព្វផ្សាយកសិកម្ម ......41
២.អនុប្រធានការិយាល័យផ្សព្វផ្សាយកសិកម្ម ......42
៣.មន្ត្រីទទួលបន្ទុកផ្នែករដ្ឋបាល ផែនការ និងគណនេយ្យ......43
៤.មន្ត្រីទទួលបន្ទុកផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស/បណ្តុះបណ្តាល ......43
៥.មន្ត្រីទទួលបន្ទុកផ្នែកអភិវឌ្ឍន៍ប្រព័ន្ធកសិកម្ម......44

៥.៦.៥.មុខងារអនុវត្ត និងគាំទ្ររបស់ការិយាល័យកសិកម្មនៅថ្នាក់ក្រុង ស្រុក-ខណ្ឌ....................................45
១.ប្រធានការិយាល័យកសិកម្ម ក្រុង ស្រុក ខណ្ឌ ....................................................................45
២.អនុប្រធានការិយាល័យកសិកម្ម ក្រុង ស្រុក ខណ្ឌ ..............................................................46
៣.មន្ត្រីទទួលបន្ទុកផ្នែករដ្ឋបាលនិងនីតិកម្មកសិកម្ម.....................................................................47
៤.មន្ត្រីទទួលបន្ទុកផ្នែកក្សេត្រសាស្ត្រ .......................................................................................48
៥.មន្ត្រីទទួលបន្ទុកផ្នែកផ្សព្វផ្សាយកសិកម្ម ...............................................................................48
៦.មន្ត្រីទទួលបន្ទុកផ្នែកផលិតកម្ម និងបសុព្យាបាល ...................................................................49
៧.មន្ត្រីទទួលបន្ទុកផ្នែកសហគមន៍កសិកម្ម...............................................................................50
៨. មន្ត្រីទទួលបន្ទុកផ្នែករុក្ខាប្រមាញ់.........................................................................................51
៩. មន្ត្រីទទួលបន្ទុកផ្នែកជលផល ..............................................................................................51
១០.ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ...............................................................................................52
១១.ភ្នាក់ងារផ្សព្វផ្សាយកសិកម្មថ្នាក់ភូមិ .....................................................................................52
៦.អត្ថប្រយោជន៍នៃតួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា.................................53
៧. ផែនការជាក់លាក់នៃការផ្សព្វផ្សាយ...........................................................................................53
៨.ការទំនាក់ទំនងផែនការផ្សព្វផ្សាយ ការស្រាវជ្រាវ និងកសិករ..........................................................54
៩. សារៈសំខាន់នៃ ការផ្ទេរព័ត៌មាន ពីកសិករមួយទៅកសិករមួយទៀតក្នុងដំណើរការផ្សព្វផ្សាយ .............................55
១០.ក្របខណ្ឌអនុវត្ត ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ.................................................................56
១១.សេចក្តីសន្និដ្ឋាន......................................................................................................................57

# **អារម្ភកថា**

ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំ បណ្តុះបណ្តាល និងផ្ទេរបច្ចេកទេស បច្ចេកវិទ្យា និងការអនុវត្តកសិកម្មល្អថ្មីៗដល់កសិករ និងសហគមន៍កសិករ សំដៅលើកកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម បង្កើនប្រាក់ចំណូលគ្រួសារ ព្រមទាំងបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុ គ្រោះធម្មជាតិ និងវិបត្តិនានា ។

ឯកសារគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានចែងថា ដើម្បីឱ្យការផ្តល់សេវាផ្សព្វផ្សាយកសិកម្មមានប្រសិទ្ធភាព និងឱ្យសហគមន៍កសិករទទួលបានសេវាផ្សព្វផ្សាយកសិកម្មយ៉ាងទៀងទាត់ និងជួយធានាឱ្យមានព័ត៌មាន បច្ចេកទេសទាន់ពេលវេលា គ្រប់គ្រាន់ដែលអាចឱ្យសហគមន៍កសិករទទួលបាន និងយកទៅអនុវត្តបានតាមតម្រូវការចាំបាច់ត្រូវមានការគាំទ្រ សម្របសម្រួល និងផ្សារភ្ជាប់ទំនាក់ទំនងរវាងគ្រប់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅកម្ពុជា និងការផ្តល់សេវាផ្សព្វផ្សាយតាមបែបពហុនិយម ឆ្លើយតបទៅនឹងតម្រូវការអ្នកប្រើប្រាស់ និងទីផ្សារ។

ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មតាមបែបពហុនិយម ដោយមានការចូលរួមពីគ្រប់អង្គភាព និងស្ថាប័នពាក់ព័ន្ធរួមមាន៖ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហគមន៍មូលដ្ឋាន។ ការផ្តល់សេវា និងការផ្សព្វផ្សាយនៅមានកម្រិត និងមិនមានប្រសិទ្ធភាពល្អដោយសារខ្វះការកំណត់តួនាទី និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់ ក្នុងការងារផ្សព្វផ្សាយកសិកម្មរបស់អង្គភាព ស្ថាប័ន និងដៃគូរពាក់ព័ន្ធនានា។

ឯកសារតួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយនៅកម្ពុជា រៀបចំឡើងដោយអនុលោមតាមគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា និងលទ្ធផលសិក្ខាសាស្ត្តពីការកំណត់តួនាទី និងការទទួលខុសត្រូវរបស់អង្គភាពពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអ្នកពាក់ព័ន្ធនានាក្រោមការគាំទ្រពីកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ(ASPIRE)។ ឯកសារតួនាទី និងការទទួល ខុសត្រូវ សម្រាប់ការផ្សព្វផ្សាយនៅកម្ពុជា ត្រូវបានស្របតាមមូលបទ "*ការផ្សព្វផ្សាយកសិកម្ម ដើម្បីតាមតម្រូវការ និងការ ទទួលបានគុណភាពខ្ពស់ នៃសេវាផ្សព្វផ្សាយកសិកម្ម*" ដើម្បីលើកកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាព ផលិតផលកសិកម្មសម្រាប់ឆ្លើយតបទៅតាមតម្រូវការទីផ្សារ និងការប្រកួតប្រជែង ព្រមទាំងបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

ឯកសារតួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយនៅកម្ពុជានេះ ជាឯកសារគ្រឹះដែលពិពណ៌នាពីតួនាទី ការទទួលទទួលខុសត្រូវ ដំណើរការ វិធីសាស្ត្រ រៀបចំគាំទ្រ និងសម្របសម្រួលកម្មវិធី និងសកម្មភាពផ្សព្វផ្សាយបច្ចេកទេសកសិកម្មនានារបស់ស្ថាប័នអង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងភ្នាក់ងារផ្តល់សេវាកសិកម្មទាំងអស់យកទៅប្រើប្រាស់ក្នុងការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងការអនុវត្តកសិកម្មល្អនានាដល់ប្រជាកសិករ និងអ្នកផលិតនៅកម្ពុជា។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមអំពាវនាវ និងលើកទឹកចិត្តដល់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មទាំងអស់នៅក្នុងវិស័យសាធារណៈទាំងនៅក្នុងវិស័យឯកជន ដៃគូរអភិវឌ្ឍន៍ កសិករ និងសហគមន៍កសិកររួមគ្នាគាំទ្រចូល រួមអនុវត្តឯកសារតួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយនៅកម្ពុជានេះ ឱ្យទទួលបានលទ្ធផលជាផ្លែផ្កា និង មានប្រសិទ្ធភាពខ្ពស់ ក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មដល់កសិករ និងសហគមន៍កសិករ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ និងឱ្យមានសេវា និងបច្ចេកទេសគ្រប់គ្រាន់តាមតម្រូវការ ទទួលយកបាន មានលទ្ធភាពប្រើប្រាស់ បាន និងយកទៅអនុវត្តបានដោយកសិករ និងសហគមន៍កសិករ ដើម្បីលើកកម្ពស់វិស័យកសិកម្ម និង**ទ្រទ្រង់កំណើន សេដ្ឋកិច្ច ធានាសមធម៌ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

## សេចក្តីថ្លែងអំណរគុណ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអភិវឌ្ឍកសិកម្មអន្តរជាតិ (IFAD) ដែលបានផ្តល់ហិរញ្ញប្បទានដល់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទក្នុង ការអនុវត្តកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ក្នុងគោលបំណង កាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់របស់គ្រួសារកសិករក្រីក្រ និងងាយរងគ្រោះខ្នាតតូចនៅកម្ពុជា។ កម្មវិធី ASPIRE បានគាំទ្រថវិកា និងបច្ចេកទេសដល់នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម ក្នុងការអនុវត្តសមាសភាព ទី២ នៃកម្មវិធីគឺអភិវឌ្ឍសមត្ថភាព សេវាផ្សព្វផ្សាយកសិកម្ម ដើម្បីជួយគាំទ្រការកែលម្អសេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់ក្រោមជាតិ និងមូលដ្ឋានតាមរយៈបង្កើនគុណភាពផ្សព្វផ្សាយកសិកម្ម គ្រប់គ្រងចំណេះដឹង និងពង្រឹងធនធានមនុស្សសម្រាប់ផ្សព្វផ្សាកសិកម្ម។

ដើម្បីកត់ត្រាទុកនូវវិភាគទាន ដ៏មានតម្លៃទាំងនេះយើងខ្ញុំសូមថ្លែងអំណគុណចំពោះក្រុមការងាររបស់នាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម គ្រឹះស្ថានអប់រំកសិកម្ម វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម អង្គភាពជំនាញពាក់ព័ន្ធ អង្គភាពគាំទ្រ និងសម្របសម្រួលថ្នាក់ដឹកនាំ និងមន្ត្រីនៃមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត និងការិយាល័យកសិកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ និងបណ្តាអ្នកពាក់ព័ន្ធទាំងអស់ដែលបានចំណាយពេលវេលា និង ចូលរួមក្នុងការផ្តល់ជាគំនិតក្នុងការរៀបចំឯកសារតួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយនៅកម្ពុជា ដើម្បីឱ្យ ឆ្លើយតបទៅនឹងការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មកម្ពុជា។

**ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ**

# សេចក្តីផ្តើម

វិស័យកសិកម្មនៅតែជាវិស័យអាទិភាពមួយ ទ្រទ្រង់កំណើនសេដ្ឋកិច្ច ធានាសមធម៌ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទក្នុងបរិបទតម្រូវការទីផ្សារប្រកួតប្រជែងនៅក្នុងតំបន់ និងលើសាកលលោក ព្រមទាំង ការប្រែប្រួលអាកាសធាតុ។ វិស័យកសិកម្មបានទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ តែវិស័យកសិកម្មក៏បាន ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបន្សាំ បង្កើនភាពធន់ និងបន្ធូរបន្ថយផលប៉ះពាល់ការប្រែប្រួលអាកាសធាតុដើម្បីធានា ប្រព័ន្ធផលិត ចែកចាយ និងផ្គត់ផ្គង់ស្បៀងមាននិរន្តរភាពសម្រាប់សន្តិសុខស្បៀង និងអាហាររូបត្ថម្ភ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាបច្ចេកទេស និងការអនុវត្តកសិកម្មល្អនានាដូចជា ពូជដំណាំធន់ ពូជសត្វ ការអនុវត្តប្រព័ន្ធកសិកម្មចម្រុះ ប្រពលវប្បកម្មដំណាំ សត្វ សួនដំណាំគ្រួសារ កសិកម្មអភិរក្ស ប្រព័ន្ធដំណាំ ស្បៀង និងថាមពលចម្រុះ ការប្រើប្រាស់ថាមពលទាប នៃប្រព័ន្ធវារីវប្បកម្ម ប្រព័ន្ធគ្រប់គ្រងព្រៃឈើ ដី និងទឹកមាន និរន្តរភាព និងកសិ-រុក្ខកម្ម។ល។

ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំ បណ្តុះបណ្តាល និងផ្ទេរបច្ចេកទេស បច្ចេកវិទ្យា និងការអនុវត្តកសិកម្មល្អថ្មីៗដល់កសិករ និងសហគមន៍កសិករសំដៅលើកកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម បង្កើនប្រាក់ចំណូលគ្រួសារ ព្រមទាំងបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុ គ្រោះធម្មជាតិ និងវិបត្តិនានា។

អាណត្តិផ្សព្វផ្សាយកសិកម្មរដ្ឋនៅកម្ពុជា គឺស្ថិតនៅក្នុងនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី/ខេត្ត បានផ្តល់សេវាផ្សព្វផ្សាយកសិកម្មតាមបែបពហុនិយម និង តាមតម្រូវការជាក់ស្តែងនៅមូលដ្ឋាន។

ឯកសារតួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយនៅកម្ពុជា បានបង្កើតឡើងដើម្បីបង្កើនប្រសិទ្ធភាពសេវាផ្សព្វផ្សាយកសិកម្មតាមលក្ខណៈពហុនិយម និងតាមតម្រូវការព្រមទាំងមានកំណត់តួនាទី និងការទទួលខុសត្រូវ របស់អង្គភាព និងតួអង្គផ្សព្វផ្សាយកសិកម្មទាំងអស់ដើម្បីទទួលបានតាមតម្រូវការកសិករ និងផ្តល់សេវាផ្សព្វផ្សាយកសិកម្មមានគុណភាពខ្ពស់។ ឯកសារតួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយនៅកម្ពុជា ឯកសារនេះពិពណ៌នាពី យន្តការគាំទ្រ និងទំនាក់ទំនង ភាពជាដៃគូ ឧបករណ៍ វិធីសាស្រ្ត និងមធ្យោបាយក្នុងការផ្តល់សេវាផ្សព្វផ្សាយ កសិកម្មទៅតាមតម្រូវការកសិករ និងអ្នកប្រើប្រាស់។

ឯកសារតួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយនៅកម្ពុជា បង្ហាញនូវតួនាទីជាទូទៅរបស់មន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មគឺជារួមមានតួនាទីអប់រំកសិករ សហគមន៍មូលដ្ឋាន និងអ្នកផលិតឱ្យពួកគាត់ចេះជួយខ្លួនឯងបាន ជួយភ្ជាប់កសិករ/អ្នកផលិតជាមួយមូលដ្ឋានព័ត៌មានស្រាវជ្រាវបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាព គុណភាព សេវាកម្ម និងសុវត្ថិភាពផលិតផលកសិកម្ម។ តួនាទីមន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មរបស់រដ្ឋគឺជាភ្នាក់ងារ កណ្តាលសម្របសម្រួលរវាងកសិករ និងអ្នកស្រាវជ្រាវ អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម អ្នកផ្តល់ឥណទាន និងវិស័យឯកជន ហើយតួនាទីមួយទៀតគឺអន្តរាគមន៍បច្ចេកទេស និងព័ត៌មានកសិកម្ម។

ឯកសារតួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយនៅកម្ពុជាក៏បានពិពណ៌នាពីតួនាទី និងការទទួល ខុសត្រូវរបស់ស្ថាប័ន អង្គភាពនានា និងអ្នកពាក់ព័ន្ធនានាក្នុងការគាំទ្រ ណែនាំ សម្របសម្រួលជំរុញការអនុវត្តច្បាប់ និងបទបញ្ញត្តិនានា តាមដានត្រួតពិនិត្យ និងវាយតម្លៃ ការធានាគុណភាព និងការអនុវត្តការផ្តល់សេវាផ្សព្វផ្សាយ កសិកម្មនៅគ្រប់កម្រិត។

## ១.ប្រវត្តិផ្សព្វផ្សាយកសិកម្មនៅកម្ពុជា

ការងារផ្សព្វផ្សាយកសិកម្មកើតមានតាំងពីមុនទសវត្សរ៍ទី៦០មកម្ល៉េះគឺៈ នៅឆ្នាំ១៩៥៧ ក្រសួងកសិកម្មបានបង្កើតការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មដែលជាផ្នែកមួយនៅក្នុងអង្គភាពកណ្តាល និងតាមអង្គភាពមូលដ្ឋាននៃអគ្គនាយកដ្ឋានកសិកម្មដែលមានភារកិច្ចធ្វើការអប់រំ ផ្សព្វផ្សាយបច្ចេកទេស និងព័ត៌មានកសិកម្មដោយមានដំណើរការរហូតដល់ឆ្នាំ១៩៧៥។ នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មិនមានរចនាសម្ព័ន្ធ និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ទេហើយហេដ្ឋារចនាសម្ព័ន្ធធនធានមនុស្ស និងសេវាផ្សព្វផ្សាយកសិកម្មត្រូវបានបំផ្លាញដល់ឫសគល់ ព្រមទាំងអ្នក បច្ចេកទេសកសិកម្ម និងអ្នកផ្សព្វផ្សាយបច្ចេកទេសកសិកម្មត្រូវបានកាប់សម្លាប់ដោយរបបខ្មែរក្រហមប៉ុលពត។

ក្រោយថ្ងៃរំដោះ៧ខែមករា ឆ្នាំ១៩៧៩ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទត្រូវបានបង្កើតឡើងវិញដោយក្នុងខែតុលា ឆ្នាំ១៩៨០ បានបង្កើតគណៈកម្មាធិការរៀបចំអត្ថបទ និងឯកសារបច្ចេកទេសកសិកម្មដើម្បីផ្សព្វផ្សាយតាមវិទ្យុ និងសារព័ត៌មាននានា ហើយនៅខែកញ្ញាឆ្នាំ១៩៨៦ ក្រសួងកសិកម្មបានបង្កើតការិយាល័យអប់រំ និងផ្សព្វផ្សាយបច្ចេកទេសកសិកម្មដែលស្ថិតនៅក្រោមការដឹកនាំរបស់ (មន្ទីរ) នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទដែលមានតួនាទីស្មើនឹងអគ្គលេខាធិការដ្ឋានបច្ចុប្បន្ន។

ដោយយោងតាមការរីកចម្រើនវិស័យកសិកម្ម និងការងារផ្សព្វផ្សាយកសិកម្មរួមទាំងតម្រូវការបច្ចេកទេស និងព័ត៌មានរបស់កសិករ **នាយកដ្ឋានបច្ចេកទេស សេដ្ឋកិច្ច និងផ្សព្វផ្សាយ** ត្រូវបានបង្កើតឡើងនៅខែឧសភា ឆ្នាំ១៩៩៥ ហើយនៅក្នុងឆ្នាំ២០០០ បានប្តូរឈ្មោះមកជា**នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម**។ នៅក្នុងឆ្នាំ២០០៨ នាយកដ្ឋានផ្សព្វផ្សាយ កសិកម្មបានកែសម្រួលដាក់ឱ្យនៅក្រោមចំណុះអគ្គនាយកដ្ឋានកសិកម្ម ដោយអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជារហូតមកដល់ពេលបច្ចុប្បន្ន។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្មមានការិយាល័យចំនួន៤ និងអង្គភាពមូលដ្ឋានចំនួន២ ព្រមទាំងមានបណ្តាញទំនាក់ទំនងការិយាល័យផ្សព្វផ្សាយកសិកម្មរាជធានី/ខេត្តគឺៈ

- ការិយាល័យ រដ្ឋបាល ផែនការ គណនេយ្យ និងសហប្រត្តិបត្តិការ អន្តរជាតិ (រ.ផ.គ.ស.អ)
- ការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស
- ការិយាល័យអប់រំ និងផ្សព្វផ្សាយកសិកម្ម
- ការិយាល័យប្រព័ន្ធកសិកម្ម និងសេដ្ឋកិច្ចកសិកម្ម
- មជ្ឈមណ្ឌលបណ្តុះបណ្តាលកសិករគំរូតំបន់អភិវឌ្ឍន៍ខាងលិចរាជធានីភ្នំពេញ (ខេត្តកំពង់ស្ពឺ) និង

- មជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្មតាស្អាង (ខេត្តស្វាយរៀង) ។

ចាប់ពីឆ្នាំ១៩៨៨ ដល់ ឆ្នាំ ២០០៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម បានសហការជាមួយអង្គការក្រៅរដ្ឋាភិបាល និងបានបណ្តុះបណ្តាលគ្រូបង្គោលផ្សព្វផ្សាយកសិកម្ម និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មបានចំនួន១,៧៧១ នាក់។

មកដល់ឆ្នាំ ២០១៥ ចំនួនមន្ត្រីក្របខ័ណ្ឌផ្សព្វផ្សាយកសិកម្មទាំងនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិមានការថយចុះដោយមន្ត្រីមួយចំនួនចូលនិវត្តន៍ និងមន្ត្រីមួយចំនួនទៀតដែលកំពុងធ្វើការនៅការិយាល័យ អង្គការកសិករ នៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្មបានដំឡើងទៅជានាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មថ្មី តាមអនុក្រឹត្យលេខ ១៧៩ អនក្រ បក. ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០១៤ ហើយមន្ត្រីខ្លះទៅធ្វើការជាមួយដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។ល។ តែភ្នាក់ងារផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅមូលដ្ឋានរបស់ដៃគូរអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនមានការកើនឡើងដែលក្នុងនោះចំនួនក្របខ័ណ្ឌមន្ត្រីផ្សព្វផ្សាយកសិកម្មដែលកំពុងអនុវត្ត និងសម្របសម្រួលការងារផ្សព្វផ្សាយកសិកម្មនៅកម្ពុជាមាន៖ មន្ត្រីផ្សព្វផ្សាយកសិកម្មនៅថ្នាក់ កណ្តាលមានចំនួន៣៥នាក់ នៅថ្នាក់រាជធានីខេត្តចំនួន១៤៩ នាក់ និងថ្នាក់ស្រុកចំនួន៤១៦នាក់ រួមបញ្ចូលទាំងមន្ត្រីបំរើការងាររដ្ឋបាលផង (ទិន្នន័យនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្សឆ្នាំ២០១៥)។ ដោយឡែកការផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅមូលដ្ឋានមានការចូលរួមពីភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំចំនួន៨៤៦នាក់ ភ្នាក់ងារផ្សព្វផ្សាយ ភូមិចំនួន៩.២៧៦នាក់នៃចំនួនភ្នាក់ងារសុខភាពសត្វភូមិ១២.០៦៧៤នាក់។

ដើម្បីអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មក្នុង១.០០០គ្រួសារកសិករ តម្រូវឱ្យមានមន្ត្រីឯកទេសផ្សព្វផ្សាយកសិកម្ម១នាក់សម្រាប់ដឹកនាំ សម្របសម្រួល និងអនុវត្តការផ្សព្វផ្សាយបច្ចេកវិទ្យា បច្ចេកទេស និងការអនុវត្តកសិកម្មថ្មីៗដល់កសិករ និងសហគមន៍កសិករ។ ដូចនេះតម្រូវឱ្យមានមន្ត្រីផ្សព្វផ្សាយកសិកម្មយ៉ាងតិច ២,១០០ នាក់ នៃចំនួនគ្រួសារកសិករ ២,១លានគ្រួសារដែលបច្ចុប្បន្ននេះមានមន្ត្រីផ្សព្វផ្សាយកសិកម្ម៦០០នាក់ ចាំបាច់ត្រូវបណ្តុះបណ្តាលបន្ថែម១.៦០០ នាក់ទៀតដើម្បីបំពេញចំនួនក្របខ័ណ្ឌមន្ត្រីផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិឱ្យបាន៥០ នាក់នៅថ្នាក់ក្រោមជាតិឱ្យ បានចំនួន២.០៥០នាក់ក្នុងនោះថ្នាក់ខេត្ត ២៥០នាក់ (១០ នាក់ក្នុង១ខេត្ត) និងស្រុក/ ខណ្ឌ ១.៨០០ នាក់តាមសមាមាត្រ ចំនួនឃុំ (ចំនួនស្រុកសរុប ១៩៤ស្រុក និងឃុំ/សង្កាត់ សរុប ១.៦៤៦ឃុំ/សង្កាត់) ។

## ២.លក្ខណៈពិសេសនៃគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា

ក្របខណ្ឌនៃគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានអនុម័តឱ្យប្រើប្រាស់ជាផ្លូវការនៅខែមេសា ឆ្នាំ២០១៥ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចង្អុលបង្ហាញឱ្យបង្កើតឯកសារតួនាទី និងការទទួល ខុសត្រូវសម្រាប់ការផ្សព្វផ្សាយនៅកម្ពុជា ដើម្បីជំរុញការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្ម បទប្បញ្ញត្តិនានា គាំទ្រសម្របសម្រួល និងប្រតិបត្តិការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ ការផ្សព្វផ្សាយកសិកម្មត្រូវបានផ្លាស់ប្តូរយុទ្ធសាស្ត្រ ពីការផ្សព្វផ្សាយដែលជំរុញផ្នែកផ្គត់ផ្គង់ ដើម្បីផលិតកម្មទៅរកការផ្សព្វផ្សាយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ការប្រកួតប្រជែង ការបង្កើនតម្លៃបន្ថែម និងការធានានិរន្តរភាព

ព្រមទាំងការផ្សព្វផ្សាយតាមបែបពហុនិយម។ បង្កើត ភាពជាដៃគូកិច្ចសហការ និងបណ្តាញទាក់ទងគ្នា ដែលជាទិដ្ឋភាពដ៏សំខាន់នៃសេវាផ្សព្វផ្សាយកសិកម្មតាមបែប ពហុនិយម។

### ការផ្សព្វផ្សាយតាមបែបពហុនិយម

ត្រូវធានាត្រូវបានការអនុវត្តការផ្សព្វផ្សាយកសិកម្ម តាមបែបពហុនិយម ដោយមានការចូលរួមពីគ្រប់ភាគីពាក់ ព័ន្ធសំខាន់ៗមានរដ្ឋ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល សមាគមដៃគូរអភិវឌ្ឍន៍ និងសហគមន៍កសិករមូលដ្ឋាន។ល។ ដើម្បីធានាកសិករ និងសហគមន៍កសិករមូលដ្ឋានទាំងអស់នៅកម្ពុជាទទួលបានសេវាផ្សព្វផ្សាយកសិកម្មមានគុណភាពខ្ពស់ និងតាមតម្រូវការជាក់ស្តែង។ ប្រសិទ្ធភាពនៃសេវាផ្សព្វផ្សាយកសិកម្មទទួលបានមកដោយផ្ទាល់ពីកិច្ចសហការ និងការចងបណ្តាញរវាងអ្នកពាក់ព័ន្ធនានាក្នុងការផ្តល់សេវាផ្សព្វផ្សាយ។

### ការផ្សព្វផ្សាយតាមតម្រូវការ

ការផ្សព្វផ្សាយកសិកម្ម ត្រូវឆ្លើយតបទៅតាមតម្រូវការកសិករ សហគមន៍មូលដ្ឋាន អ្នកផលិត និងទីផ្សារដោយ ផ្តោតតាមលទ្ធភាព និងធនធានដែលមានរបស់កសិករ។ អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ត្រូវសិក្សាវាយតម្លៃ និង ពិភាក្សាជាមួយកសិករពីតម្រូវការសេវាសមស្របនានា ដែលត្រូវគាំទ្រសម្រាប់ការសិក្សារបស់កសិករជាមួយតម្រូវការទីផ្សារ។

### ភាពទទួលខុសត្រូវ

គណនេយ្យភាព ឬការទទួលខុសត្រូវ មិនត្រូវពិនិត្យតែទៅលើអ្នកទទួលផលឬអតិថិជនទទួលសេវាផ្សព្វផ្សាយ ទេត្រូវរៀបចំ និងពិនិត្យលើយន្តការ គោលការណ៍ណែនាំ និងបទប្បញ្ញត្តិ ធានាគុណភាព និងប្រសិទ្ធភាពសេវាផ្សព្វផ្សាយ ផ្សារភ្ជាប់ជាមួយតម្រូវការជាក់ស្តែង-ទីផ្សារ។

ត្រូវបង្កើតគោលការណ៍ណែនាំវិធានការណ៍នៃការអនុវត្តស្តង់ដារការងារ សម្រាប់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាពនៃសេវាផ្សព្វផ្សាយ។ ការធានាគុណភាពក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មអាចសម្រេចទៅបានតាមរយៈវិធានការណ៍៖ កំណត់កម្រិតគុណវឌ្ឍអប្បបរមា ដែលអាចទទួលយកបានសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម បង្កើតគោលការណ៍ណែនាំសម្រាប់ការអនុវត្តកម្មវិធីផ្សព្វផ្សាយនៅថ្នាក់ស្រុក និងបង្កើតនិងអនុវត្តប្រព័ន្ធគណនេយ្យភាព និងដាក់ពិន្ទុ លើអង្គភាព និងភ្នាក់ងារផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។

## ៣.ចក្ខុវិស័យ គោលបំណង និងគោលដៅ

ដើម្បីសម្រេចបាននូវចក្ខុវិស័យគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ឯកសារតួនាទី និងការទទួល ខុសត្រូវសម្រាប់ការផ្សព្វផ្សាយនៅកម្ពុជា មានចក្ខុវិស័យគឺធ្វើយ៉ាងណាឱ្យកសិករ និងសហគមន៍កសិករ និងអ្នកផលិត ទាំងអស់នៅកម្ពុជាទទួលបានសេវាផ្សព្វផ្សាយកសិកម្មមានគុណភាពខ្ពស់ និងតាមតម្រូវការ។

**គោលបំណង**

ដើម្បីសម្រេចបានចក្ខុវិស័យខាងលើឯកសារតួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយនៅកម្ពុជា មានគោលបំណង ដូចគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជាគឺៈកសិករ និងសហគមន៍កសិករទាំងអស់នៅ កម្ពុជានឹងទទួលបាន និងប្រើប្រាស់ចំណេះដឹងព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មបានល្អប្រសើរ ដើម្បីលើកកម្ពស់ផលិតភាព
ពិពិធភាវូបនីយកម្ម ពាណិជ្ជូបនីយកម្មកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

**គោលដៅ**

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើឯកសារតួនាទី និងការទទួលខុសត្រូវ សម្រាប់ការផ្សព្វផ្សាយនៅកម្ពុជាមានគោលដៅជាក់លាក់ដូចខាងក្រោមៈ

- ធ្វើឱ្យប្រសើរឡើងនូវតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័ន អង្គភាព និងប្រព័ន្ធផ្សព្វផ្សាយកសិកម្មគ្រប់កម្រិត ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពនៃការប្រតិបត្តិ ការសហការ ការសម្របសម្រួល និងពង្រឹងការ ទំនាក់ទំនងរវាងតួអង្គពាក់ព័ន្ធទាំងអស់
- ធ្វើឱ្យប្រសើរឡើង និងកំណត់បាននូវយន្តការគាំទ្រ សម្របសម្រួល និងប្រតិបត្តិការផ្តល់សេវាកម្មផ្សព្វផ្សាយ កសិកម្ម ដើម្បីឆ្លើយតបទៅនឹងតម្រូវការកសិករ អ្នកផលិត និងទីផ្សារ
- ពង្រឹងការទំនាក់ទំនង និងផ្សារភ្ជាប់រវាងស្ថាប័ន និងអង្គភាពក្នុងការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាសមស្រប និងសម្ភារផ្សព្វផ្សាយនូវបច្ចេកវិទ្យាទាំងនេះមានគ្រប់គ្រាន់សម្រាប់កសិករ និងអ្នកផលិតទទួលយកបាន មានលទ្ធភាពប្រើប្រាស់បាន និងយកទៅអនុវត្តបាន
- អភិវឌ្ឍសម្ភារផ្សព្វផ្សាយ និងជំរុញឱ្យមានការទទួលយក និងប្រើប្រាស់នូវចំណេះដឹង ព័ត៌មាន បច្ចេកវិទ្យាកសិកម្មឱ្យមានប្រសិទ្ធភាពនិង
- បង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាកម្មផ្សព្វផ្សាយកសិកម្ម ដើម្បីលើកកម្ពស់ការសម្រេចចិត្តរបស់កសិករ និងសហគមន៍កសិករ ដើម្បីបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម ពាណិជ្ជូបនីយកម្មកសិកម្ម និងបង្កើនប្រាក់ចំណូល។

## ៤.អភិក្រម និងយុទ្ធសាស្ត្រ

ការផ្តល់សេវាផ្សព្វផ្សាយយកសិកម្ម ត្រូវមានយន្តការប្រទាក់ក្រឡាគ្នាមានគោលនយោបាយ និងបទដ្ឋានគតិយុត្តិ រចនាសម្ព័ន្ធ និងអង្គការចាត់តាំងស្ថាប័ន និងប្រតិបត្តិការផ្តល់សេវាផ្សព្វផ្សាយ។ ការផ្សព្វផ្សាយកសិកម្មត្រូវមានយន្តការ ធនធាន និងមានប្រព័ន្ធធានាគុណភាពតាមរយៈការអភិវឌ្ឍ និងអនុវត្តគោលការណែនាំ និងនិយ័តកម្មថ្មីៗសម្រាប់អ្នក ផ្តល់សេវាកម្មផ្សព្វផ្សាយ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម គ្រឹះស្ថានអប់រំកសិកម្ម អង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍មូលដ្ឋាន និងកសិករ។

ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មត្រូវអនុវត្តតាមតម្រូវការកសិករ និងទីផ្សារ ធានាឱ្យមានភាពជាដៃគូ ដើម្បី ជំរុញការផ្សព្វផ្សាយតាមបែបពហុនិយម មានយន្តការបទប្បញ្ញត្តិ និងគោលការណ៍ណែនាំថ្មីៗការពង្រឹង សមត្ថភាពមន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម មានបច្ចេកវិទ្យា បច្ចេកទេស និងការអនុវត្តកសិកម្មល្អថ្មី និង សម្ភារព្រមទាំងការអនុវត្តយុទ្ធវិធី និងវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាព និងនវានុវត្តភាពជាពិសេសការ ប្រើប្រាស់បច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន(ICT) ជាយានចម្បងក្នុងការផ្សព្វផ្សាយបញ្ជូនសារ និងព័ត៌មាន។

ឯកសារតួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយនៅកម្ពុជានេះ គឺពិពណ៌នាផ្តោតលើការ អនុវត្តយន្តការតួនាទី និងការទទួលខុសរបស់ស្ថាប័ន អង្គភាពផ្សព្វផ្សាយ អង្គភាពជំនាញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅថ្នាក់ក្រោមជាតិ ដើម្បីលើកម្ពស់ការផ្តល់សេវា ផ្សព្វផ្សាយកសិកម្ម មានប្រសិទ្ធភាព។

## ៥.រចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវលើការផ្សព្វផ្សាយកសិកម្ម

តួនាទីរបស់រដ្ឋក្នុងការផ្សព្វផ្សាយកសិកម្ម គឺជាភ្នាក់ងារកណ្តាលសម្របសម្រួលរវាងកសិករ និងអ្នក ស្រាវជ្រាវ អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម អ្នកផ្តល់ឥណទាន និងវិស័យឯកជនហើយតួនាទីមួយទៀតគឺអន្តរាគមន៍ បច្ចេកទេសនិងព័ត៌មានកសិកម្ម។ បន្ថែមពីនេះតួនាទីរបស់រដ្ឋក្នុងការផ្សព្វផ្សាយកសិកម្ម គឺធ្វើឱ្យប្រសើរឡើងនូវ ដំណើរការសិក្សា ដកបទពិសោធន៍រវាងអ្នកផ្សព្វផ្សាយ និងកសិករចូលរួម។ មុខងារចម្បងរបស់ការងារ ផ្សព្វផ្សាយកសិកម្មជារួម៖

១. វិភាគស្ថានភាពសេដ្ឋកិច្ចសង្គមរបស់កសិករ និងលក្ខខណ្ឌគ្យេត្របរិស្ថាន កាលានុវត្តភាព និងកត្តា ឧបសគ្គ

និងដោះស្រាយទៅតាមបរិបទតម្រូវការកសិករ ទីផ្សារ និងការប្រកួតប្រជែង។

២.ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មតាមរយៈវគ្គបណ្តុះបណ្តាលប្រព័ន្ធផ្សព្វផ្សាយសាធារណៈ និងតាម រយៈការ ទំនាក់ទំនងផ្ទាល់រវាងអ្នកផ្សព្វផ្សាយកសិកម្ម និងកសិករ។

៣.ការផ្តល់ព័ត៌មានត្រឡប់ទាន់ពេលវេលាអំពីប្រតិកម្មត្រឡប់របស់កសិករ ទៅលើ បច្ចេកទេសថ្មីៗទៅឱ្យអ្នក ស្រាវជ្រាវ ដើម្បីធ្វើការកែតម្រូវកម្មវិធីនៃការស្រាវជ្រាវ។

៤.បង្កើតបណ្តាញទំនាក់ទំនងរវាងអ្នកស្រាវជ្រាវ អ្នកធ្វើផែនការរបស់រដ្ឋ អង្គការមិនមែនរដ្ឋាភិបាល អង្គការ កសិករ អង្គការសហគមន៍មូលដ្ឋាន កសិករគំរូ គ្រឹះស្ថានហិរញ្ញវត្ថុ និងផ្នែកឯកជន។

អាណត្តិផ្សព្វផ្សាយកសិកម្មរដ្ឋនៅកម្ពុជា គឺស្ថិតនៅក្នុងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋាន កសិកម្ម ផ្នែកផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយនៅថ្នាក់ក្រោមជាតិគឺនៅក្នុង ការិយាល័យ ផ្សព្វផ្សាយកសិកម្មនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត និងការិយាល័យ កសិកម្មស្រុក ក្រុងខណ្ឌ។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ដោយមានសហការគាំទ្រដោយអង្គភាពជំនាញពាក់ព័ន្ធនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានតួនាទី និងការទទួលត្រូវខុសត្រូវក្នុងការកែលម្អគុណភាព និងចំណេះដឹង ផ្សព្វផ្សាយកសិកម្ម ការពង្រឹងសមត្ថភាពធនធានមនុស្សផ្សព្វផ្សាយកសិកម្ម និងជួយគាំទ្រការកែលម្អការផ្តល់សេវា ផ្សព្វផ្សាយកសិកម្មដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត និងអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មផ្សេងៗទៀត។ ដើម្បីអនុវត្តការផ្សព្វផ្សាយកសិកម្មមានប្រសិទ្ធភាព និងការទទួលត្រូវ ត្រូវមានមានយន្តការនិង រចនាសម្ព័ន្ធព្រមទាំងមានកំណត់តួនាទី និងការទទួលខុសច្បាស់លាស់។

### យន្តការ និងរចនាសម្ព័ន្ធផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិ

នៅថ្នាក់ជាតិការផ្សព្វផ្សាយកសិកម្មត្រូវបានដំណើរការ និងសម្របសម្រួលដោយៈ

- គណៈកម្មាធិការប្រឹក្សាយោបល់ផ្សព្វផ្សាយកសិកម្ម
- អនុគណៈកម្មាធិការបច្ចេកទេសកសិកម្មថ្នាក់ជាតិ
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ជាលេខាធិការដ្ឋាន
- អង្គភាពជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
- គ្រឹះស្ថានអប់រំកសិកម្មនានា (មានសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលាប និងកំពង់ចាម។ល។) ។

### យន្តការ និងរចនាសម្ព័ន្ធផ្សព្វផ្សាយកសិកម្មនៅថ្នាក់ក្រោមជាតិ

នៅថ្នាក់ក្រោមជាតិការផ្សព្វផ្សាយកសិកម្មត្រូវបានដំណើរការ និងសម្របសម្រួលដោយៈ

- ក្រុមការងារផ្សព្វផ្សាយកសិកម្ម រាជធានី/ខេត្ត
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តៈ
    - ការិយាល័យផ្សព្វផ្សាយកសិកម្ម
    - ការិយាល័យ និងផ្នែកជំនាញនានានៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រុមគាំទ្របច្ចេកទេសកសិកម្មស្រុក/ ក្រុង/ ខណ្ឌ
- ការិយាល័យកសិកម្មស្រុក/ ក្រុង/ ខណ្ឌ
- ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ/សង្កាត់ ។ល។

### ៥.១.គណៈកម្មាធិការប្រឹក្សាយោបល់ផ្សព្វផ្សាយកសិកម្ម

គណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្ម បានបង្កើតឡើងដែលមានសមាសភាព មក ពីអង្គភាពពាក់ព័ន្ធនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្នែកឯកជន

តំណាងកសិករមានភារកិច្ចតួនាទីធ្វើការ ណែនាំនិងសម្របសម្រួលកម្មវិធីផ្សព្វផ្សាយកសិកម្មនៅកម្ពុជា។ គណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយ កសិកម្មមានតួនាទី និងភារកិច្ចសំខាន់ដូចខាងក្រោម៖

- គាំទ្រ និងសម្របសម្រួលសកម្មភាពទំនាក់ទំនងរវាងការស្រាវជ្រាវ ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលកសិកម្ម
- ជំរុញ និងគាំទ្រការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជាឱ្យមានប្រសិទ្ធភាពកាន់តែល្អប្រសើរឡើង
- គាំទ្រសម្របសម្រួល និងណែនាំរាល់សកម្មភាពផ្សព្វផ្សាយកសិកម្មនៅក្នុងគម្រោង និងកម្មវិធីនានានៅកម្ពុជា
- គៀងគរធនធាន និងថវិកាគាំទ្រដល់កម្មវិធីគម្រោង និងសកម្មភាពផ្សព្វផ្សាយកសិកម្មនានានៅកម្ពុជា
- ពិនិត្យ និងសម្រេចលើកញ្ចប់មូលនិធិរួម (Trust Fund) សម្រាប់អនុវត្តការងារផ្សព្វផ្សាយកសិកម្មដែលគ្រប់គ្រង ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ណែនាំពិនិត្យ និងសម្រេចលើកម្មវត្ថុ និងប្រធានបទការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗសម្រាប់ផ្សព្វផ្សាយកសិកម្ម
- ពិនិត្យ និងសម្រេចកម្មវិធីអភិវឌ្ឍធនធានមនុស្សផ្សព្វផ្សាយកសិកម្ម មានកម្មវិធីសិក្សា និងការបណ្តុះបណ្តាលមន្ត្រី និង ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម
- ពិនិត្យ និងសម្រេចលើគោលការណ៍ណែនាំ ប្រធានបទកម្មវត្ថុ ឯកសារ សម្ភារ និងសារផ្សព្វផ្សាយកសិកម្ម
- ពិនិត្យ និងសម្រេចលើមធ្យោបាយ និងវិធីសាស្ត្រសេវាផ្សព្វផ្សាយកសិកម្ម
- ពិនិត្យ តាមដាន និងវាយតម្លៃរាល់សកម្មភាពផ្សព្វផ្សាយកសិកម្មនានានៅកម្ពុជាដែលអនុវត្តដោយវិស័យ សាធារណៈវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា
- ផ្តល់អនុសាសន៍សម្រាប់កែលម្អប្រព័ន្ធសេវាផ្សព្វផ្សាយកសិកម្មនៅកម្ពុជា។

## ៥.២.អនុគណៈកម្មាធិការបច្ចេកទេសកសិកម្មថ្នាក់ជាតិ

អនុគណៈកម្មាធិការបច្ចេកទេសកសិកម្មថ្នាក់ជាតិស្ថិត ក្រោមគណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មដែលមានសមាសភាពជាតំណាងមកពីអង្គភាពពាក់ព័ន្ធនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកឯកជនដោយមានភារកិច្ចធ្វើការណែនាំ និងសម្របសម្រួលការអភិវឌ្ឍបច្ចេកវិទ្យាកសិកម្ម សម្ភារ និងសារផ្សព្វផ្សាយកសិកម្ម។ អនុគណៈកម្មាធិការបច្ចេកទេសកសិកម្មថ្នាក់ជាតិមានតួនាទី និងភារកិច្ចសំខាន់ដូចខាងក្រោម៖

- វិភាគ និងកសាងផែនការអភិវឌ្ឍន៍បច្ចេកកសិកម្មថ្នាក់ជាតិរយៈពេលខ្លី មធ្យម និងរយៈពេលវែង
- តាមដានការអនុវត្ត និងការទទួលយកបច្ចេកវិទ្យាដែលបានផ្សព្វផ្សាយ

- សហការសម្របសម្រួលជាមួយអង្គភាពជំនាញពាក់ព័ន្ធដើម្បីចងក្រង និងវាយតម្លៃលើឯកសារផ្សព្វផ្សាយ សម្រាប់ប្រើប្រាស់
- សម្របសម្រួល និងចាត់ចែងរៀបចំប្រជុំត្រួតពិនិត្យលើគុណវឌ្ឍនៃការងារផ្សព្វផ្សាយកសិកម្ម
- ត្រួតពិនិត្យ និងវាយតម្លៃលើគោលការណ៍ណែនាំ បទដ្ឋានអនុវត្តបច្ចេកវិទ្យា ការស្រាវជ្រាវការផ្សព្វផ្សាយ កសិកម្ម និងអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ
- ត្រួតពិនិត្យ និងសម្រេចលើកម្មវត្ថុ ឯកសារ សម្ភារ មធ្យោបាយ និងវិធីសាស្ត្រសេវាផ្សព្វផ្សាយកសិកម្ម
- ពិនិត្យ កែសម្រួល និងផ្តល់អនុសាសន៍រាល់វិធីសាស្ត្រ និងសេវាផ្សព្វផ្សាយកសិកម្ម
- ទទួលចម្លើយតបពីអ្នកអនុវត្តដើម្បីសិក្សាបន្ត និងអភិវឌ្ឍន៍បច្ចេកវិទ្យាស្របតាមតម្រូវការ
- រៀបចំ កសាងលើកម្មវត្ថុ ប្រធានបទ ការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗសម្រាប់ផ្សព្វផ្សាយកសិកម្ម
- រៀបចំបូកសរុបរបាយការណ៍នៃកិច្ចប្រជុំពាក់ព័ន្ធ និងរបាយការណ៍វឌ្ឍនភាពដាក់ជូនគណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្ម
- បំពេញភារកិច្ចផ្សេងៗទៀតដែលគណគណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មប្រគល់ជូន។

## ៥.៣.ក្រុមផ្សព្វផ្សាយកសិកម្ម និងទឹក (ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក)

ក្រុមផ្សព្វផ្សាយកសិកម្ម និងទឹកថ្នាក់ជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ដែលមានសមាសភាពជាតំណាងមកពីអង្គភាពពាក់ព័ន្ធនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្នែកឯកជន និង អង្គការមិនមែនរដ្ឋាភិបាល ។

ក្រុមផ្សព្វផ្សាយកសិកម្ម និងទឹកមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជួយដល់ក្រុមការងារបច្ចេកទេសកសិម្ម និងទឹកក្នុងការគាំទ្រដល់ការអនុវត្តគោលនយោបាយផ្សព្វផ្សាយ កសិកម្ម និងធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួល និងភ្ជាប់បណ្តាញទំនាក់ទំនងស្រាវជ្រាវ ការអប់រំ បណ្តុះបណ្តាលក្នុងវិស័យកសិម្ម និងទឹកក៏ដូចជាការស្រោចស្រព និងផលិតកម្មកសិកម្ម
- គាំទ្រដល់ការរៀងគរ និងសម្របសម្រួលធនធាន សម្រាប់ការងារផ្សព្វផ្សាយកសិកម្មនិងធារាសាស្ត្រក្នុងការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្ម
- សម្របសម្រួល ការចែករំលែកចំណេះដឹង ការជួយគាំទ្រ និងលើកទឹកចិត្តការសិក្សាអ្នកពាក់ព័ន្ធ និងការគាំទ្រ ការសហការសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវអនុផ្នែកការផ្សព្វផ្សាយ និងសម្របសម្រួលមតិទូទៅ និងការ ព្រមព្រៀងក្នុងដំណើរការនៃពិនិត្យបច្ច័យ/ និងពិនិត្យឡើងវិញនៃទំនាក់ទំនងយុទ្ធសាស្ត្រ គោលការណ៍ណែនាំ បច្ចេកទេស ផែនការការងារប្រតិបត្តិទាក់ទងទៅ និងសេវាកម្មផ្សព្វផ្សាយ។

## ៥.៤.តួនាទី និងភារកិច្ចនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ជាលេខាធិការដ្ឋាន

អាណត្តិនាយកដ្ឋានផ្សព្វផ្សាយកសិកម្មក្នុងការគាំទ្រ សម្របសម្រួល ពិនិត្យតាមដាន និងវាយតម្លៃសកម្មភាព របស់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម និងទទួលស្គាល់តួនាទីរបស់ភាគីពាក់ព័ន្ធនៅក្នុងការផ្តល់សេវាផ្សព្វផ្សាយ។ ក្នុងបរិបទការផ្តល់សេវាផ្សព្វផ្សាយកសិកម្មតាមតម្រូវការកសិករ ទីផ្សារ និងការប្រតិបត្តិការផ្សព្វផ្សាយកសិកម្មតាមបែបពហុនិយមនាយកដ្ឋានផ្សព្វផ្សាយកសិកម្មត្រូវ៖

១) ដើរតួនាទីជាលេខាធិការដ្ឋានគាំទ្រដល់គណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្ម និងអនុគណៈកម្មាធិការបច្ចេកទេសកសិកម្មថ្នាក់ជាតិ ។

២) លើកកម្ពស់ការអនុវត្តទស្សនៈពហុនិយម ក្នុងការផ្តល់សេវាផ្សព្វផ្សាយតាមរយៈបណ្តាញ និងវេទិកាផ្សព្វផ្សាយដែលមានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើន ដើម្បីសម្របសម្រួលសេវាផ្សព្វផ្សាយកសិកម្មសំដៅលើកកម្ពស់គុណភាពសេវា។

៣) កសាងសមត្ថភាពដល់មន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មដែលពាក់ព័ន្ធ។

៤) លើកកម្ពស់អនុវត្តបែបវិមជ្ឈការ និងវិសហមជ្ឈការក្នុងការផ្តល់សេវាផ្សព្វផ្សាយដល់មន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយ
កសិកម្ម និងអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មពាក់ព័ន្ធនានានៅថ្នាក់ក្រោមជាតិផ្សេងៗនៅគ្រប់កម្រិតដោយ អនុលោមតាមរចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា។

៥) ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីធានាគុណភាព និងការអនុវត្តសេវាផ្សព្វផ្សាយ នៅគ្រប់កម្រិត។

ដើម្បីធានាគុណភាព និងប្រសិទ្ធភាពដល់ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ត្រូវផ្តល់ការដឹកនាំកិច្ច ប្រតិបត្តិ និងការគ្រប់គ្រងសេវាផ្សព្វផ្សាយកសិកម្មរួមមាន៖

១) កំណត់អាទិភាពការផ្សព្វផ្សាយកសិកម្មជាតិដោយអនុលោមតាមយុទ្ធសាស្ត្រ និងគោលនយោបាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២) ការគ្រប់គ្រងមន្ត្រី និងការបណ្តុះបណ្តាលការងារផ្សព្វផ្សាយកសិកម្ម។

៣) គាំទ្រការធ្វើផែនការថវិកាតាមកម្មវិធីសម្រាប់សេវាផ្សព្វផ្សាយកសិកម្ម។

៤) បង្កើតបរិយាកាសលើកទឹកចិត្តឱ្យផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ចូលរួមក្នុងផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។

៥) ពង្រឹងការផ្សារភ្ជាប់ទំនាក់ទំនងរវាងការស្រាវជ្រាវ អប់រំ និងផ្នែកឯកជនតាមរយៈកិច្ចប្រជុំប្រចាំត្រីមាស និង វេទិការចែករំលែកបទពិសោធន៍ និងមេរៀននានាជាមួយភាគីពាក់ព័ន្ធ។

៦) គ្រប់គ្រង និងប្រតិបត្តិបណ្តុំព័ត៌មានឯកសារផ្សព្វផ្សាយកសិកម្ម (Extension Hub) ដោយសម្របសម្រួល ការផ្តល់នូវរូបភាព និងសម្ភារផ្សព្វផ្សាយដើម្បីបំពេញបន្ថែមដល់កម្មវិធី និងសកម្មភាពផ្សព្វផ្សាយ កសិកម្ម។

៧) អនុវត្តប្រព័ន្ធគណនេយ្យភាព ដើម្បីបង្ហាញពីប្រសិទ្ធភាពតាមរយៈការផ្តួចផ្តើមឱ្យមានប្រព័ន្ធតាមដាន និង វាយតម្លៃដ៏រឹងមាំមួយរួមបញ្ចូលទាំងប្រព័ន្ធព័ត៌មានគ្រប់គ្រង(MIS)សម្រាប់បណ្តាស្រុកនីមួយៗ។

៨) បង្កើតកិច្ចសន្យា ការផ្តល់សេវាផ្សព្វផផ្សាយកសិកម្ម រវាងអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មឯកជន ជាមួយ វិស័យសាធារណៈអង្គការមិនមែនរដ្ឋាភិបាល សហគមន៍កសិករ។ល។

៩) បង្កើតប្រព័ន្ធទទួលព័ត៌មានជាសំឡេងតាមរយៈទូរស័ព្ទ និងសារអេឡិចត្រូនិកសម្រាប់ការរាយការណ៍ អំពីជម្ងឺសត្វ សកម្មភាពបំផ្លាញធនធានធម្មជាតិ និងសម្រាប់សេវាសួរឆ្លើយអំពីបញ្ហាកសិកម្ម។

ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មមានតួនាទី និងការ ទទួលខុសត្រូវលម្អិតដូចខាងក្រោមដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានគតិយុត្តិ ដើម្បីកំណត់តួនាទីភារកិច្ចអ្នកពាក់ព័ន្ធដែលត្រូវចូលរួមយ៉ាងសកម្មធ្វើ ការងារផ្សព្វផ្សាយកសិកម្មឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព
- សហការជាមួយដៃគូរពាក់ព័ន្ធ សិក្សាស្រាវជ្រាវអំពីប្រសិទ្ធិភាពផ្សព្វផ្សាយកសិកម្ម និង តម្រូវការដើម្បីកំណត់អាទិភាពការងារផ្សព្វផ្សាយកសិកម្មជាតិ និងរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីផ្សព្វផ្សាយកសិកម្ម
- លើកកម្ពស់ការអនុវត្តទស្សនៈពហុនិយមក្នុងការផ្តល់សេវាផ្សព្វផ្សាយតាមរយៈបណ្តាញ និងវេទិកា ផ្សព្វផ្សាយ ដែលមានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើន ដើម្បីសម្របសម្រួលសេវាផ្សព្វផ្សាយកសិកម្ម សំដៅលើកកម្ពស់ គុណភាពសេវា និងប្រសិទ្ធភាព
- លើកកម្ពស់ការអនុវត្តតាមបែបវិមជ្ឈការ និងវិសហមជ្ឈការក្នុងការផ្តល់សេវាផ្សព្វផ្សាយតាមរយៈក្រុមអតិថិ ជនផ្សព្វផ្សាយ និងស្ថាប័ននៅថ្នាក់ក្រោមជាតិគ្រប់កម្រិត ដោយអនុលោមតាមរចនាសម្ព័ន្ធរបស់ រាជរដ្ឋាភិបាលកម្ពុជា
- បង្កើតបរិយាកាសលើកទឹកចិត្តឱ្យផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ចូលរួម ក្នុងការ ផ្តល់សេវាផ្សព្វផ្សាយកសិកម្ម
- ជំរុញការផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅកន្លែងដែលពុំមានការចូលរួមពីវិស័យឯកជន អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា
- បង្កើតកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល ផ្សព្វផ្សាយកសិកម្មក្រៅប្រព័ន្ធគ្រឹះស្ថានអប់រំកសិកម្ម
- រៀបចំយន្តការដើម្បីការផ្សារភ្ជាប់ទំនាក់ទំនងរវាងការស្រាវជ្រាវ អប់រំ និងផ្នែកឯកជន តាមវិធីសាស្ត្រ ចម្រុះ ដើម្បីលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព

- កត់ត្រាជាប្រចាំនូវចំណេះដឹងថ្មីៗពីកសិករ សិក្សាស្រាវជ្រាវប្រមូលផ្តុំឯកសារបច្ចេកទេសកសិកម្ម ដោយ សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីរៀបចំចងក្រង បោះពុម្ពអត្ថបទបច្ចេកទេស ទស្សនាវដ្តី ព្រឹត្តិប័ត្រព័ត៌មាន វីដេអូ ខិតប័ណ្ណ.......និងការរៀបចំពិព័រណ៍កសិកម្ម ឬផ្សារណាត់ផលិតផល
- សហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីប្រមូលផ្តុំសម្ភារផ្សព្វផ្សាយ និងប្រភពចំណេះដឹងនានាប្រកបដោយគុណភាព និងបង្កើតបណ្តុំព័ត៌មានឯកសារផ្សព្វផ្សាយកសិកម្ម(Eextension Hub)ដែលអាចសិក្សា និងទាញយកទៅអនុវត្តជាសាធារណៈ
- សហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីធ្វើការវាយតម្លៃ និងធ្វើបច្ចុប្បន្នភាពជាប្រចាំនូវធនធាន និងសម្ភារផ្សព្វផ្សាយ
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើតប្រព័ន្ធកត់ត្រាបញ្ហានានា និងឆ្លើយតបឆាប់រហ័សជុំវិញកិច្ចការបច្ចេកទេសកសិកម្ម និងទីផ្សារកសិផល
- ដឹកនាំ និងសម្របសម្រួលការផ្ទេរបច្ចេកវិទ្យាតាមរយៈការអនុវត្តសាលារៀនស្រែកសិករ ប្រព័ន្ធកសិកម្មធ្វើបង្ហាញ ទិវាបង្ហាញ ទស្សនកិច្ចសិក្សា វេទិកាស្វែងយល់ពីកសិកម្ម
- ចងក្រង និង ធ្វើបច្ចុប្បន្នភាពជាប្រចាំនូវអ្នកដែលពាក់ព័ន្ធ ដែលផ្តល់សេវាកម្មផ្សព្វផ្សាយកសិកម្ម រដ្ឋ ឯកជន និងអង្គការក្រៅរដ្ឋាភិបាល (Extension Pool)
- បង្កើតគោលការណ៍ណែនាំ និងវិធាននៃការអនុវត្តបទដ្ឋានគំរូ ការងារសម្រាប់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាពនៃសេវាផ្សព្វផ្សាយ។ ការធានាគុណភាពក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មរួមមាន៖

  ១-ការកំណត់កម្រិតអប្បបរមានៃគុណវុឌ្ឍដែលអាចទទួលយកបានសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម

  ២-បង្កើតគោលការណ៍ណែនាំសម្រាប់ការអនុវត្តកម្មវិធីផ្សព្វផ្សាយនៅថ្នាក់ស្រុក/ក្រុង

  ៣-ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តសេវាផ្សព្វផ្សាយកសិកម្មប្រកបដោយតម្លាភាព គណនេយ្យភាព និង ប្រសិទ្ធភាពក្នុងការដាក់ពិន្ទុលើគុណភាពសេវាផ្សព្វផ្សាយកសិកម្ម
- សហការជាមួយដៃគូរពាក់ព័ន្ធដើម្បីសិក្សាអំពីប្រសិទ្ធភាព និងសមត្ថភាពរបស់ភ្នាក់ងារផ្សព្វផ្សាយ និងលើក ផែនការអភិវឌ្ឍន៍សមត្ថភាពភ្នាក់ងារផ្សព្វផ្សាយ
- ផ្តល់ការគាំទ្រ និងសហការជាមួយដៃគូរពាក់ព័ន្ធ ដើម្បីបន្តអភិវឌ្ឍន៍សមត្ថភាពមន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម
- ទទួលភារកិច្ចផ្សេងៗទៀតដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រគល់ជូនពាក់ព័ន្ធទៅនឹងការងារផ្សព្វផ្សាយកសិកម្ម។

តួនាទី និងភារកិច្ចសំខាន់ៗរបស់រចនាសម្ព័ន្ធនាយកដ្ឋានផ្សព្វផ្សាយកសិកម្មមាន៖

**១.ប្រធាននាយកដ្ឋាន**

- ផ្តល់ការដឹកនាំ ផ្តល់ដំបូន្មាន និងការណែនាំ ដើម្បីទទួលបានការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយ និងផែនការផ្សព្វផ្សាយកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា
- ណែនាំ និងផ្តល់ទិសដៅផែនការកម្មវិធីផ្សព្វផ្សាយ លទ្ធផលស្នាដៃ និងការវាយតម្លៃ
- ធានានូវប្រសិទ្ធភាព ការគ្រប់គ្រងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្នុងការភ្ជាប់ជាមួយអាទិភាពគោលនយោបាយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- អនុវត្តយុទ្ធសាស្ត្រនៃការអភិវឌ្ឍរចនាសម្ព័ន្ធនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងធនធានមនុស្ស
- ផ្តល់ភាពម៉ឺងម៉ាត់ ណែនាំ ការសង្ខេប និងរាយការណ៍ដើម្បីគាំទ្រប្រសិទ្ធភាពក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងការរួមបញ្ចូលការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយ
- លើកកម្ពស់ចំណេះដឹង អ្នកទទួលផល និងកសិករយ៉ាងសមរម្យ ការចូលរួម និងការសហការក្នុងប្រព័ន្ធការផ្សព្វផ្សាយកសិកម្មនៅប្រទេសកម្ពុជា
- បង្កើត និងថែទាំប្រសិទ្ធភាពសេវាកម្មរដ្ឋបាល និងការគាំទ្រ
- បង្កើតការទំនាក់ទំនងល្អជាមួយម្ចាស់ជំនួយ និងណែនាំការរៀបចំគម្រោង និងអនុវត្តសកម្មភាពផ្សព្វផ្សាយកសិកម្ម
- ទទួលភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ជូន។

**២.អនុប្រធាននាយកដ្ឋាន**

- ជួយប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ដើម្បីគ្រប់គ្រងការអភិវឌ្ឍ និងការអនុវត្ត គោលនយោបាយ
- ជាជំនួយការ ផ្តល់ដំបូន្មាន ណែនាំ និងតម្រង់ទិសដៅ ចាត់ចែង និងរៀបចំដំណើរការ និងមុខងារនាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម
- តំណាងនាយកដ្ឋានផ្សព្វផ្សាយកសិកម្មក្នុងជួររាជរដ្ឋាភិបាលកម្ពុជា
- ការសម្របសម្រួល និងលើកទឹកចិត្តការសហការជាមួយអ្នកពាក់ព័ន្ធ
- ការគ្រប់គ្រងគំនិតផ្តួចផ្តើមគោលនយោបាយពិសេសដែលបានស្នើដោយ ប្រធាននាយកដ្ឋានផ្សព្វផ្សាយ កសិកម្ម
- ទទួលភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ជូន។

តួនាទី ភារកិច្ច និងការទទួលខុសត្រូវសំខាន់ៗរបស់ការិយាល័យ ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រីតាមផ្នែកនីមួយៗមានដូចខាងក្រោម៖

## ៥.៤.១.ការិយាល័យ រដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ(រ.ផ.គ.ស.អ)

- រៀបចំ និងកសាងគោលនយោបាយ សម្រាប់ការងារផ្សព្វផ្សាយកសិកម្ម និងសម្របសម្រួលការងារកសាង ផែនការកម្មវិធី និងគម្រោងការប្រចាំឆ្នាំ
- សិក្សា ត្រួតពិនិត្យ វាយតម្លៃ និងធ្វើអង្កេតរក ឱ្យឃើញឥទ្ធិពលនៃសកម្មភាពផ្សព្វផ្សាយកសិកម្ម ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍប្រភពធនធានការអនុវត្តផែនការគោលនយោបាយ និងកំណត់អាទិភាពវិធីសាស្ត្រមាន ប្រសិទ្ធភាព ក្នុងប្រព័ន្ធផ្សព្វផ្សាយកសិកម្មដោយមានការទទួលយក និងសាយភាយរបស់កសិករ
- សហការ សម្របសម្រួល ទំនាក់ទំនងការងារ ផ្លាស់ប្តូរព័ត៌មាន ជាមួយអង្គការជាតិ អន្តរជាតិ ផ្នែកឯកជន និង ដៃគូអភិវឌ្ឍនានា ដែលមានការងារពាក់ព័ន្ធគ្នាទៅនឹងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម ដើម្បីគ្រប់គ្រង និងធានានូវ ប្រសិទ្ធភាពក្នុងការងារផ្សព្វផ្សាយកសិកម្ម
- ផ្តល់ការណែនាំ និងគាំទ្រសេវាផ្នែកហិរញ្ញវត្ថុដល់ការិយាល័យក្រោមឱវាទនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រាប់បញ្ចូលទាំងការរៀបចំថវិកា ផ្នែកគណនេយ្យ និងផ្តល់របាយការណ៍ទូទាត់តាមកាលកំណត់សម្រាប់ការ អនុវត្តកម្មវិធីផ្សព្វផ្សាយកសិកម្ម។

### ១. ប្រធានការិយាល័យ (រ.ផ.គ.ស.អ)

- ចាត់ចែងរាល់សកម្មភាពការងារក្នុងការិយាល័យ
- ត្រួតពិនិត្យ សម្រេច និងចុះហត្ថលេខា ឬហត្ថលេខាសង្ខេបរាល់ឯកសារផ្សេងៗមុនដាក់ជូនលោកប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

### ២. អនុប្រធានការិយាល័យទទួលបន្ទុករដ្ឋបាល

- សម្របសម្រួលរាល់សកម្មភាពការងាររដ្ឋបាល
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលរាល់សកម្មភាពការងាររដ្ឋបាល និងការងារសង្គម
- ធានាប្រសិទ្ធិភាព សុវត្ថិភាពរដ្ឋបាល និងការងារពិធីការ
- ផ្តល់ការផ្គត់ផ្គង់ និងការដឹកជញ្ជូនដែលគាំទ្រដល់ការងាររបស់នាយកដ្ឋាន
- ការពារសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យក្នុងនាយកដ្ឋាន
- គ្រប់គ្រងសំណុំឯកសារជីវប្រវត្តិស្ថិតិក្របខណ្ឌមន្ត្រីរាជការ
- លើកសំណើសុំការផ្ទេរ ដំឡើងឋានៈ លើកសរសើរ ដាក់វិន័យ ឬកែសម្រួលរចនាសម្ព័ន្ធតាមស្ថានភាពជាក់ស្តែង

- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំស្តីពីសកម្មភាព និងលទ្ធផលការងាររបស់នាយកដ្ឋានដោយធ្វើការបូកសរុបរបាយការណ៍ និងការងារផ្សេងៗពីបណ្តាការិយាល័យចំណុះនាយកដ្ឋាន
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

### ៣. អនុប្រធានការិយាល័យទទួលបន្ទុកផែនការ

- រៀបចំ និងកសាងគោលនយោបាយសម្រាប់ការងារផ្សព្វផ្សាយកសិកម្ម និងសម្របសម្រួលការងារកសាង ផែនការកម្មវិធី និងគម្រោងការប្រចាំឆ្នាំ
- ត្រួតពិនិត្យវាយតម្លៃ សិក្សា និងធ្វើអង្កេតរកឱ្យឃើញឥទ្ធិពលនៃសកម្មភាពផ្សព្វផ្សាយកសិកម្ម ដើម្បីជួយគាំទ្រ ដល់ការអភិវឌ្ឍធនធាន ការអនុវត្តផែនការ គោលនយោបាយ និងកំណត់អាទិភាពវិធីសាស្ត្រមានប្រសិទ្ធភាពនៅ ក្នុងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

### ៤. អនុប្រធានការិយាល័យទទួលបន្ទុកគណនេយ្យ

- រៀបចំឯកសារបៀរវត្ស ប្រាក់កម្រៃ និងរបបឧបត្ថម្ភដោយសហការជាមួយនាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំ និងគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ បញ្ជីសារពើភ័ណ្ឌ ទ្រព្យសម្បត្តិ និងសម្ភារបរិក្ខាររបស់នាយកដ្ឋាន
- គ្រប់គ្រងសន្និធិ និងបែងចែកសម្ភារបរិក្ខារ ប្រេងឥន្ធនៈរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍ទូទាត់ ចំណូលចំណាយក្នុងការអនុវត្តថវិការដ្ឋ និងគម្រោងផ្សេងៗរបស់នាយកដ្ឋាន
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

### ៥. អនុប្រធានការិយាល័យទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិ

- ធ្វើទំនាក់ទំនង សម្របសម្រួល ផ្លាស់ប្តូរព័ត៌មាន ការងារសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ ផ្នែកឯកជន និងដៃគូអភិវឌ្ឍនានាលើការងារផ្សព្វផ្សាយកសិកម្ម
- សម្របសម្រួល រៀបចំបែបបទរដ្ឋបាល និងឯកសារផ្សេងៗសម្រាប់ការបណ្តុះបណ្តាលមន្ត្រី ឬទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រត្តិបត្តិការអន្តរជាតិ បែងចែកជាបួនផ្នែកៈ ផ្នែករដ្ឋបាល ផែនការ ហិរញ្ញវត្ថុ និងសហប្រត្តិបត្តិការអន្តរជាតិ។ តួនាទី និងភារកិច្ចរបស់មន្ត្រីតាមផ្នែកនីមួយៗមានៈ

### ៦. មន្ត្រីទទួលបន្ទុកផ្នែករដ្ឋបាល

- សម្របសម្រួលគ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលរាល់សកម្មភាពការងាររដ្ឋបាល និងការងារសង្គម
- ធានាប្រសិទ្ធភាព សុវត្ថិភាព រដ្ឋបាល និងការងារពិធីការ
- សម្របសម្រួល រៀបចំបែបបទរដ្ឋបាល និងឯកសារផ្សេងៗសម្រាប់ការងារបណ្តុះបណ្តាលទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេសរបស់មន្ត្រី និងកសិករគំរូ
- គ្រប់គ្រង និងថែរក្សាចលនទ្រព្យ និងអចលនទ្រព្យរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

### ៧. មន្ត្រីទទួលបន្ទុកផ្នែកផែនការ

- សហការរៀបចំគោលនយោបាយ ផែនការកម្មវិធី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មប្រាំឆ្នាំ ផែនការរំកិល ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំឱ្យត្រូវទៅតាមស្ថានភាព និងគោលនយោបាយរយៈពេលវែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងវាយតម្លៃសេវាកម្មផ្សព្វផ្សាយដើម្បីគាំទ្រដល់ការអភិវឌ្ឍ ធនធានការអនុវត្តប្រព័ន្ធផ្សព្វផ្សាយកសិកម្ម
- សម្របសម្រួលក្នុងការសិក្សា និងវាយតម្លៃការទទួលយកបាន និងការសាយភាយនៃសេវា និងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម
- ផ្សព្វផ្សាយកសិកម្មដើម្បីគាំទ្រផែនការ ការអនុវត្ត និងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម
- តាមដាន និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធផ្សព្វផ្សាយកសិកម្ម
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

### ៨. មន្ត្រីទទួលបន្ទុកផ្នែកគណនេយ្យ

- ផ្តល់ការណែនាំ និងគាំទ្រសេវាផ្នែកហិរញ្ញវត្ថុដល់ការិយាល័យក្រោមឱវាទនាយកដ្ឋានផ្សព្វផ្សាយកសិកម្មរាប់ បញ្ចូលទាំងការរៀបចំថវិកា គណនេយ្យ និងធ្វើរបាយការណ៍ទូទាត់ថវិកាចំណូលចំណាយក្នុងការអនុវត្តថវិការដ្ឋ និងគម្រោងផ្សេងៗ
- រៀបចំឯកសារបៀវត្ស ប្រាក់កម្រៃ និងរបបរឧបត្ថម្ភ បេសកម្មក្នុង និងក្រៅប្រទេសដោយសហការជាមួយនាយកដ្ឋានជំនាញ
- ផ្តល់ការផ្គត់ផ្គង់សម្ភារ និងការដឹកជញ្ជូនដែលគាំទ្រដល់ប្រសិទ្ធភាពការងាររបស់នាយកដ្ឋាន
- គ្រប់គ្រងសន្និធិ និងបែងចែកសម្ភារ បរិក្ខា ប្រេងឥន្ធនៈ និងមធ្យោបាយធ្វើដំណើរ
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

### ៩. មន្ត្រីទទួលបន្ទុកផ្នែកសហប្រត្តិបត្តិការអន្តរជាតិ

- ធានានូវប្រសិទ្ធភាពនៃទំនាក់ទំនង ការគាំទ្រការអនុវត្តគម្រោងជាមួយអង្គកាជាតិ អន្តរជាតិ ផ្នែកឯកជន និងដៃគូអភិវឌ្ឍន៍នានា

- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

## ៥.៤.២.ការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស

- សហការជាមួយអង្គភាពជំនាញ ស្ថាប័នអប់រំ ផ្នែកឯកជន និងដៃគូអភិវឌ្ឍន៍នានាក្នុងការរៀបចំ និងអនុវត្តគុណវុឌ្ឍិនៃសេវាកម្មបណ្តុះបណ្តាលបច្ចេកទេសផ្សព្វផ្សាយកសិកម្ម ដើម្បីធានាប្រសិទ្ធភាពនៃការសិក្សា និងតម្រូវការអភិវឌ្ឍជំនាញនៃការផ្សព្វផ្សាយ
- សិក្សាពីស្ថានភាពនៃតម្រូវការអាហារូបត្ថម្ភរបស់គ្រួសារកសិករ
- សម្របសម្រួល អនុវត្តកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីផ្សព្វផ្សាយកសិកម្ម អ្នកឯកទេស ទីប្រឹក្សាភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ ភូមិ និងកសិករ
- ចូលរួមតាមដាន ត្រួតពិនិត្យ និងវាយតម្លៃក្របខ័ណ្ឌ ប្រព័ន្ធ និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដោយការសិក្សានិងធ្វើអង្កេតឥទ្ធិពល លទ្ធផលនៃសេវាផ្សព្វផ្សាយកសិកម្មដើម្បីធានាគុណភាព និងប្រសិទ្ធភាពនៃការអនុវត្តសេវាផ្សព្វផ្សាយកសិកម្ម
- រៀបចំបង្កើត និងអនុវត្តគោលការណ៍ណែនាំ ឱ្យក្លាយជាភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ ភូមិ ដល់អ្នកពាក់ព័ន្ធ
- រៀបចំបង្កើត និងអនុវត្តបណ្តាញគោលការណ៍ណែនាំការងារយេនឌ័រ និងការអភិវឌ្ឍក្នុងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម បច្ចេកទេស និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលផ្សព្វផ្សាយកសិកម្មសម្រាប់ក្រៅប្រព័ន្ធគ្រឹះស្ថានអប់រំកសិកម្ម
- រៀបចំវេទិកា សិក្ខាសាលាផ្សព្វផ្សាយកសិកម្ម និងសន្និបាតកសិករដោយមានកិច្ចសម្របសម្រួល និងសហការពីការិយាល័យផ្សព្វផ្សាយកសិកម្មរាជធានី ខេត្ត។

តួនាទី និងភារកិច្ចសំខាន់ៗរបស់៖

### ១. ប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស

- បង្កើតគោលការណ៍ និងផែនការអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីសម្របសម្រួលប្រសិទ្ធភាពការអភិវឌ្ឍជំនាញផ្សព្វផ្សាយ និងសមត្ថភាព
- ផ្តល់ការគាំទ្រ និងជំនួយការដល់ការិយាល័យផ្សព្វផ្សាយកសិកម្ម ដើម្បីអភិវឌ្ឍន៍ប្រសិទ្ធភាពការកសាងសមត្ថភាពការបណ្តុះបណ្តាលការផ្សព្វផ្សាយដល់ខេត្ត
- ផ្តល់ការធានាគុណភាព គោលការណ៍កម្មវិធីសិក្សា និងការអនុម័តរាល់ការផ្តល់កម្មវិធីបណ្តុះបណ្តាលនៅថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- គាំទ្រការចាត់ចែង ជំនាញការបណ្តុះបណ្តាលក្នុងរាល់មុខវិជ្ជាដោយការគ្រប់គ្រង ការអនុញ្ញាតផ្តល់វិញ្ញាបនប័ត្រដោយរាជរដ្ឋាភិបាលដល់ផ្នែកឯកជនជាអ្នកផ្តល់វគ្គបណ្តុះបណ្តាល

- លើកទឹកចិត្ត និងផ្តល់ការអភិវឌ្ឍគោលការណ៍យេនឌ័រ និងកម្មវិធីដោយការពង្រឹងសមត្ថភាព និងប្រសិទ្ធភាព នៃប្រព័ន្ធការផ្សព្វផ្សាយការថែរក្សាប្រព័ន្ធព័ត៌មានសមស្របដោយផ្អែកលើការបណ្តុះបណ្តាល និងតម្រូវការ គាំទ្រផែនការអភិវឌ្ឍន៍ធនធានមនុស្ស ការវាយតម្លៃ និងប្រភពធនធានដែលមាននៅថ្នាក់ជាតិថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការគ្រប់គ្រង និងផ្តល់គុណភាពសេវាកម្មវគ្គបណ្តុះបណ្តាលដល់នាយកដ្ឋានផ្សព្វផ្សាយ និងការិយាល័យ ផ្សព្វផ្សាយរាជធានី ខេត្ត ក្រុង
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

## ២. អនុប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស

- រៀបចំផែនការ ដឹកនាំ និងគ្រប់គ្រងសកម្មភាព ផ្នែកការគ្រប់គ្រងការបណ្តុះបណ្តាល
- គាំទ្រ និងជួយប្រធានការិយាល័យក្នុងការការគ្រប់គ្រងការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស
- ណែនាំការភិវឌ្ឍជំនាញសមត្ថភាព ការបណ្តុះបណ្តាលដែលបានជ្រើសរើសក្នុងផ្នែកការិយាល័យ អភិវឌ្ឍន៍ ធនធានមនុស្ស
- សម្របសម្រួល អភិវឌ្ឍន៍ជំនាញសមត្ថភាពការបណ្តុះបណ្តាលការផ្សព្វផ្សាយក្នុងការិយាល័យផ្សព្វផ្សាយ កសិកម្ម
- អនុវត្តដំណើរការគុណភាពការបណ្តុះបណ្តាលរាប់បញ្ចូលទាំងការផ្តល់គោលការណ៍បណ្តុះបណ្តាល និង វិញ្ញាបនប័ត្រដល់អ្នកផ្តល់វគ្គបណ្តុះបណ្តាល
- សម្របសម្រួល ការទទួលស្គាល់ និងការសហការជាមួយផ្នែកខាងក្រៅ (រដ្ឋាភិបាល ឬផ្នែកឯកជន) ជាអ្នក ផ្តល់ ការបណ្តុះបណ្តាល
- ការសហការ ការវិភាគតម្រូវការវគ្គបណ្តុះបណ្តាល ផ្តល់វគ្គបណ្តុះបណ្តាល និងវាយតម្លៃផលប៉ះពាល់ វគ្គ បណ្តុះបណ្តាល
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

ការិយាល័យ អភិវឌ្ឍន៍ធនធានមនុស្ស បែងចែកជាបីផ្នែក៖ផ្នែកគ្រប់គ្រងការបណ្តុះបណ្តាលផ្នែកយេនឌ័រ និងការអភិវឌ្ឍ ផ្នែកគ្រប់គ្រងប្រព័ន្ធទិន្នន័យអភិវឌ្ឍន៍ធនធានមនុស្ស និងផ្នែករដ្ឋបាល-គណនេយ្យ។ តួនាទី និង ភារកិច្ចជាក់លាក់របស់មន្ត្រីតាមផ្នែកនីមួយៗមាន៖

## ៣.មន្ត្រីទទួលបន្ទុកផ្នែកការគ្រប់គ្រងការបណ្តុះបណ្តាល

- រៀបចំឯកសារ និងអនុវត្តការវាយតម្លៃតម្រូវការវគ្គបណ្តុះបណ្តាលរបស់មន្ត្រីផ្សព្វផ្សាយកសិកម្ម (ការិយាល័យ ផ្សព្វផ្សាយកសិកម្មរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)
- រៀបចំ និងពិនិត្យធ្វើបច្ចុប្បន្នភាព មាតិកាឯកសារបណ្តុះបណ្តាល

- រៀបចំផែនការ គោលការណ៍ និងកម្មវិធីបណ្តុះបណ្តាល ផ្អែកលើលទ្ធផលការវាយតម្លៃតម្រូវការវគ្គបណ្តុះបណ្តាលដល់មន្ត្រីផ្សព្វផ្សាយកសិកម្ម និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ ឃុំ
- សម្របសម្រួល ធ្វើការវាយតម្លៃធនធានមនុស្សក្នុងលទ្ធផលការងារផ្សព្វផ្សាយកសិកម្មក្នុងនាយកដ្ឋានផ្សព្វផ្សាយ កសិកម្ម និងមន្ទីរកសិកម្ម រាជធានី ខេត្ត និងរៀបចំបណ្តុះបណ្តាល
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃគុណភាព និងផលប៉ះពាល់ក្នុងការបណ្តុះបណ្តាលមន្ត្រីផ្សព្វផ្សាយ និងភ្នាក់ងារ ផ្សព្វផ្សាយកសិកម្ម ភូមិ ឃុំ
- សហការជាមួយអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម និងរៀបចំអនុវត្តស្តង់ដារគុណភាពបណ្តុះបណ្តាល របស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
- ផ្តល់ការណែនាំ និងតម្រង់ទិសដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ការិយាល័យផ្សព្វផ្សាយកសិកម្មខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការធ្វើការជាមួយក្រុមកសិករខ្នាតតូចដោយអនុវត្តវិធីសាស្ត្រ ស្ថេរភាព និរន្តរភាព ផលិតភាព សមធម៌ និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

## ៤.មន្ត្រីទទួលបន្ទុកផ្នែកយេនឌ័រ និងការអភិវឌ្ឍន៍

- ចូលរួមរៀបចំបង្កើតគោលនយោបាយ និងគោលការណ៍ណែនាំយេនឌ័រ និងការអភិវឌ្ឍក្នុងវិស័យកសិកម្ម និងការអភិវឌ្ឍផែនការផ្សព្វផ្សាយកសិកម្ម
- សិក្សាពីស្ថានភាព និងតម្រូវការអាហាររូបត្ថម្ភ របស់គ្រួសារកសិករ
- រៀបចំផែនការបញ្ជ្រាបយេនឌ័រ លើកគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទៅតាមផ្នែកនីមួយៗ
- សហការជាមួយក្រុមបណ្តាញយេនឌ័រ អង្គភាពពាក់ព័ន្ធ ក្នុងការអនុវត្តតួនាទីយេនឌ័រដែលបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ បរិស្ថាន និងការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម
- ផ្តល់សេវាកម្មបណ្តុះបណ្តាលផ្នែកយេនឌ័រ និងការអភិវឌ្ឍក្នុងសេវាផ្សព្វផ្សាយកសិកម្ម
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

## ៥.មន្ត្រីទទួលបន្ទុកផ្នែកគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងអភិវឌ្ឍន៍ធនធានមនុស្ស

- រៀបចំបង្កើត វិភាគ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យធនធានមនុស្សដល់ផ្នែកផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- គ្រប់គ្រងទិន្នន័យ និងចងក្រង លទ្ធផលការអភិវឌ្ឍធនធានមនុស្ស ដើម្បីគាំទ្រដល់ប្រសិទ្ធភាពនៃការកសាងផែនការកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស

- គ្រប់គ្រងស្ថិតិទិន្នន័យ និងសម្របសម្រួលវគ្គបណ្តុះបណ្តាលផ្នែកផ្សព្វផ្សាយកសិកម្មដល់មន្ត្រីផ្សព្វផ្សាយ កសិកម្ម និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មថ្នាក់ក្រោមជាតិ (ខេត្ត/រាជធានី/ស្រុក/ខណ្ឌ/ក្រុង និងឃុំ/សង្កាត់ ទូទាំងប្រទេស និងធ្វើរបាយការណ៍បច្ចុប្បន្នភាពរាយការណ៍ជារៀងរាល់ខែ អំពីការប្រែប្រួលទាំងនេះជូន ថ្នាក់ដឹកនាំនាយកដ្ឋាន
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

**៦.មន្ត្រីទទួលបន្ទុកផ្នែករដ្ឋបាល និងគណនេយ្យ**

- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ ការិយាល័យ
- គ្រប់គ្រងស្ថិតិ និងកត់ត្រាលិខិតចេញចូល និងសម្របសម្រួលរាល់សកម្មភាពរដ្ឋបាល និងការងារសង្គម
- រៀបចំកសាងផែនការសកម្មភាព និងរបាយការណ៍ទូទាត់ថវិការប្រចាំឆ្នាំ
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

## ៥.៤.៣.ការិយាល័យការអប់រំ និងផ្សព្វផ្សាយកសិកម្ម

- ផ្តល់ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពសេវាកម្មប្រព័ន្ធផ្សព្វផ្សាយសាធារណៈដល់ការិយាល័យផ្សព្វផ្សាយ កសិកម្មរាជធានីខេត្តឱ្យមានប្រសិទ្ធភាពតាមតម្រូវការរបស់ក្រុមផ្សព្វផ្សាយកសិកម្ម ក្រុង ស្រុក ខណ្ឌ សម្រាប់ការផលិតវីដេអូ ការថតចម្លងដែលមានគុណភាពល្អប្រសើរ
- ការសហការ ផលិត និងចែកចាយ នូវផលិតផលប្រព័ន្ធផ្សព្វផ្សាយសាធារណៈត្រូវទៅនឹងតម្រូវការបន្ទាន់នៃកម្មវិធីផ្សព្វផ្សាយកសិកម្ម
- រៀបចំផលិតឯកសារផ្សព្វផ្សាយតាមប្រព័ន្ធសាធារណៈ និងផ្តល់រាល់ឯកសារស្រាវជ្រាវ និងលទ្ធផលបទពិសោធន៍លើវិស័យកសិកម្មដើម្បីផ្តល់ជូនផ្នែកបោះពុម្ពផ្សាយ
- ដឹកនាំការធ្វើបង្ហាញផ្សព្វផ្សាយអំពីប្រភេទ បរិមាណ និងគុណភាពផលិតផលកសិកម្មដល់សាធារណជន ក្រោមរូបភាពតាំងពិព័រណផ្សារណាត់ផលិតផលកសិកម្មដើម្បីទាក់ទាញ និងបង្កើនទីផ្សារ
- តាមដានការអនុវត្ត និងវាយតម្លៃលទ្ធផលការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្ម សកម្មភាព និងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម និងលើកវិធានការកែលម្អជូនក្រសួង
- ពង្រឹងសមត្ថភាពការិយាល័យផ្សព្វផ្សាយកសិកម្មរាជធានី ខេត្ត ក្រុង ខណ្ឌ ស្រុក និងសេវាកម្មផ្សព្វផ្សាយព័ត៌មាន
- សិក្សាស្រាវជ្រាវប្រមូលផ្តុំឯកសារបច្ចេកទេសកសិកម្មដោយសហការជាមួយអង្គភាពជំនាញនានា អង្គការជាតិ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល

ដៃគូអភិវឌ្ឍន៍ដើម្បីរៀបចំអត្ថបទចងក្រងបោះពុម្ព ទស្សនាវដ្តី កាសែតកសិកម្ម ប្រត្តិបត្តិព័ត៌មាន គំនូររូបភាព កំណាព្យ រឿងនិទានខ្លីៗ

- បោះពុម្ពរាល់ឯកសារស្រាវជ្រាវ និងលទ្ធផលសម្រេចបានពីការធ្វើពិសោធន៍ លើវិស័យកសិកម្មនានា និង រាល់សមិទ្ធផលដែលមានភាពជោគជ័យដើម្បីផ្សព្វផ្សាយជូនប្រជាពលរដ្ឋនៅគ្រប់មជ្ឈដ្ឋាន
- គ្រប់គ្រងបណ្ណាល័យ និងឯកសារបច្ចេកទេសកសិកម្មដែលបានបោះពុម្ពរួច សម្រាប់យកទៅអនុវត្តរបស់ សិស្ស និស្សិត កសិករ និងអតិថិជនទូទាំងប្រទេស។

តួនាទី និងភារកិច្ចសំខាន់ៗរបស់៖

## ១.ប្រធានការិយាល័យអប់រំ និងផ្សព្វផ្សាយកសិកម្ម

- ផលិតខ្នាតគំរូព័ត៌មាន និងគុណភាពគោលការណ៍ដើម្បីសម្របសម្រួលប្រសិទ្ធភាពនៃការផ្ទេរបច្ចេកវិទ្យា និងការកសាងសមត្ថភាពកសិករដោយឆ្លងកាត់ប្រព័ន្ធការផ្សព្វផ្សាយ
- ជួយការិយាល័យផ្សព្វផ្សាយកសិកម្ម ក្នុងការគាំទ្រដល់សកម្មភាពនៅថ្នាក់ស្រុក ដើម្បីបង្កើនប្រសិទ្ធភាពសេវាកម្មព័ត៌មានផ្សព្វផ្សាយសាធារណៈ
- ផ្តល់ការបណ្តុះបណ្តាលអំពីប្រព័ន្ធព័ត៌មានផ្សព្វផ្សាយសាធារណៈ ដល់មន្ត្រីផ្សព្វផ្សាយដោយយោងទៅតាម ការអនុម័តខ្នាតគំរូការបណ្តុះបណ្តាលរបស់ផ្នែកអភិវឌ្ឍនធនធានមនុស្ស
- គ្រប់គ្រង និងផ្តល់គុណភាពនៃសេវាកម្មការផលិតព័ត៌មានផ្សព្វផ្សាយសាធារណៈដល់នាយកដ្ឋានផ្សព្វផ្សាយ កសិកម្ម និងការិយាល័យផ្សព្វផ្សាយកសិកម្ម
- គ្រប់គ្រងការផលិតខ្នាតគំរូនៃការផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ដើម្បីធ្វើឱ្យប្រសើរនូវចំណេះដឹង និងការឆ្លើយ តបទៅនឹងប្រព័ន្ធផ្សព្វផ្សាយក្នុងសហគមន៍កសិកម្ម
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ២.អនុប្រធានការិយាល័យអប់រំ និងផ្សព្វផ្សាយកសិកម្ម

- រៀបចំផែនការ និងការទទួលខុសត្រូវដឹកនាំសកម្មភាពនៃផ្នែកការផ្សព្វផ្សាយឯកសារបច្ចេកទេសនានាតាម វិទ្យុ ទូរទស្សន៍ និងបណ្តាញសង្គម
- ណែនាំ និងបង្កើតការប្រកួតប្រជែង និងប្រសិទ្ធភាពនៃសមត្ថភាពព័ត៌មានផ្សព្វផ្សាយសាធារណៈរាប់បញ្ចូលទាំងជំនាញ និងឧបករណ៍នៅក្នុងផ្នែកនេះ
- សម្របសម្រួលបង្កើតការប្រកួតប្រជែង សមត្ថភាពសេវាកម្មព័ត៌មានផ្សព្វផ្សាយសាធារណៈ ក្នុងការគាំទ្រកម្មវិធីផ្សព្វផ្សាយផ្អែកលើថ្នាក់ស្រុក
- ការអនុវត្តដំណើរការការធានាគុណភាពព័ត៌មានផ្សព្វផ្សាយសាធារណៈ រាប់បញ្ចូលទាំងការផ្តល់នូវខ្នាតគំរូ និងវិញ្ញាបនប័ត្រដល់អ្នកផ្តល់សេវា

- សម្របសម្រួល ការទទួលស្គាល់ និងការសហការជាមួយផ្នែកខាងក្រៅ (រដ្ឋាភិបាល ឬវិស័យឯកជន) អ្នក ផ្តល់សេវាផ្សព្វផ្សាយសាធារណៈ
- ផ្តល់ការផលិត និងសេវាកម្មសេវាផ្សព្វផ្សាយសាធារណៈក្នុងតំបន់ដែលបានជ្រើសរើសក្នុងការឯកភាពជាមួយអតិថិជនជាក់លាក់ និងតម្រូវការជាអាទិភាពនៃប្រព័ន្ធផ្សព្វផ្សាយ
- ផ្តល់ដំបូន្មានដល់អតិថិជនអំពីប្រសិទ្ធភាពនៃការប្រើសេវាកម្មព័ត៌មានផ្សព្វផ្សាយសាធារណៈ
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យអប់រំ និងផ្សព្វផ្សាយកសិកម្មបែងចែកជាបីផ្នែក៖ ផ្នែកផ្សព្វផ្សាយតាមប្រព័ន្ធសាធារណៈ ផ្នែកពិព័រណ៍ ផលិតផលកសិកម្ម ផ្នែកបោះពុម្ព ផ្នែករដ្ឋបាល និងបណ្ណាល័យ។ តួនាទី និងភារកិច្ចជាក់លាក់របស់មន្ត្រីតាមផ្នែកនីមួយៗ មាន៖

### ៣.មន្ត្រីទទួលបន្ទុកផ្នែកផ្សព្វផ្សាយតាមប្រព័ន្ធសាធារណៈ

- ផលិត និងផ្សព្វផ្សាយឯកសារបច្ចេកទេសតាមទូរទស្សន៍ និងវិទ្យុ
- សិក្សា និងវាយតម្លៃពីតម្រូវការប្រព័ន្ធការផ្សព្វផ្សាយព័ត៌មាន បច្ចេកវិទ្យាកសិកម្មរបស់កសិករ និងអ្នកប្រើប្រាស់
- ផ្តល់ជំនួយបច្ចេកទេស និងបណ្តុះបណ្តាលក្នុងការប្រើប្រាស់សេវាកម្មព័ត៌មានការផ្សព្វផ្សាយកសិកម្មឱ្យមានប្រសិទ្ធភាពពីការិយាល័យផ្សព្វផ្សាយកសិកម្មខេត្ត ដល់តម្រូវការរបស់មន្ត្រីការិយាល័យកសិកម្មស្រុកអ្នកផ្សព្វផ្សាយ និងក្រុមកសិករផ្សព្វផ្សាយ
- ការរៀបចំជាប្រព័ន្ធការគ្រប់គ្រងព័ត៌មាន និងការប្រមូលទិន្នន័យ (ប្រព័ន្ធការស្ទាបស្ទង់តម្រូវការកសិករ)
- បណ្តុះបណ្តាលមន្ត្រីកសិកម្មរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពីការប្រើប្រាស់ប្រព័ន្ធទទួលព័ត៌មានជាសម្លេង តាមរយៈទូរស័ព្ទ និងជាសារអេឡិចត្រូនិកសម្រាប់បញ្ជូនព័ត៌មានទាន់ហេតុការណ៍ពាក់ព័ន្ធវិស័យកសិកម្ម និងសម្រាប់សេវាសំណួរ និងចម្លើយ
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

### ៤.មន្ត្រីទទួលបន្ទុកផ្នែកបោះពុម្ព

- រៀបចំបង្កើត ផលិត និងបោះពុម្ព ឯកសារព័ត៌មានបច្ចេកទេសផ្សព្វផ្សាយកសិកម្មជាបទដ្ឋានគំរូជាតិ និងចែកចាយដើម្បីគាំទ្រ និងផ្តល់នូវបច្ចេកវិទ្យាថ្មីដល់កសិករ និងសហគមន៍កសិកម្ម
- រៀបចំចងក្រង ផ្តល់ការបណ្តុះបណ្តាល និងណែនាំដល់មន្ត្រីមន្ទីរកសិកម្មរាជធានីខេត្ត អង្គការមិនមែនរដ្ឋាភិបាល អ្នកផ្តល់សេវាផ្នែកឯកជន អង្គការកសិករដោយអនុវត្តនូវបទដ្ឋានគំរូនៃប្រព័ន្ធការធានានូវគុណភាព សម្ភារការផ្សព្វផ្សាយ ដើម្បីសម្រេចបាននូវគុណភាពនៃការផ្សព្វផ្សាយកសិកម្ម
- បណ្តុះបណ្តាលមន្ត្រីពីបច្ចេកទេសបោះពុម្ព Design មន្ត្រីឯកទេសរៀបចំទំព័រអត្ថបទបច្ចេកទេសកសិកម្ម និងគ្រប់គ្រងថែរក្សាម៉ាស៊ីនបោះពុម្ព

- គ្រប់គ្រងខ្សែចង្វាក់ការផលិត ការបោះពុម្ពផ្សាយ ទិន្នន័យឯកសារបោះពុម្ពនៅក្នុងកុំព្យូទ័រ និងរក្សាទុកក្នុងឃ្លាំង
- ផលិត និងចែកចាយឯកសារផ្សព្វផ្សាយកសិកម្ម (ទស្សនាវដ្ដីកសិកម្ម ព្រឹត្តិបត្រកសិកម្ម booklet, leaflet, manual, buletin, Agnote, poster..)
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

### ៥.មន្ត្រីទទួលបន្ទុកផ្នែករដ្ឋបាល និងបណ្ណាល័យ

- ការគ្រប់គ្រង និងថែទាំបណ្ណាល័យ និងឯកសារបច្ចេកទេសកសិកម្ម
- ប្រមូលឯកសារពីស្ថាប័ននានា ដូចជាៈ សៀវភៅបច្ចេកទេសកសិកម្ម ទស្សនាវដ្ដីកសិកម្ម ការសែតកសិកម្ម វីដេអូកសិកម្ម ខិតប័ណ្ណ កូនសៀវភៅតូចៗ ផ្ទាំងរូបភាពដើម្បីរក្សាទុកបណ្ណាល័យកសិកម្មជាតិ
- រក្សាទុកឯកសារដែលបានផ្សព្វផ្សាយតាមប្រព័ន្ធសាធារណៈដូចជាៈ កាសែតវីដេអូកសិកម្មនាទីកសិកម្មវេទិកា ស្វែងយល់ពីកសិកម្ម នាទីចុះស្រែ និងព័ត៌មានកសិកម្ម ។ល។
- ពង្រឹងសមត្ថភាពមន្ត្រីពីជំនាញបណ្ណារក្ស
- ធានាប្រសិទ្ធភាព សុវត្ថិភាព រដ្ឋបាល និងការចែកចាយឯកសារកសិកម្ម
- សម្របសម្រួលរៀបចំបញ្ជីលេខកូដសៀវភៅបច្ចេកទេសតាមបទដ្ឋានបច្ចេកទេស
- គ្រប់គ្រង និងថែរក្សាចលនទ្រព្យ និងអចលនទ្រព្យរបស់បណ្ណាល័យ
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

### ៦.មន្ត្រីទទួលបន្ទុកផ្នែកពិព័រណ៍ផលិតផលកសិកម្ម

- សហការ ដឹកនាំការធ្វើបង្ហាញផ្សព្វផ្សាយអំពីប្រភេទបរិមាណ និងគុណភាពផលិតផលកសិកម្មដល់សាធារណជន ក្រោមរូបភាពតាំងពិព័រណ៍ផ្សារណាត់ ផលិតផលកសិកម្មដើម្បីទាក់ទាញ និងបង្កើនទីផ្សារផ្សព្វផ្សាយលក់ ផលិតផលពិព័រណ៍។ល។
- រៀបចំសហការ និងទំនាក់ទំនងជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធផ្សេងៗ និងមន្ទីរកសិកម្មរុក្ខាប្រមាញ់ និង នេសាទរាជធានី ខេត្ត និងសហគមន៍អភិវឌ្ឍន៍កសិកម្ម ប្រមូលឯកសារព័ត៌មានបច្ចុប្បន្នភាពទិន្នន័យ រូបថត និងសមិទ្ធផលកសិកម្មសម្រាប់តាំងពិព័រណ៍ផលិតផលកសិកម្ម
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

## ៥.៤.៤.ការិយាល័យប្រព័ន្ធកសិកម្ម និងសេដ្ឋកិច្ចកសិកម្ម

- ផ្ដល់ការគាំទ្របច្ចេកទេស និងការអនុវត្តប្រព័ន្ធផ្សព្វផ្សាយកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រាប់បញ្ចូលទាំង

  ការវិភាគសេដ្ឋកិច្ច ចំណេះដឹង និងបទពិសោធន៍ទៅ និងតម្រូវការអភិវឌ្ឍនៃផ្នែកកសិកម្ម ក្នុងប្រទេសកម្ពុជា

- ផ្តល់ការគាំទ្របច្ចេកទេស ប្រឹក្សា និងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពមន្ទីរកសិកម្ម កសិកម្មស្រុក និងអ្នកផ្សព្វផ្សាយឃុំ ភូមិ
- ផ្តល់យន្តការសម្រាប់ការទំនាក់ទំនងបច្ចេកទេស និងសហការជាមួយអ្នកទទួលផលប្រព័ន្ធកសិកម្មផ្សេងៗ នៅថ្នាក់ជាតិ រាប់បញ្ចូលទាំងនាយកដ្ឋានពាក់ព័ន្ធក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថាប័នស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន ។

តួនាទី និងភារកិច្ចសំខាន់ៗរបស់ការិយាល័យប្រព័ន្ធកសិកម្ម និងសេដ្ឋកិច្ចកសិកម្ម៖

**១.ប្រធានការិយាល័យប្រព័ន្ធកសិកម្ម និងសេដ្ឋកិច្ចកសិកម្ម**

- ដឹកនាំ រៀបចំផែនការគ្រប់គ្រងការងារការិយាល័យប្រព័ន្ធកសិកម្មចម្រុះ និងសេដ្ឋកិច្ចកសិកម្ម
- សម្របសម្រួល និងធានាថាមូលដ្ឋានគ្រឹះបច្ចេកទេសសម្រាប់ការអនុវត្តប្រព័ន្ធការផ្សព្វផ្សាយទទួលបាននូវ សមិទ្ធផលចំណេះដឹង និងបទពិសោធន៍យ៉ាងសមរម្យត្រូវទៅនឹងតម្រូវការផ្នែកការផ្សព្វផ្សាយកសិកម្មនៃប្រទេសកម្ពុជា
- ដឹកនាំ ណែនាំផ្តល់ការគាំទ្របច្ចេកទេស ប្រឹក្សា និងបណ្តុះបណ្តាល (ប្រធានបទ និងគុណភាពដែលបានអនុម័ត និងទទួលស្គាល់ដោយផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីពង្រឹងសមត្ថភាពភ្នាក់ងារផ្សព្វផ្សាយ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការអភិវឌ្ឍផែនការ និងកម្មវិធីផ្សព្វផ្សាយកសិកម្ម
- បង្កើត អនុវត្ត និងគ្រប់គ្រងប្រព័ន្ធព័ត៌មានកសិកម្មនៅថ្នាក់ជាតិ
- សម្របសម្រួលការទំនាក់ទំនងបច្ចេកទេស និងការសហការជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិរាប់បញ្ចូលទាំងនាយកដ្ឋានបច្ចេកទេស នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិទ្យាស្ថានស្រាវជ្រាវ និងផ្នែក ឯកជន
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

**២.អនុប្រធានការិយាល័យ ប្រព័ន្ធកសិកម្ម និងសេដ្ឋកិច្ចកសិកម្ម**

- រៀបចំផែនការ និងការទទួលខុសត្រូវសកម្មភាពផ្នែកប្រព័ន្ធកសិកម្ម
- ដឹកនាំ និងសហការក្នុងការផ្តល់ជំនួយការបច្ចេកទេស និងគាំទ្រដល់ការិយាល័យផ្សព្វផ្សាយកសិកម្មក្នុងគោលបំណងរៀបចំអាទិភាពការស្រាវជ្រាវ និងផ្សព្វផ្សាយប្រព័ន្ធកសិកម្មថ្នាក់ខេត្ត
- ផ្តល់ការគាំទ្របច្ចេកទេស ប្រឹក្សាយោបល់ និងណែនាំដល់មន្ត្រីការិយាល័យផ្សព្វផ្សាយកសិកម្មខេត្ត ក្រុង ស្រុក ខណ្ឌ អំពីប្រព័ន្ធកសិកម្ម និងការអនុវត្តបច្ចេកទេសផ្សព្វផ្សាយកសិកម្ម
- សហការ និងសម្របសម្រួលការបង្កើតប្រព័ន្ធក្សេត្របរិស្ថាន (AEA) និង EPP ទូទាំងរាជធានី ខេត្ត ក្រុង
- បន្តការថែរក្សាចំណេះដឹងនៃការបង្ហាញនូវបច្ចេកវិទ្យាកសិកម្មថ្មីៗ និងនិន្នាការការវាយតម្លៃ និងផ្តល់ការណែនាំអំពីការអនុវត្តកសិកម្មកម្ពុជា

- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

ការិយាល័យប្រព័ន្ធកសិកម្ម និងសេដ្ឋកិច្ចកសិកម្មបែងចែកជាបួនផ្នែក៖ ផ្នែកប្រព័ន្ធកសិកម្ម ផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មានកសិកម្ម ផ្នែកសេដ្ឋកិច្ចកសិកម្ម និងផ្នែករដ្ឋបាល។

តួនាទី និងភារកិច្ចជាក់លាក់របស់មន្ត្រីតាមផ្នែកនីមួយៗមាន៖

### ៣.មន្ត្រីទទួលបន្ទុកផ្នែកប្រព័ន្ធកសិកម្ម

- ចេញគោលការណ៍ណែនាំ និងធ្វើការបណ្តុះបណ្តាលទ្រឹស្តីបច្ចេកទេសលើការវិភាគប្រព័ន្ធកសិកម្ម
- បណ្តុះបណ្តាល និងសិក្សាវាយតម្លៃប្រព័ន្ធក្សេត្រ-បរិស្ថាន (Agro-Ecosystem Analysis) ដើម្បីគាំទ្រក្នុង ការរៀបចំផែនការវិនិយោគឃុំ/សង្កាត់
- ការបង្កើតបទដ្ឋានអនុវត្តបច្ចេកវិទ្យាកសិកម្ម (TIP) និងបង្កុំបច្ចេកវិជ្ជាកសិកម្មដោយមានការចូលរួមជាមួយ អង្គភាពជំនាញ
- បណ្តុះបណ្តាលកសិករលើការអនុវត្តប្រព័ន្ធកសិកម្មចម្រុះ
- សហការជាមួយការិយាល័យផ្សព្វផ្សាយកសិកម្មរាជធានី ខេត្ត ក្នុងការប្រើប្រាស់លទ្ធផលវិភាគប្រព័ន្ធក្សេត្របរិស្ថានដើម្បីរៀបចំផែនការវិនិយោគ និងផែនការអភិវឌ្ឍកសិកម្មនៅឃុំ/សង្កាត់ប្រកបដោយប្រសិទ្ធភាព
- ផលិតកម្មស្បៀងជាលក្ខណៈគ្រួសារ តាមរយៈការធ្វើបង្ហាញ និងកសិដ្ឋានគំរូ(Model farming) ពីការអនុវត្តកសិកម្មធន់នឹងការប្រែប្រួលអាកាសធាតុដែលរួមមាន៖ ការធ្វើប្រពលវប្បកម្មដំណាំ និងការចិញ្ចឹមសត្វ និងវារីវប្បកម្មជាលក្ខណៈគ្រួសារ និងសួនបន្លែគ្រួសារ។ល។
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

### ៤.មន្ត្រីទទួលបន្ទុកផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មានកសិកម្ម (FSMIS)

- បង្កើត អនុវត្ត គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានកសិកម្មដោយបញ្ចូលឯកសាររបាយការណ៍ការ វិភាគប្រព័ន្ធក្សេត្របរិស្ថាន និងទិន្នន័យដែលពាក់ព័ន្ធ និងបទដ្ឋានអនុវត្តបច្ចេកវិទ្យាដែលសមស្របទៅនឹង ភូមិសាស្ត្រជាក់ស្តែងនីមួយៗ
- បណ្តុះបណ្តាលពីការប្រើប្រាស់ និងបញ្ចូលទិន្នន័យដល់មន្ត្រីផ្សព្វផ្សាយកសិកម្មរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ
- សម្របសម្រួលដល់ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព នូវទិន្នន័យគ្រឹះប្រព័ន្ធកសិកម្មសម្រាប់ធ្វើផែនការផ្សព្វផ្សាយកសិកម្ម
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

### ៥.មន្ត្រីទទួលបន្ទុកផ្នែកសេដ្ឋកិច្ចកសិកម្ម

- សម្របសម្រួល និងបណ្តុះបណ្តាលអំពីធ្វើផែនការធុរកិច្ចខ្នាតតូចដល់គ្រួសារកសិករ

- សិក្សាសក្តានុពលសេដ្ឋកិច្ចតាមមុខដំណាំធៀបនឹងផ្ទៃដី ពេលវេលា និងខ្សែសង្វាក់ផលិតកម្មកសិកម្មរបស់ប្រជាកសិករតាមភូមិសាស្ត្រជាក់ស្តែង
- សិក្សាស្រាវជ្រាវពីតម្រូវការ និងស្ថានភាពទីផ្សារ និងការផ្សព្វផ្សាយព័ត៌មានដល់ភូមិ ឃុំ សង្កាត់
- សិក្សាពីប្រសិទ្ធភាពសេដ្ឋកិច្ចនៃបច្ចេកវិទ្យាព័ត៌មានកសិកម្មនៅមូលដ្ឋានជាក់ស្តែងនីមួយៗ
- សិក្សា វិភាគ និងវាយតម្លៃស្ថានភាពសេដ្ឋកិច្ចកសិកម្មរបស់គ្រួសារកសិករ (Farm Economic Analysis)
- ផ្តល់ការ ពិភាក្សា និងផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តប្រព័ន្ធកសិកម្មចម្រុះដល់អ្នកពាក់ព័ន្ធផ្សេងទៀតក្នុង ផ្នែកផ្សព្វផ្សាយកសិកម្ម
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

**៦.មន្ត្រីទទួលបន្ទុកផ្នែករដ្ឋបាល**

- រៀបចំកាលវិភាគចុះបេសកកម្មប្រចាំខែរបស់មន្ត្រីក្នុងការិយាល័យ និងធ្វើរបាយការណ៍ទូទាត់ថវិកាប្រចាំខែ ត្រីមាស ឆមាស និង ឆ្នាំរបស់អង្គភាពការងារទៅតាមផែនការប្រចាំឆ្នាំរបស់ការិយាល័យដែលបានកំណត់ឱ្យ អនុវត្តដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
- ទទួល និងចែកចាយលិខិតស្នាមនានាដល់មន្ត្រីពាក់ព័ន្ធ និងទិន្នន័យរដ្ឋបាលក្នុងការិយាល័យ
- គ្រប់គ្រងស្ថិតិ កត់ត្រាលិខិតចេញចូល និងសម្របសម្រួលរាល់សកម្មភាពរដ្ឋបាល និងការងារសង្គមរបស់ការិយាល័យ
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំការិយាល័យប្រគល់ជូន ។

## ៥.៤.៥.មជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្ម តាស្លាង (ខេត្តស្វាយរៀង)

មជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្មតាស្លាងមានតួនាទី និងភារកិច្ចសំខាន់ៗមាន៖

- កសាងគម្រោងផែនការសកម្មភាព ក្នុងការអភិវឌ្ឍដំណាំស្រូវ ដំណាំបន្លែ ដំណាំហូបផ្លែ ការចិញ្ចឹមត្រីការ ចិញ្ចឹមសត្វ និងអភិវឌ្ឍន៍ប្រព័ន្ធកសិកម្មចម្រុះ
- សហការសម្របសម្រួលវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំគ្រប់ប្រភេទ និងការដាំដុះតាមលក្ខណៈវិទ្យាសាស្ត្រ ឆ្លើយតបតាមតម្រូវការទីផ្សារក្នុង និងក្រៅស្រុក
- សហការ និងបណ្តុះបណ្តាលកសិករពីតួនាទីយេនឌ័រក្នុងសកម្មភាពកសិកម្ម និងបម្រែបម្រួលអាកាសធាតុ តួនាទីយេនឌ័រ និងការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម
- ផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងបទពិសោធន៍ដែលរកឃើញថ្មីជូនដល់កសិករ អង្គការកសិករ សហគមន៍អភិវឌ្ឍន៍កសិកម្មតាមរយៈការធ្វើបង្ហាញ រៀបចំទិវាស្រែ និងធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍រវាងកសិករ និងកសិករគំរូរវាងអង្គការដៃគូអភិវឌ្ឍន៍នានាក្នុង និងក្រៅតំបន់គោលដៅ
- គ្រប់គ្រង និងថែរក្សា ចលនទ្រព្យ និងអចលនទ្រព្យរបស់មជ្ឈមណ្ឌល

- សហការជាមួយអង្គភាពជំនាញនានាក្នុងការសាកល្បង និងបន្សាំដំណាំ និងការចិញ្ចឹមសត្វគ្រប់ប្រភេទ
- ចូលរួមតាមដាន និងវាយតម្លៃការអនុវត្តសកម្មភាពផ្សព្វផ្សាយកសិកម្មនៅក្នុងមូលដ្ឋាន និងកែលម្អនូវប្រសិទ្ធភាព នៃការអនុវត្ត
- រៀបចំរបាយការណ៍បច្ចេកទេសលើលទ្ធផល និងប្រសិទ្ធភាពការអនុវត្ត ផែនការសកម្មភាពផ្សព្វផ្សាយកសិកម្មប្រចាំឆ្នាំ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

## ៥.៤.៦.មជ្ឈមណ្ឌលបណ្តុះបណ្តាលកសិករគំរូតំបន់អភិវឌ្ឍន៍ខាងលិច រាជធានីភ្នំពេញ (ខេត្តកំពង់ស្ពឺ)

មជ្ឈមណ្ឌលបណ្តុះបណ្តាលកសិករគំរូតំបន់អភិវឌ្ឍន៍ខាងលិចរាជធានីភ្នំពេញ (ខេត្តកំពង់ស្ពឺ) មានតួនាទី និង ភារកិច្ចសំខាន់ៗមាន៖

- កសាងគម្រោងផែនការ និងសកម្មភាពជម្រុញការអនុវត្តកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស ផ្នែកផ្សព្វផ្សាយកសិកម្មថ្នាក់ខេត្ត រាជធានី ក្រុង ស្រុក ខណ្ឌ និងប្រជាកសិករ
- សហការ សម្របសម្រួល ការបណ្តុះបណ្តាល បំពាក់បំប៉នមន្ត្រីផ្សព្វផ្សាយ អង្គការកសិករ សហគមន៍អភិវឌ្ឍន៍ កសិកម្ម ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ និងកសិករគំរូ
- សហការចូលរួមសម្របសម្រួលការស្រាវជ្រាវ ពិសោធន៍បន្សាំដំណាំគ្រប់ប្រភេទ ការចិញ្ចឹមសត្វ ការចិញ្ចឹម ត្រី ផ្លាស់ប្តូរបទពិសោធន៍រវាងកសិករនឹងកសិករគំរូរវាងអង្គការកសិករ សហគមន៍អភិវឌ្ឍន៍កសិកម្ម
- សហការ ការបណ្តុះបណ្តាល កសិករពីតួនាទីយេនឌ័រក្នុងសកម្មភាពកសិកម្ម និងការប្រែប្រួលអាកាសធាតុ តួនាទីយេនឌ័រ និងការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម
- សហការជាមួយការិយាល័យកសិកម្មស្រុក និងអាជ្ញាធរមូលដ្ឋាន រៀបចំវេទិការសាធារណៈអំពីការលើកកម្ពស់តួនាទីភាព ជាអ្នកដឹកនាំក្នុងសហគមន៍សម្រាប់និរន្តរភាពនៃការអភិវឌ្ឍកសិកម្ម
- គ្រប់គ្រង ថែរក្សា ចលនទ្រព្យ និងអចលនទ្រព្យរបស់មជ្ឈមណ្ឌល
- រៀបចំរបាយការណ៍បច្ចេកទេសលើលទ្ធផល និងប្រសិទ្ធភាពការអនុវត្តផែនការសកម្មភាពផ្សព្វផ្សាយកសិកម្ម ប្រចាំឆ្នាំនៃលទ្ធផលការងារដែលទទួលបាន
- ចូលរួមតាមដាន និងវាយតម្លៃការអនុវត្តសកម្មភាពផ្សព្វផ្សាយកសិកម្មនៅក្នុងមូលដ្ឋាន និងកែលម្អនូវប្រសិទ្ធភាពនៃការអនុវត្ត
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

## ៥.៥.មុខងារគាំទ្រ និងសម្របសម្រួលរបស់អង្គភាពពាក់ព័ន្ធក្នុង ការងារផ្សព្វផ្សាយកសិកម្ម

ការចូលរួមរបស់អង្គភាពពាក់ព័ន្ធក្នុងការផ្សព្វផ្សាយកសិកម្មផ្តោតលើការអភិវឌ្ឍបច្ចេកវិទ្យា បច្ចេទេស និងការអនុវត្តកសិកម្មថ្មីៗ សម្រាប់ផ្សព្វផ្សាយដល់កសិករ និងសហគមន៍កសិករ។ ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាថ្មីៗ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់ គឺជាធាតុដ៏សំខាន់ដើម្បីធានាបាននូវការផ្តល់សេវាផ្សព្វផ្សាយដ៏ល្អប្រសើរ។

អង្គភាពជំនាញពាក់ព័ន្ធចូលរួមមាន៖

- គណៈកម្មាធិការប្រឹក្សាការផ្សព្វផ្សាយកសិកម្ម ដែលមានតួនាទីពេញលេញគាំទ្រដល់នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិ ដើម្បីធ្វើការសម្របសម្រួល តម្រង់ទិស និងត្រួតពិនិត្យ សំដៅធ្វើឱ្យប្រសើរឡើងនូវការផ្សារ

  ភ្ជាប់ទំនាក់ទំនងរវាងស្ថាប័នស្រាវជ្រាវ អប់រំ និងបណ្តុះបណ្តាល
- ផ្តល់ និងគៀរគរធនធាន និងតម្រូវឱ្យគ្រឹះស្ថានស្រាវជ្រាវ និងអប់រំកសិកម្មធ្វើការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងចំណេះដឹង ដើម្បីតម្រូវតាមលក្ខខណ្ឌតំបន់ជាក់លាក់តាមតម្រូវការ និងតម្រូវការទីផ្សារសម្រាប់ជួយបម្រើដល់ កសិករ និងសហគមកសិករ
- រៀបចំវេទិកា ដើម្បីចែករំលែកនូវបច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗ និងការអនុវត្តល្អៗរវាងអ្នកពាក់ព័ន្ធនានា។
- បង្កើតនូវប្រព័ន្ធត្រួតពិនិត្យវាយតម្លៃ និងសិក្សាបទពិសោធន៍ច្បាស់លាស់ដើម្បីតាមដានលើការសម្រេច បាននូវគោលបំណង និងគោលដៅនៃសេវាផ្សព្វផ្សាយកសិកម្ម។

ក ារងារផ្សព្វផ្សាយកសិកម្មក៏មានការចូលរួមពីវិទ្យាស្ថានស្រាវជ្រាវ សាកលវិទ្យាល័យ និងសាលាកសិកម្ម អង្គភាពជំនាញក្រោមឱវាទក្រសួង សង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានាត្រូវចាត់វិធានការណ៍ដូចតទៅ៖

- ចូលរួមជាអនុគណៈកម្មាធិការបច្ចេកទេសកសិកម្មជាតិ ត្រូវរៀបចំវេទិកាប្រចាំឆ្នាំសម្រាប់អ្នកស្រាវជ្រាវកសិកម្ម ពាក់ព័ន្ធដើម្បីពង្រឹងការសម្របសម្រួលសកម្មភាពស្រាវជ្រាវដោយស្ថាប័ន និងអង្គភាពនានា
- បង្កើតអាទិភាពស្រាវជ្រាវកសិកម្ម និងយន្តការផ្តល់មូលនិធិដោយមាននិរន្តរភាព ដើម្បីបង្កើនកម្រិតឱកាសសម្រាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យា ការបង្កើតបង្កំបច្ចេកទេស និងការផ្សព្វផ្សាយ
- ការអភិវឌ្ឍបច្ចេកវិទ្យាត្រូវតម្រង់ទិសទៅរកទីផ្សារ និងតម្រូវការជាក់ស្តែង
- អង្គភាពជំនាញពាក់ព័ន្ធ ស្ថាប័នស្រាវជ្រាវ និងស្ថាប័នបណ្តុះបណ្តាលត្រូវបង្កើតទំនាក់នងផ្សារភ្ជាប់រវាងការ ស្រាវជ្រាវ-ផ្សព្វផ្សាយ-អប់រំជាមួយនឹងអង្គការកសិករ
- លើកកម្ពស់ការស្រាវជ្រាវ និងធ្វើទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ជាមួយស្ថាប័នអន្តរជាតិនានា។

ការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាកសិកម្មត្រូវផ្តោតលើ៖

- ដំណាំស្រូវ ដំណាំរួមផ្សំ សាកវប្បកម្ម (ឈើហូបផ្លែ បន្លែ និងរុក្ខជាតិលម្អ) និងដំណាំឧស្សាហកម្ម ។
- ផលិតកម្មកៅស៊ូ
- ផលិតកម្ម និងបសុព្យាបាល
- វារីវប្បកម្ម និងជលផល
- រុក្ខវប្បកម្ម
- ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- ទីផ្សារកសិកម្ម និងការរកឱកាសទីផ្សារថ្មីៗ
- ការទុកដាក់ និងការកែច្នៃក្រោយប្រមូលផល
- គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម និងសុវត្ថិភាពស្បៀងអាហារ។

បច្ចេកវិទ្យា ការអនុវត្ត និងសារបច្ចេកទេសកសិកម្មថ្មីៗនានាត្រូវផ្តោតលើ៖

- ការស្រាវជ្រាវបច្ចេកវិទ្យាផ្អែកតាមទីកន្លែងជាក់លាក់ សំដៅបង្កើនផលិតកម្ម និងប្រសិទ្ធផល
- ខ្សែសង្វាក់តម្លៃផលិតកម្មទាំងមូលដែលរួមមានផលិតកម្ម ការបង្កើតតម្លៃបន្ថែម ការទុកដាក់ ការរកទីផ្សារ និងការប្រើប្រាស់
- ការប្រែក្លាយកសិកម្មពីកសិកម្មបង្គ្រប់តម្រូវការក្នុងគ្រួសារទៅជាកសិកម្មសម្រាប់ធ្វើជំនួញរកចំណេញ
- ស្តង់ដារគុណភាពនៃធាតុចូលកសិកម្ម និងផលិតផល វិធានការសុវត្ថិភាពស្បៀងអាហារ និងការកំណត់ថ្លៃសមស្របដើម្បីទទួលបានផលិតផលដែលមានគុណភាព
- ការបង្កើតបច្ចេកវិទ្យាដែលត្រូវផ្ទេរឱ្យកសិករត្រូវស្របនឹងបរិបទសង្គម ផ្តល់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងមិនប៉ះពាល់បរិស្ថាន។

## ៥.៥.១.តួនាទី និងភារកិច្ចគ្រឹះស្ថានអប់រំ និងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

គ្រឹះស្ថានអប់រំកសិកម្ម និងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាមាន៖ សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប សាលាជាតិកសិកម្មកំពង់ចាម វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា។ល។ មានតួនាទីភារកិច្ច និងការទទួលខុសត្រូវក្នុងការផ្សព្វផ្សាយកសិកម្មដូចខាងក្រោម៖

### ក.គ្រឹះស្ថានអប់រំ

- សិក្សាប៉ាន់ប្រមាណពីតម្រូវការធនធានមនុស្សតម្រូវតាមទីផ្សារការងាររបស់ស្ថាប័នរដ្ឋ និងឯកជន និងរៀបចំ ផែនការធនធានមនុស្សពីជំនាញកសិកម្ម និងពាក់ព័ន្ធដោយបញ្ចូលនូវវិធីសាស្រ្តផ្សព្វផ្សាយកសិកម្មឱ្យស្រប ទៅតាមបរិបទ និងតម្រូវការទីផ្សារ

- បណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យកសិកម្ម កម្រិតសញ្ញាប័ត្រ មធ្យម ឧត្តម និងក្រោយឧត្តមប្រកបដោយ គុណភាព ទាំងទ្រឹស្តី និងការអនុវត្តដោយផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយសហគមន៍ និងសាកលវិទ្យាល័យ
- បង្កើតកម្មវិធីសិក្សាសម្រាប់បណ្តុះបណ្តាលជំនាញផ្សព្វផ្សាយកសិកម្មទៅក្នុងកម្មវិធីសិក្សាកម្រិតសញ្ញាប័ត្រ និង វគ្គបណ្តុះបណ្តាលខ្លី
- ផ្តល់វគ្គបណ្តុះបណ្តាល និងវគ្គបំប៉នបន្ថែមនូវបច្ចេកវិទ្យាកសិកម្មថ្មីៗដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងអង្គភាព ពាក់ព័ន្ធតាមការចាំបាច់
- ធ្វើការសិក្សាស្រាវជ្រាវជាប្រចាំ ដើម្បីបង្កើតបង្កំបច្ចេកវិទ្យា បច្ចេកទេស និងការអនុវត្តកសិកម្មល្អបែបថ្មីៗ ទំនើប
- គ្រឹះស្ថានត្រូវធ្វើជាទីកន្លែងនៃប្រភពធនធានសម្រាប់សិក្សាកសិកម្មគ្រប់កម្រិត និងគ្រប់រូបភាពនៃវិធីសាស្ត្រ ផ្សព្វផ្សាយកសិកម្ម
- សហការជាមួយអង្គភាពជំនាញ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម មន្ទីរកសិកម្មខេត្ត ឬស្ថាប័នពាក់ព័ន្ធ(ជំនាញបណ្តុះបណ្តាលស្រាវជ្រាវ) ដើម្បីទទួលបាននូវបញ្ហានានា ដែលបាននឹងកំពុងជួបប្រទះ
- សហការជាមួយស្ថាបន័ពាក់ព័ន្ធ ដើម្បីស្វែងយល់អំពីបញ្ហាបច្ចេកទេស និងការប្រឈមនានាដើម្បីធ្វើការសិក្សាស្រាវជ្រាវរកដំណោះស្រាយ និងបង្កើតបង្កំបច្ចេកវិទ្យា បច្ចេកទេសបែបថ្មីៗប្រកបដោយភាពឆ្នៃប្រឌិត ដើម្បីផ្សព្វផ្សាយ និងផ្តល់ជាធាតុចូលសម្រាប់អ្នករៀបចំគោលនយោបាយ
- ចងក្រងឯកសារ និងសម្ភារផ្សព្វផ្សាយដើម្បីធ្វើការផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ
- ធ្វើការផ្សព្វផ្សាយតាមបែបពហុនិយមទៅដល់អ្នកពាក់ព័ន្ធ និងកសិករ។

## ខ.វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- សិក្សាវាយតម្លៃពីតម្រូវការបច្ចេកវិទ្យាថ្មី និងការអនុវត្តបច្ចេកទេសកសិកម្មនានាទៅតាមតម្រូវការទីផ្សារ
- ស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យា បច្ចេកទេស និងការអនុវត្តកសិកម្មល្អបែបថ្មីៗ និងទំនើបសម្រាប់ប្រើ ប្រាស់ក្នុងផលិតកម្មកសិកម្ម
- បង្កើតបង្កំបច្ចេកវិទ្យា បច្ចេកទេស និងការអនុវត្តកសិកម្មល្អ បែបថ្មីៗ និងទំនើបសហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្នុងការផ្តល់ព័ត៌មានស្តីពីការផ្សព្វផ្សាយនូវបច្ចេកវិទ្យាថ្មី ដើម្បីធានាថាព័ត៌មានដែល ផ្សព្វផ្សាយទៅកសិករមានគុណភាព និងប្រសិទ្ធភាព
- សិក្សាវាយតម្លៃពីប្រសិទ្ធភាពនៃការទទួលយក និងប្រើប្រាស់នូវបច្ចេកវិទ្យាថ្មីរបស់អ្នកប្រើប្រាស់
- ចែករំលែកនូវរាល់លទ្ធផលស្រាវជ្រាវដល់អង្គភាពផ្សព្វផ្សាយកសិកម្ម និងវិទ្យាស្ថានអប់រំកសិកម្មឱ្យបាន ឆាប់តាមដែលអាចធ្វើទៅបានដើម្បីការសាយភាយបានឆាប់រហ័សដល់កសិករឬផលិតករ
- បណ្តុះបណ្តាលគ្រូជំនាញបង្គោលអំពីបច្ចេកវិទ្យាថ្មីៗ។

### ៥.៥.២.តួនាទី និងភារកិច្ចអង្គភាពជំនាញពាក់ព័ន្ធ

អង្គភាពជំនាញពាក់ព័ន្ធនានានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមាននាយកដ្ឋានជំនាញនានានៃអគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកដ្ឋានកៅស៊ូ រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល និងអគ្គនាយកដ្ឋានផលិតកម្មសត្វ និងសុខភាពសត្វ និងអង្គភាពពាក់ព័ន្ធនានា។ អង្គភាពជំនាញទាំងនេះ មានតួនាទីភារកិច្ច និងការទទួលខុសត្រូវតាមជំនាញក្នុងការងារផ្សព្វផ្សាយកសិកម្ម។

អង្គភាពជំនាញធ្វើការសហការជាមួយគ្រឹះស្ថានបណ្តុះបណ្តាល និង ស្ថាប័នស្រាវជ្រាវ អង្គភាពពាក់ពន្ធ័ ដើម្បីៈ

- រៀបចំលិខិតបទដ្ឋានគតិយុត្តិ និងគោលការណ៍ណែនាំដែលពាក់ព័ន្ធនឹងជំនាញ និងផ្សព្វផ្សាយដល់កសិករ និងអ្នកប្រើប្រាស់ និងសហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មតាមភាពចាំបាច់
- ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យា បច្ចេកទេស និងការអនុវត្តកសិកម្មល្អ បែបថ្មីៗ និងទំនើបសម្រាប់ ប្រើប្រាស់ក្នុងផលិតកម្មកសិកម្ម
- បង្កើតបង្គុំបច្ចេកវិទ្យា និងបទដ្ឋានគំរូ និងបច្ចេកទេសនានាដែលពាក់ព័ន្ធនឹងជំនាញដើម្បីធ្វើការផ្សព្វផ្សាយដល់កសិករ និងអ្នកពាក់ព័ន្ធ
- រៀបចំ និងចងក្រងឯកសារ និងសម្ភារផ្សព្វផ្សាយ និងធ្វើការផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ
- បណ្តុះបណ្តាលជំនាញបច្ចេកទេសដល់អ្នកពាក់ព័ន្ធ
- សិក្សាវាយតម្លៃពីការទទួលយកនូវបច្ចេកវិទ្យាថ្មី ការប្រើប្រាស់បច្ចេកវិទ្យា បច្ចេកទេស និងការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់តាមបែបទំនើបនីយកម្មរបស់កសិករ និងអ្នកប្រើប្រាស់ ។

### ៥.៥.៣.តួនាទី និងភារកិច្ចអង្គភាពគាំទ្រ និងសម្របសម្រួល

អង្គភាពគាំទ្រ និងសម្របសម្រួលមានៈ នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស នាយកដ្ឋានផែនការស្ថិតិ នាយកដ្ឋាននីតិកម្មកសិកម្ម នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ...។ល។ មានតួនាទីភារកិច្ច និងចូលរួម ទទួលខុសត្រូវក្នុងការងារផ្សព្វផ្សាយកសិកម្មរួមមានៈ

- សហការ រៀបចំគោលនយោបាយផែនការយុទ្ធសាស្រ្តអភិវឌ្ឍវិស័យកសិកម្ម ផែនការយុទ្ធសាស្រ្តថវិកា ផែនការថវិកាតាមកម្មវិធី និងគម្រោងវិនិយោគពាក់ព័ន្ធ និងកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សក្នុងការងារផ្សព្វផ្សាយកសិកម្ម
- សហការ សម្របសម្រួល រាល់លិខិតបទដ្ឋានគតិយុត្តិ គោលការណ៍ណែនាំ និងវិធានការអនុវត្តបទដ្ឋានគតិយុត្តិនានាដល់អ្នកពាក់ព័ន្ធ
- សហការក្នុងការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយក្នុងការងារផ្សព្វផ្សាយកសិកម្ម ប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ៥.៦.តួនាទី និងភារកិច្ចរបស់អង្គភាពនៅថ្នាក់ក្រោមជាតិ

នៅថ្នាក់ក្រោមជាតិ ការគាំទ្រ សម្របសម្រួល និងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មគឺប្រតិបត្តិដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត និងការិយាល័យកសិកម្មស្រុក ក្រុង ខណ្ឌ។ ដើម្បីដឹកនាំ សម្របសម្រួល គាំទ្រ និង ប្រតិបត្តិការផ្សព្វផ្សាយកសិកម្មឱ្យមានគុណភាព និងប្រសិទ្ធភាព មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តត្រូវរៀបចំក្រុមការងារផ្សព្វផ្សាយបច្ចេកទេសថ្នាក់រាជធានី ខេត្ត និងក្រុមគាំទ្របច្ចេកទេសកសិកម្មថ្នាក់ស្រុក ក្រុង ខណ្ឌ។

### ៥.៦.១.តួនាទី និងភារកិច្ចរបស់ក្រុមការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មរាជធានី-ខេត្ត

ក្រុមការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មខេត្តមានតួនាទី និងភារកិច្ចដឹកនាំ គាំទ្រ និងសម្របសម្រួលសកម្មភាព និងកម្មវិធីផ្សព្វផ្សាយកសិកម្មជាមួយអង្គភាព និងភ្នាក់ងារផ្តល់សេវាផ្សព្វផ្សាយពាក់ព័ន្ធនៅក្នុងខេត្ត បង្កើតឱ្យមានទំនាក់ ទំនងការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្ម ការត្រួតពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីផ្សព្វផ្សាយកសិកម្ម និងការបណ្តុះ បណ្តាលបច្ចេកទេសមន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត ស្រុក និងឃុំ។ ក្រុមការងារផ្សព្វផ្សាយបច្ចេកទេស កសិកម្មខេត្តដឹកនាំដោយគណៈអភិបាលរាជធានីខេត្ត (អភិបាលរង) ជាប្រធាន និងមានសមាសភាពប្រធានមន្ទីរកសិកម្ម រាជធានី ខេត្តជាអនុប្រធាន ព្រមទាំងសមាជិកមកពីតំណាងមន្ទីរកិច្ចការនារីខេត្ត ការិយាល័យជំនាញរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត តំណាងសហគមន៍កសិកម្ម វិស័យឯកជន និងប្រធានការិយាល័យផ្សព្វផ្សាយកសិកម្ម រាជធានី ខេត្តជាលេខាអចិន្ត្រៃយ៍។ ក្រុមការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មរាជធានី ខេត្តមានតួនាទី និងភារកិច្ចៈ

- សម្របសម្រួលការផ្សារភ្ជាប់ការស្រាវជ្រាវ និងការផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត
- គាំទ្រ និងសម្របសម្រួល កម្មវិធីគម្រោង និងសកម្មភាពផ្សព្វផ្សាយកសិកម្មនានានៅខេត្ត និងស្រុក
- គាំទ្រ និងសម្របសម្រួលការផ្តល់សេវាផ្សព្វផ្សាយកសិកម្មតាមបែបពហុនិយម ដោយគ្រប់ភាគពាក់ព័ន្ធមានផ្នែកសាធារណៈផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហគមន៍មូលដ្ឋាននានា
- គាំទ្របច្ចេកទេសដល់មន្ត្រីផ្សព្វផ្សាយកសិកម្មស្រុក និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅមូលដ្ឋាន
- គៀងគរធនធាន និងថវិកាគាំទ្រដល់កម្មវិធីគម្រោង និងសកម្មភាពផ្សព្វផ្សាយកសិកម្មនានានៅថ្នាក់ខេត្ត និងស្រុក
- ពិនិត្យ វាយតម្លៃលើកម្មវត្ថុ ប្រធានបទ និងសារផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត និងស្រុក
- ពិនិត្យតាមដាន និងវាយតម្លៃ កម្មវិធីគម្រោង និងសកម្មភាពផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត និងស្រុក និង ការបណ្តុះបណ្តាលមន្ត្រីផ្សព្វផ្សាយកសិកម្មស្រុក និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មមូលដ្ឋាន
- រៀបចំវេទិកាប្រចាំឆ្នាំសម្រាប់មន្ត្រីផ្សព្វផ្សាយកសិកម្ម និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មនានានៅក្នុងខេត្ត

- ពិនិត្យតាមដាន វាយតម្លៃ និងសិក្សាដកស្រង់បទពិសោធន៍នូវឥទ្ធិពលបច្ចេកវិទ្យា នវានុវត្តន៍ឯកសារ និង សារបច្ចេកទេសកសិកម្មនៅក្នុងខេត្ត។

### ៥.៦.២.តួនាទី និងភារកិច្ចរបស់ក្រុមគាំទ្របច្ចេកទេសកសិកម្មស្រុក

ក្រុមគាំទ្របច្ចេកទេសថ្នាក់ស្រុកមានតួនាទី និងភារកិច្ចផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ព្រមទាំងគាំទ្រ និង សម្របសម្រួលសកម្មភាព និងកម្មវិធីផ្សព្វផ្សាយកសិកម្មនៅថ្នាក់ស្រុក។ ក្រុមគាំទ្របច្ចេកទេសកសិកម្មថ្នាក់ស្រុកនេះមានសមាសភាពៈ តំណាងគណៈអភិបាលស្រុក (អភិបាលរងស្រុក) ជាប្រធានប្រធានការិយាល័យកសិកម្មស្រុក អនុប្រធាន និងសមាជិកមកពីការិយាល័យកិច្ចការនារី ផ្នែកជំនាញនានា (ក្សេត្រសាស្ត្រ ពេទ្យសត្វ ជលផល និងព្រៃឈើ តំណាង កសិករ និងប្រធានផ្នែកផ្សព្វផ្សាយកសិកម្មស្រុកជាលេខាអចិន្ត្រៃយ៍។

ក្រុមគាំទ្របច្ចេកទេសថ្នាក់ស្រុកមានតួនាទី និងភារកិច្ចលម្អិតដូចខាងក្រោមៈ

- ជួយកសិកម្មស្រុកក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម
- ពិនិត្យ និងសម្រេចផែនការសកម្មភាព និងកម្មវិធីផ្សព្វផ្សាយកសិកម្មនៅថ្នាក់ស្រុក
- ចូលរួម និងសម្របសម្រួលការដាក់បញ្ចូលកម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្មក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីឃុំ/សង្កាត់
- គាំទ្រ និងសម្របសម្រួលកម្មវិធីគម្រោង និងសកម្មភាពផ្សព្វផ្សាយកសិកម្មនានានៅថ្នាក់ស្រុក
- ចូលរួមគាំទ្របច្ចេកទេសដល់ភ្នាក់ផ្សព្វផ្សាយកសិកម្មនៅមូលដ្ឋាន (ភូមិ ឃុំ) និងកសិករ
- ពិនិត្យ វាយតម្លៃលើកម្មវត្ថុ ប្រធានបទ និងសារផ្សព្វផ្សាយកសិកម្ម នៅថ្នាក់ខេត្ត និងស្រុក
- ចូលរួមរៀបចំវេទិកាជាប្រចាំ ដើម្បីវាយតម្លៃគុណភាពសេវាផ្សព្វផ្សាយកសិកម្ម ដែលផ្តល់ដោយអ្នកផ្តល់សេវាផ្សព្វផ្សាយនានា
- ចូលរួមពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីគម្រោង និងសកម្មភាពផ្សព្វផ្សាយកសិកម្មនៅថ្នាក់ស្រុក។

### ៥.៦.៣.មុខងារសម្របសម្រួល គ្រប់គ្រង និងគាំទ្ររបស់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តមានតួនាទី ក្នុងការងារផ្សព្វផ្សាយកសិកម្មដូចខាងក្រោមៈ

- ផ្តល់ទិសដៅ និងសម្របសម្រួលក្នុងការរៀបចំកសាងផែនការយុទ្ធសាស្ត្រ និងអភិវឌ្ឍគម្រោងកម្មវិធីផ្សព្វផ្សាយកសិកម្មប្រចាំឆ្នាំ
- សម្របសម្រួលត្រូវបង្កើតក្រុមមន្ត្រីផ្សព្វផ្សាយកសិកម្មខេត្ត និងក្រុមគាំទ្របច្ចេកទេសថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ ភូមិ

- សម្របសម្រួល ផ្តល់ការណែនាំមន្ត្រីជំនាញបច្ចេកទេស ដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីផ្សព្វផ្សាយកសិកម្មថ្នាក់ខេត្ត និងស្រុក
- សម្របសម្រួល គៀងគរធនធានមនុស្ស និងថវិកា សម្រាប់អនុវត្តកម្មវិធីផ្សព្វផ្សាយកសិកម្ម
- សម្របសម្រួល និងផ្តល់ព័ត៌មានទីផ្សារផលិតផលកសិកម្មដល់មន្ត្រីកសិកម្ម ដើម្បីផ្សព្វផ្សាយបន្តដល់កសិករ និងអ្នកពាក់ព័ន្ធ
- តាមដាន និងចូលរួមដោះស្រាយបញ្ហាប្រឈមទាក់ទងទៅនឹងផលិតកម្មកសិកម្មដោយសហការយ៉ាងជិតស្និទ្ធជា មួយស្ថាប័នជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន
- រៀបចំវេទិកានៅកម្រិតការិយាល័យកសិកម្មស្រុក-ខណ្ឌ ដែលមានអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មពាក់ព័ន្ធ ផ្សេងៗសហគមន៍កសិកម្ម កសិករ លក់-ទិញ ធាតុចូល និងផលិតកម្ម
- ចូលរួមធានាសេវាផ្សព្វផ្សាយកសិកម្មឱ្យមានប្រសិទ្ធភាពខ្ពស់ តាមរយៈការជំរុញយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃការទទួលយករបស់កសិករ និងសាយភាយ។

## ១.ប្រធានមន្ទីរ

- ដឹកនាំរៀបចំកសាងផែនការយុទ្ធសាស្ត្រ និងអភិវឌ្ឍគម្រោងកម្មវិធីផ្សព្វផ្សាយកសិកម្មប្រចាំឆ្នាំ
- ដឹកនាំបង្កើតក្រុមមន្ត្រីផ្សព្វផ្សាយកសិកម្មខេត្ត និងក្រុមគាំទ្របច្ចេកទេសថ្នាក់ស្រុក ឃុំ ភូមិ
- ណែនាំមន្ត្រីជំនាញបច្ចេកទេស ដើម្បីពង្រឹងសមត្ថភាពដល់ភ្នាក់ងារផ្សព្វផ្សាយស្រុក
- គៀងគរធនធានមនុស្ស និងថវិកាសម្រាប់អនុវត្តកម្មវិធីផ្សព្វផ្សាយកសិកម្មដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា
- ដោះស្រាយបញ្ហាប្រឈមទាក់ទងទៅនឹងផលិតកម្មកសិកម្ម ដោយសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័ន ជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន
- ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តសកម្មភាពផ្សព្វផ្សាយកសិកម្មឱ្យបានទៀងទាត់ និងផ្តួចផ្តើមនូវសកម្មភាពនានាដើម្បីឆ្លើយតបទៅនឹងផែនការដែលបានគ្រោងទុក និងធានាបាននូវប្រសិទ្ធិភាពការទទួលយករបស់កសិករ និងសាយភាយ
- ទទួលភារកិច្ចផ្សេងៗដែលក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានប្រគល់ជូន។

## ២.អនុប្រធានមន្ទីរ

- ដឹកនាំ និងសម្របសម្រួល អនុវត្តសកម្មភាពផ្តល់បច្ចេកទេសផ្សព្វផ្សាយកសិកម្មជាមួយមន្ត្រីបច្ចេកទេសថ្នាក់ខេត្ត ការិយាល័យកសិកម្មស្រុកធានាថាសេវាផ្សព្វផ្សាយកសិកម្ម និងអនុវត្តយុទ្ធវិធីនិងវិធីសាស្ត្រដែល ប្រកបដោយប្រសិទ្ធភាព
- សហការការអនុវត្តគម្រោងកម្មវិធីជាមួយដៃគូរអភិវឌ្ឍន៍ និងផ្នែកឯកជនក្នុងការអនុវត្តកម្មវិធីផ្សព្វផ្សាយកសិកម្មដោយធានាថាគោលនយោបាយផ្សព្វផ្សាយកសិកម្មត្រូវបានដាក់បញ្ចូល និងអនុវត្ត

- ធានាថារាល់សកម្មភាពផ្សព្វផ្សាយកសិកម្មត្រូវបានដាក់បញ្ចូលតួនាទីយេនឌ័រក្នុងសកម្មភាពកសិកម្ម និង បម្រែបម្រួលអាកាសធាតុ តួនាទីយេនឌ័រ និងការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម
- រៀបចំ និងអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់គាំទ្រដល់សកម្មភាពផ្សព្វផ្សាយកសិកម្ម
- រៀបចំរបាយការណ៍ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំមន្ទីរ
- ទទួលភារកិច្ចផ្សេងៗទៀតដែលមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានដាក់ជូន។

## ៥.៦.៤.ការិយាល័យផ្សព្វផ្សាយកសិកម្ម រាជធានី-ខេត្ត

តួនាទីនិង ភារកិច្ចសំខាន់ៗរបស់ការិយាល័យផ្សព្វផ្សាយកសិកម្មរួមមាន៖

- កសាងផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងថវិកាកម្មវិធីប្រចាំឆ្នាំ
- គាំទ្រដល់ការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងថវិកាកម្មវិធីប្រចាំឆ្នាំលើការងារផ្សព្វផ្សាយកសិកម្ម
- ផ្តល់ការណែនាំ និងរួមសហការជាមួយការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ដៃគូអភិវឌ្ឍន៍ផ្នែកឯកជនដើម្បីអនុវត្តកម្មវិធីផ្សព្វផ្សាយកសិកម្មឱ្យមានប្រសិទ្ធភាពខ្ពស់
- ចងក្រងបទពិសោធន៍ល្អៗដែលទទួលបានពីការអនុវត្តដើម្បីផ្សព្វផ្សាយបន្ត
- អភិវឌ្ឍន៍សមត្ថភាពមន្ត្រីថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិលើការងារផ្សព្វផ្សាយតាមរយៈការ បណ្តុះបណ្តាល ទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស សិក្ខាសាលា ប្រជុំ និងអនុវត្តជាក់ស្តែង
- កសាង និងធ្វើបច្ចុប្បន្នភាពសម្ភារផ្សព្វផ្សាយកសិកម្មឱ្យកាន់តែមានលក្ខណៈសមស្រប និងស្របតាមបរិបទនៃការប្រែប្រួលអាកាសធាតុដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- រៀបចំសិក្ខាសាលាប្រចាំឆ្នាំ ដើម្បីចែករំលែកបទពិសោធន៍ល្អៗដែលទទួលបានជោគជ័យ និងរៀបចំការតាំងពិព័ណ៌សមិទ្ធផលកសិកម្ម កសាង និងធ្វើបច្ចុប្បន្នភាពឯកសារវិភាគប្រព័ន្ធកៀស្រ្ត បរិស្ថានឃុំ សង្កាត់
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃពីប្រសិទ្ធភាព នៃសកម្មភាពផ្សព្វផ្សាយកសិកម្មថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់ទាំងអស់
- ទទួលភារកិច្ចផ្សេងៗទៀតដែលមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រគល់ជូន។

### ១.ប្រធានការិយាល័យផ្សព្វផ្សាយកសិកម្ម

- ដឹកនាំ រៀបចំផែនការ គ្រប់គ្រងការងារការិយាល័យផ្សព្វផ្សាយកសិកម្ម
- ផ្តល់
  និងទំនាក់ទំនងការណែនាំគោលនយោបាយដើម្បីសម្របសម្រួលប្រសិទ្ធិភាពការអនុវត្តសកម្មភាពផ្សព្វផ្សាយកសិកម្មនៅកម្រិត ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ផ្តល់ និងសម្របសម្រួលបច្ចេកទេស ស្រាវជ្រាវ និងគាំទ្រដល់ប្រធានការិយាល័យកសិកម្ម ក្រុង ស្រុក ខណ្ឌ និងក្រុមផ្សព្វផ្សាយថ្នាក់ស្រុកដើម្បីបង្កើត និងអភិវឌ្ឍន៍នៅមូលដ្ឋាន EPP ការប្រើប្រាស់ EPP ដែលបាន បង្កើតរួចនៅកន្លែងដទៃៗទៀត និងអនុញ្ញាតិដល់ភ្នាក់ងារផ្សព្វផ្សាយដើម្បីឆ្លើយតបទៅនឹងប្រសិទ្ធភាពនៃ ការជ្រើសរើសប្រភេទបញ្ហាផលិតកម្មរបស់កសិករ
- សម្របសម្រួលបង្កើតផែនការផ្សព្វផ្សាយថ្នាក់ក្រុង ស្រុក ខណ្ឌ និងកម្មវិធីដោយដាក់បញ្ចូលក្នុងផែនការវិនិយោគ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បន្តការផ្តល់កម្មវិធីបណ្តុះបណ្តាល/អភិវឌ្ឍន៍ធនធានមនុស្ស (ក្នុងការពិភាក្សាជាមួយការិយាល័យអភិវឌ្ឍន៍ធនធានមនុស្សនៃនាយកដ្ឋានផ្សព្វផ្សាយ)
- សហការ និងការគ្រប់គ្រងសម្ភារផ្តល់ដល់មន្ត្រីផ្សព្វផ្សាយ ក្រុង ស្រុក ខណ្ឌ រាប់បញ្ចូលទាំងការផលិតព័ត៌មាន សេវាកម្ម ខិតប័ណ្ណបច្ចេកទេស និងការផ្គត់ផ្គង់ឧបករណ៍ផ្សេងៗទៀត
- តាមដាន និងវាយតម្លៃប្រសិទ្ធភាពនៃកសិកម្មភាពផ្សព្វផ្សាយកសិកម្មថ្នាក់ ក្រុង ស្រុក ខណ្ឌ
- គ្រប់គ្រងដំណើរការ ការសហការ ផែនការ និងចំណាត់ថ្នាក់អាទិភាពជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ខេត្ត និង លើកកម្ពស់ និងចំណាត់ថ្នាក់ផែនការទាំងនេះទៅក្នុងវេទិកាផែនការថ្នាក់ជាតិ
- អនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មកម្ពុជាលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងទាក់ទងនឹងព័ត៌មាន និងរដ្ឋបាល នៃអង្គការកសិករ
- ការបង្កើតជំនាញ និងសមត្ថភាពផ្សព្វផ្សាយរបស់ខេត្ត ត្រូវតាមតម្រូវការនៃប្រព័ន្ធផ្សព្វផ្សាយ
- ទទួលភារកិច្ចផ្សេងៗទៀតដែលមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទប្រគល់ជូន។

## ២.អនុប្រធានការិយាល័យផ្សព្វផ្សាយកសិកម្ម

- រៀបចំ និងគ្រប់គ្រង សកម្មភាពផ្នែកការគាំទ្រការផ្សព្វផ្សាយ
- ដឹកនាំ និងគ្រប់គ្រង ផែនការកម្មវិធីផ្សព្វផ្សាយ យេនឌ័រ និងការបណ្តុះបណ្តាលផ្សេងៗដើម្បីពង្រឹងសមត្ថភាព មន្ត្រីផ្សព្វផ្សាយកសិកម្មក្រុង ស្រុក ខណ្ឌ
- ផ្តល់ និងការសហការ ការគាំទ្របច្ចេកទេសដល់មន្ត្រីផ្សព្វផ្សាយ ក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំប្រព័ន្ធកេ្សត្របរិស្ថាន (AEA)ដោយបង្កើត និងការជំរុញការអនុវត្តជាមួយក្រុមកសិករជាពិសេសធ្វើឱ្យមានប្រសិទ្ធភាពការជ្រើសរើស និងប្រើប្រាស់សំណុំកម្មវិធីផ្សព្វផ្សាយ
- គ្រប់គ្រង និងសម្របសម្រួលនូវប្រសិទ្ធភាពនៃការឆ្លើយតបបញ្ហាបច្ចេកទេស (ដែលសួរដោយមន្ត្រីថ្នាក់ស្រុក និងកសិករ) ពីនាយកដ្ឋានបច្ចេកទេសនៅថ្នាក់ជាតិ រាជធានី ខេត្ត ក្នុងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពស្រាវជ្រាវនានា
- គ្រប់គ្រង និងសម្របសម្រួលការផ្តល់ប្រសិទ្ធភាពការផលិតព័ត៌មាន និងសេវាកម្មដើម្បីគាំទ្រមូលដ្ឋានសកម្មភាពការផ្សព្វផ្សាយនៅថ្នាក់ស្រុក

- ការសម្របសម្រួល ការផ្តល់ឧបករណ៍ និងសម្ភារដើម្បីគាំទ្រសកម្មភាពផ្សព្វផ្សាយនៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- បន្តការណែនាំ ការបណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រីការិយាល័យផ្សព្វផ្សាយឱ្យត្រូវតាមតម្រូវការ និងឱកាសនៃប្រព័ន្ធផ្សព្វផ្សាយ
- ទទួលភារកិច្ចផ្សេងៗទៀតដែលមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រគល់ជូន។

ដើម្បីបំពេញតួនាទីខាងលើឱ្យមានប្រសិទ្ធភាព ការិយាល័យផ្សព្វផ្សាយកសិកម្មមានៈ

  - ផ្នែកកិច្ចការរដ្ឋបាល ផែនការ និងគណនេយ្យ
  - ផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស/បណ្តុះបណ្តាល
  - ផ្នែកប្រព័ន្ធកសិកម្ម និងផ្សព្វផ្សាយ
  - ផ្នែកយេនឌ័រ

### ៣.មន្ត្រីទទួលបន្ទុកផ្នែករដ្ឋបាល ផែនការ និងគណនេយ្យ

- គ្រប់គ្រង ចរាចរឯកសាររដ្ឋបាលគ្រប់ប្រភេទ និងផ្គត់ផ្គង់នូវរាល់ឧបករណ៍ និងសម្ភារការិយាល័យ
- រៀបចំសំណើរសុំថវិកា និងធ្វើរបាយការណ៍ផ្នែកហិរញ្ញវត្ថុ
- សម្របសម្រួលរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ
- សហការជាមួយនឹងការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងរៀបចំបូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានការិយាល័យប្រគល់ជូន។

### ៤.មន្ត្រីទទួលបន្ទុកផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស/បណ្តុះបណ្តាល

- វិភាគតម្រូវការការបណ្តុះបណ្តាលរបស់មន្ត្រីផ្សព្វផ្សាយថ្នាក់ខេត្ត ថ្នាក់ស្រុក ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងរៀប ចំបង្កើតកម្មវិធីបណ្តុះបណ្តាល
- រៀបចំបង្កើតសម្ភារ/ឯកសារបណ្តុះបណ្តាល ដើម្បីឱ្យឆ្លើយតបតាមគោលការណ៍ណែនាំ
- សម្របសម្រួល និងរៀបចំបណ្តុះបណ្តាលគ្រូបង្គោល និងភ្នាក់ងារផ្សព្វផ្សាយឃុំ ភូមិ
- សម្របសម្រួល និងសហការជាមួយដៃគូពាក់ព័ន្ធដើម្បីផ្តល់ និងប្រើប្រាស់សេវាផ្សព្វផ្សាយកសិកម្មឱ្យមានប្រសិទ្ធភាពខ្ពស់
- តាមដាន វាយតម្លៃ និងធ្វើរបាយការណ៍ពីលទ្ធផលនៃការបណ្តុះបណ្តាលមន្ត្រី និងកសិករដើម្បីវិភាគពីលទ្ធផលសេវាកម្មបណ្តុះបណ្តាល
- ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានការិយាល័យប្រគល់ជូន។

**៥.មន្ត្រីទទួលបន្ទុកផ្នែកអភិវឌ្ឍន៍ប្រព័ន្ធកសិកម្ម**

- រៀបចំ និងផ្តល់ការបណ្តុះបណ្តាលស្តីពីបច្ចេកទេស ប្រព័ន្ធកសិកម្មចម្រុះទៅតាមខ្នាតគំរូ និងតម្រូវការអ្នក ទទួលសេវា
- សម្របសម្រួល និងគាំទ្រដល់មន្ត្រីផ្សព្វផ្សាយកសិកម្មស្រុក ក្រុង ខណ្ឌ ក្នុងការរៀបចំសាលារៀនស្រែ-ចំការកសិករ ការធ្វើបង្ហាញ និងទិវាស្រែ
- ដឹកនាំ និងសម្របសម្រួលចុះធ្វើការវិភាគ និងចងក្រងឯកសារប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ
- សម្របសម្រួល និងអនុវត្តសំណុំកម្មវិធីផ្សព្វផ្សាយថ្នាក់ស្រុក និងការយកទៅអនុវត្តសារជាថ្មីនូវសំណុំកម្មវិធីផ្សព្វផ្សាយថ្នាក់ ក្រុង ស្រុក អាស្រ័យទៅតាមតម្រូវការ លក្ខខណ្ឌ និងផែនការរបស់មូលដ្ឋាន
- ចូលរួមសហការជាមួយជំនាញពាក់ព័ន្ធ ដើម្បីដោះស្រាយនូវរាល់បញ្ហាប្រឈមរបស់កសិករដែលជួបប្រទះឱ្យទាន់ពេលវេលា
- បង្កើនការយល់ដឹងពីបច្ចេកវិទ្យាថ្មី និងនិន្នាការកសិកម្មដែលវិវត្តន៍លេចចេញជារូបរាងឡើងដើម្បីរួមចំណែក ដល់ការវាយតម្លៃពីប្រសិទ្ធភាពនៃការអនុវត្តនៃបច្ចេកវិទ្យា
- ចូលរួមសម្របសម្រួល រៀបចំប្រព័ន្ធព័ត៌មានទីផ្សារកសិកម្ម និងវិភាគសេដ្ឋកិច្ចគ្រួសារកសិករ
- ចូលរួមរៀបចំគ្រប់គ្រង និងបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានកសិកម្ម
- ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានការិយាល័យប្រគល់ជូន។

**៦.មន្ត្រីទទួលបន្ទុកផ្នែកយេនឌ័រ**

- រៀបចំ និងផ្តល់ការបណ្តុះបណ្តាលមន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ត្រីការិយាល័យកសិកម្មស្រុក និងកសិករអំពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម យេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងអាហាររូបត្ថម្ភ របស់កុមារ
- បង្កើនសមត្ថភាពអំពីយុទ្ធសាស្ត្រការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម និងការប្រែប្រួលអាកាសធាតុ ដើម្បីរួមចំណែកក្នុងការពង្រឹងតួនាទីយេនឌ័រក្នុងរបរកសិកម្ម
- ធានាថារាល់សកម្មភាពផ្សព្វផ្សាយកសិកម្មត្រូវបានដាក់បញ្ចូលតួនាទីយេនឌ័រ ក្នុងសកម្មភាពកសិកម្ម និង បម្រែបម្រួលអាកាសធាតុ តួនាទីយេនឌ័រ និងការបង្កើសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម
- ចូលរួមក្នុងការធ្វើផែនការប្រចាំឆ្នាំផ្នែកការបញ្ជ្រាបយេនឌ័រ ជាមួយមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីលទ្ធផលការអនុវត្តសកម្មភាពការបញ្ជ្រាបយេនឌ័រ ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពគាំទ្រគម្រោងយេនឌ័រ និងកុមារនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (GCPSU-MAFF)
- ទទួលភារកិច្ចផ្សេងៗទៀត ដែលប្រធានការិយាល័យប្រគល់ជូន។

## ៥.៦.៥.មុខងារអនុវត្ត និងគាំទ្ររបស់ការិយាល័យកសិកម្មនៅថ្នាក់ក្រុង ស្រុក-ខណ្ឌ

ការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ជាអង្គភាពថ្នាក់មូលដ្ឋានរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ នៅថ្នាក់ ស្រុក ខណ្ឌ ស្ថិតនៅក្រោមការដឹកនាំគ្រប់គ្រងផ្ទាល់របស់ប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត និងជាអង្គភាព ជំនាញទទួលខុសត្រូវក្នុងវិស័យកសិកម្ម នៅក្នុងក្របខ័ណ្ឌរដ្ឋបាលក្រុង ស្រុក ខណ្ឌ របស់ខ្លួន។ តួនាទី និងភារកិច្ច សំខាន់ៗរបស់ការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ នៅក្នុងកម្មវិធីផ្សព្វផ្សាយកសិកម្មមាន ៖

- អនុវត្តការងារគ្រប់គ្រងដឹកនាំវិស័យកសិកម្មគ្រប់ផ្នែកនៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- ណែនាំ និងអនុវត្តវិធានការផ្សព្វផ្សាយបច្ចេកទេសវិស័យកសិកម្មដល់ប្រជាកសិករ ដែលជាការិយាល័យ ជំនាញ និងមន្ទីរកសិកម្មរាជធានី ខេត្តបានដាក់ចុះ
- សម្របសម្រួលកិច្ចព្រមព្រៀង និងការងារផ្សព្វផ្សាយកសិកម្ម ហើយបញ្ជ្រាបសកម្មភាពទាំងនេះទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ-សង្កាត់ តាមរយៈសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក-ខណ្ឌ
- រៀបចំកិច្ចប្រជុំ ឬវេទិកាជាមួយអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅមូលដ្ឋាន
- តាមដានសកម្មភាព ប្រមូលទិន្នន័យ ស្ថិតិ ឱ្យបានច្បាស់លាស់ពិតប្រាកដ និងជាក់ស្តែងដែលទាក់ទងទៅនឹង វិស័យកសិកម្ម និងផ្តល់របាយការណ៍ឱ្យបានទាន់ពេលវេលា និងទៀងទាត់ដល់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត
- លើកសំណើសុំវិធានការណ៍ និងធ្វើសកម្មភាពនូវបញ្ហាពាក់ព័ន្ធនឹងវិស័យកសិកម្មគ្រប់ផ្នែក ដែលកើតឡើងនៅក្នុងក្រុង ស្រុក ខណ្ឌ ដល់មន្ទីរកសិកម្មរាជធានី ខេត្ត ដើម្បីពិនិត្យនិងដោះស្រាយ
- ចូលរួម និងសហការអនុវត្តគម្រោងកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្មជាមួយអង្គការជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយនៅក្នុងក្រុង ស្រុក ខណ្ឌ ។

### ១.ប្រធានការិយាល័យកសិកម្ម ក្រុង ស្រុក ខណ្ឌ

- ដឹកនាំ ណែនាំ និងគ្រប់គ្រងការធ្វើផែនការក្នុងការអនុវត្តន៍កម្មវិធីផ្សព្វផ្សាយកសិកម្ម ក្រុង ស្រុក ខណ្ឌ រួមទាំងផែនការ ប្រចាំឆ្នាំ និងថវិកាប្រចាំឆ្នាំ
- ដាក់គម្រោងស្នើសុំសម្រាប់ការអភិវឌ្ឍ និងអនុវត្តសំណុំកម្មវិធីផ្សព្វផ្សាយសមស្របជូនទៅមន្ទីរកសិកម្មដើម្បីពិនិត្យសម្រេច
- ណែនាំដល់ការអភិវឌ្ឍក្រុមផ្សព្វផ្សាយស្រុក ប្រកបដោយតុល្យភាព និងមានសមត្ថភាពដែលឆ្លុះបញ្ចាំងនូវ ស្ថានភាពកសិកម្ម និងអាទិភាពអភិវឌ្ឍន៍សម្រាប់ស្រុក
- ចាត់ចែង និងសម្របសម្រួលដល់កម្មវិធីបណ្តុះបណ្តាលកសិករគំរូ និងបណ្តាអ្នកពាក់ព័ន្ធក្នុងកម្មវិធីផ្សព្វផ្សាយ ថ្នាក់ ក្រុង ស្រុក ខណ្ឌ

- ចូលរួមជាមួយនឹងបុគ្គលិកបច្ចេកទេស នៅក្នុងកម្មវិធីស្រាវជ្រាវបន្សាំដើម្បីបង្កើតសំណុំកម្មវិធីផ្សព្វផ្សាយថ្មីៗដែលឆ្លើយតបនឹងតម្រូវការជាអាទិភាព កំណត់រកឃើញនៅក្នុងការវិភាគប្រព័ន្ធកសិកម្មជាបន្តបន្ទាប់
- លើកឡើង និងដាក់បញ្ចូលនូវផែនការអនុវត្តន៍កម្មវិធីផ្សព្វផ្សាយកសិកម្មថ្មីៗ តាមតម្រូវការគ្រួសារកសិករខ្នាតតូចទៅក្នុងផែនការវិនិយោគឃុំ សង្កាត់ ផែនការសមាហរណកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ និងផែនការអភិវឌ្ឍន៍ថ្នាក់រាជធានី ខេត្ត
- សហការជាមួយ និងកសិករ អ្នកពាក់ព័ន្ធផ្សេងៗទៀតនៅថ្នាក់ក្រុង ស្រុក ខណ្ឌ កំណត់នូវអាទិភាពសម្រាប់ការអភិវឌ្ឍកសិកម្មនៅថ្នាក់ស្រុក ដោយយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ និងបរិស្ថាន តួនាទីយេនឌ័រក្នុងសកម្មភាពកសិកម្ម និងបម្រែបម្រួលអាកាសធាតុ តួនាទីយេនឌ័រ និងការបង្កើសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម អនុវត្ត និងផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសដល់កសិករ និងសហគមន៍កសិកម្ម
- សម្របសម្រួល និងគៀងគរធនធាន និងសេវាផ្សព្វផ្សាយកសិកម្មនានានៅមូលដ្ឋាន
- រៀបចំវេទិកាព័ត៌មានត្រឡប់ជាមួយភាគីពាក់ព័ន្ធនៅមូលដ្ឋានពីឥទ្ធិពល និងការទទួលយកបច្ចេកវិទ្យាសារ និងព័ត៌មានកសិកម្មពីកសិករ និងអ្នកប្រើប្រាស់
- សម្របសម្រួលដល់ការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់បណ្តាអង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ ក្រសួងពាក់ព័ន្ធផ្សេងៗ និងផ្នែកឯកជននានាក្នុងការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយកសិកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ
- សហការជាមួយអង្គការក្រៅរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានរៀបចំវេទិកាសាធារណៈអំពីការលើកកម្ពស់ តួនាទីភាពជាអ្នកដឹកនាំក្នុងសហគមន៍សម្រាប់និរន្តរភាពនៃការអភិវឌ្ឍកសិកម្ម
- គ្រប់គ្រងរចនាសម្ព័ន្ធកសិករ និងកម្មវិធីឥណទាន និងក្រុមហ៊ុនឯកជននានាពាក់ព័ន្ធនឹងសកម្មភាពការផ្សព្វផ្សាយ បច្ចេកទេសកសិកម្ម
- បង្កើត រក្សា និងកែលម្អជាប្រចាំនូវប្រព័ន្ធទិន្នន័យព័ត៌មានស្តីពីកសិកម្មថ្នាក់ស្រុក និងចូលរួមចំណែកក្នុងដំណើរការកសាងផែនការខេត្តសម្រាប់វិស័យកសិកម្ម
- ត្រួតពិនិត្យ និងវាយតម្លៃលើការទទួលយកសំណុំកម្មវិធីផ្សព្វផ្សាយកសិកម្មឱ្យមានប្រសិទ្ធភាព។

## ២.អនុប្រធានការិយាល័យកសិកម្ម ក្រុង ស្រុក ខណ្ឌ

ជួយគ្រប់គ្រងមន្ត្រី និងចូលរួមដឹកនាំសកម្មភាពរួមថ្នាក់ស្រុក ដូចជា៖

- ជ្រើសរើសភូមិ ឃុំ គោលដៅ និងរៀបចំចងក្រងក្រុមកសិករ និងប្រមូលព័ត៌មាន តម្រូវការសិក្សាផ្នែកកសិកម្ម របស់កសិករ
- ដឹកនាំ សម្របសម្រួល និងតាមដានការអនុវត្តសកម្មភាពសាលារៀនស្រែកសិកររបស់មន្ត្រីការជ្រើសរើសកសិករធ្វើបង្ហាញ

- ដឹកនាំប្រជុំប្រចាំខែនៅថ្នាក់ស្រុក និងចូលរួមប្រជុំប្រចាំខែនៅមន្ទីរកសិកម្ម
- ដឹកនាំការ រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍកសិកម្មថ្នាក់ស្រុក ផែនការយុទ្ធសាស្ត្រថវិកាផែនការសកម្មភាព ថវិកាប្រចាំឆ្នាំ និងថវិកាកម្មវិធី រៀបចំផែនការវិនិយោគឃុំ ផែនការសមាហរណកម្មថ្នាក់ស្រុក ផែនការសកម្មភាពប្រចាំខែ
- ដឹកនាំ និងតាមដានការអនុវត្តបច្ចេកទេសថ្មី និងដោះស្រាយបញ្ហាកើតមានរបស់ក្រុមកសិករ
- ចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មថ្មី និងចាប់យកបទពិសោធន៍ថ្មីៗដើម្បីអនុវត្តសកម្មភាពថ្នាក់ស្រុក
- រៀបចំកិច្ចតែងការការបណ្តុះបណ្តាលកសិករសម្រាប់មន្ត្រីផ្តល់វគ្គបណ្តុះបណ្តាលដល់កសិករ
- ដឹកនាំទស្សនកិច្ចសិក្សារបស់មន្ត្រី និងក្រុមកសិករ
- សម្របសម្រួលក្នុងការផ្ទេរបទពិសោធន៍ពីកសិករមួយទៅកសិករមួយ
- ដឹកនាំការវាយតម្លៃលទ្ធផលការងាររបស់មន្ត្រីថ្នាក់ស្រុក និងការវាយតម្លៃការអនុវត្តសកម្មភាពការផ្សព្វផ្សាយកសិកម្មថ្នាក់ស្រុក
- រៀបចំរបាយការណ៍រីកចម្រើន ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំជូនប្រធានការិយាល័យកសិកម្មស្រុក
- ដឹកនាំការប្រជុំ សិក្ខាសាលា វេទិកាផ្សេងៗក្នុងស្រុកគោលដៅ
- ទទួលភារកិច្ចដែលថ្នាក់ដឹកនាំប្រគល់ជូន។

តួនាទី និងភារកិច្ចជាក់លាក់របស់មន្ត្រីតាមផ្នែកនីមួយៗនៅក្នុងកម្មវិធីផ្សព្វផ្សាយមាន៖

## ៣.មន្ត្រីទទួលបន្ទុកផ្នែករដ្ឋបាលនិងនីតិកម្មកសិកម្ម

- សម្របសម្រួល និងផ្តល់ការគាំទ្រផ្នែកការងាររដ្ឋបាលដល់ក្រុមផ្សព្វផ្សាយកសិកម្មស្រុក៖ ការវាយអត្ថបទ ការគ្រប់គ្រងបញ្ជី កំណត់ត្រា ការផ្គត់ផ្គង់សម្ភារការិយាល័យ ការថែរក្សាឧបករណ៍ និងសេវាសម្អាតនានា
- ផ្តល់ការរៀបចំថវិកា របាយការណ៍ និងសេវាផ្នែកគណនេយ្យ ដើម្បីគាំទ្រការកសាងផែនការ និងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពនូវធនធាន និងកម្មវិធីផ្សព្វផ្សាយថ្នាក់ ក្រុង ស្រុក ខណ្ឌ
- រៀបចំរបាយការណ៍ស្តីពី ការអនុវត្តសកម្មភាពផ្សព្វផ្សាយកសិកម្មក្រុង ស្រុក ខណ្ឌ និងមន្ទីរកសិកម្ម រាជធានី ខេត្ត
- ធ្វើការប្រាស្រ័យទាក់ទងជាមួយ ការិយាល័យផ្សព្វផ្សាយរាជធានី ខេត្ត និងការិយាល័យពាក់ព័ន្ធនានា
- ត្រួតពិនិត្យការធ្វើចរាចរ និងការតាំងលក់សម្ភារកសិកម្ម ក្នុងក្រុង ស្រុក ខណ្ឌ
- ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ប្រគល់ជូន។

## ៤.មន្ត្រីទទួលបន្ទុកផ្នែកក្សេត្រសាស្ត្រ

- រៀបចំ និងអនុវត្តផែនការសម្រាប់សកម្មភាពផ្សព្វផ្សាយនីមួយៗ និងរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំស្តីពីសមិទ្ធផលធៀបនឹងផែនការសកម្មភាពប្រចាំឆ្នាំ
- ផ្តល់ការសម្របសម្រួល បណ្តុះបណ្តាល ការធ្វើបង្ហាញដល់កសិករក្នុងមូលដ្ឋាន
- បង្កើនទំនាក់ទំនង និងប្រសិទ្ធភាពការងារអនុវត្តកម្មវិធីផ្សព្វផ្សាយជាមួយកសិករក្នុងមូលដ្ឋាន និងគណៈកម្មការ រអភិវឌ្ឍន៍ ឃុំ សង្កាត់ និងភូមិ
- រៀបចំបង្កើតទីតាំងសម្រាប់ធ្វើបង្ហាញដោយសហការជាមួយកសិករក្នុងមូលដ្ឋាន ដើម្បីជំរុញដល់ការទទួលយកនូវបច្ចេកវិទ្យាកសិកម្មដែលបានកែលម្អថ្មីៗ និងការតាមដាន និងវាយតម្លៃនូវប្រសិទ្ធភាពនៃការទទួលយករបស់កសិករ
- ផ្តល់ព័ត៌មាន យោបល់ និងការគាំទ្របច្ចេកទេសជាមូលដ្ឋានស្តីពីផលិតកម្មដំណាំដែលរួមមានការជ្រើស រើសទីកន្លែងកសិករ ការរៀបចំដី ពូជ និងការគ្រប់គ្រងទឹក គ្រប់គ្រងកត្តាសត្វចង្រៃ និងកែលម្អជីជាតិដី ។ល។
- សម្របសម្រួលដល់ការឆ្លើយតបផ្នែកបច្ចេកទេសចំពោះបញ្ហាប្រឈមផ្សេងៗ ដែលទាក់ទងនឹងផលិតកម្មកសិកម្មរបស់កសិករដោយមានការជួយគាំទ្រពីមន្ត្រីក្សេត្រសាស្ត្រ និងផលិតភាពកសិកម្មរាជធានី ខេត្ត នៅពេលចាំបាច់
- ប្រមូល និងទុកដាក់ទិន្នន័យស្ថិតិសមស្រប ស្តីពីការងារកសិកម្មដើម្បីជួយដល់ការកសាងផែនការ ការស្រាវជ្រាវ ការវាយតម្លៃ និងសកម្មភាពផ្តល់ប្រឹក្សា(ផ្សព្វផ្សាយ)នៅតាមថ្នាក់ស្រុក ក្រុង ខណ្ឌ ថ្នាក់រាជធានី ខេត្តនិងថ្នាក់ជាតិ
- សម្របសម្រួលដល់ការចូលរួមឱ្យមានប្រសិទ្ធភាពរបស់អ្នកផ្តល់សេវាផ្សព្វផ្សាយនានា ដែលស្ថិតនៅក្នុងប្រព័ន្ធផ្សព្វផ្សាយថ្នាក់ស្រុក ក្រុង ខណ្ឌ ឱ្យស្របទៅតាមគោលការណ៍ណែនាំស្តីពីប្រព័ន្ធផ្សព្វផ្សាយកសិកម្មកម្ពុជា។
- ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានការិយាល័យកសិកម្មស្រុក ក្រុង ខណ្ឌ ប្រគល់ជូន។

## ៥.មន្ត្រីទទួលបន្ទុកផ្នែកផ្សព្វផ្សាយកសិកម្ម

- សម្របសម្រួលដល់ការអនុវត្តសំណុំកម្មវិធីផ្សព្វផ្សាយនៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- ចូលរួមចំណែកក្នុងដំណើរការកសាងផែនការផ្សព្វផ្សាយក្រុង ស្រុក ខណ្ឌ ប្រចាំឆ្នាំ
- រៀបចំ និងអនុវត្តផែនការសកម្មភាពផ្សព្វផ្សាយនីមួយៗ និងរៀបចំរបាយការណ៍ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ ស្តីពីសមិទ្ធផលសម្រេចបានធៀបនឹងផែនការប្រចាំឆ្នាំ
- សម្របសម្រួល និងដាក់បញ្ចូលផែនការផ្សព្វផ្សាយកសិកម្មជាមួយនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងភូមិ
- ផ្តល់ការសម្របសម្រួល បណ្តុះបណ្តាល និងដឹកនាំការធ្វើបង្ហាញសម្រាប់កសិករក្នុងមូលដ្ឋាន

- រៀបចំកន្លែងសម្រាប់ធ្វើបង្ហាញជាមួយកសិករក្នុងមូលដ្ឋាន ដើម្បីជំរុញដល់ការទទួលយកនូវបច្ចេកវិទ្យាកសិកម្មល្អបែបថ្មីៗ និងទំនើប និងការតាមដាន និងវាយតម្លៃនូវប្រសិទ្ធភាពនៃការទទួលយករបស់កសិករ
- សម្របសម្រួលដល់ការឆ្លើយតបផ្នែកបច្ចេកទេស ចំពោះបញ្ហាប្រឈមផ្សេងៗដែលទាក់ទងនឹងផលិតកម្ម កសិកម្មរបស់កសិករដោយមានការគាំទ្រពីបុគ្គលិកការិយាល័យផ្សព្វផ្សាយរាជធានីខេត្តនៅពេលចាំបាច់
- បង្កើនទំនាក់ទំនងការងារឱ្យមានប្រសិទ្ធភាពជាមួយកសិករក្នុងមូលដ្ឋាន និងគណៈកម្មការអភិវឌ្ឍន៍ឃុំសង្កាត់ ភូមិ
- ប្រមូល និងរក្សាទុកនូវទិន្នន័យស្ថិតិសមស្របស្តីពីការងារផ្សព្វផ្សាយកសិកម្មនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បី ជួយដល់ការកសាងផែនការ ការស្រាវជ្រាវ ការវាយតម្លៃ និងសកម្មភាពប្រឹក្សាផ្តល់យោបល់ (ផ្សព្វផ្សាយ) នៅ ថ្នាក់ក្រុង ស្រុក ខណ្ឌ
- សម្របសម្រួលដល់ការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់អ្នកផ្តល់សេវាផ្សព្វផ្សាយនានា នៅក្នុងប្រព័ន្ធផ្សព្វផ្សាយថ្នាក់ក្រុង ស្រុក ខណ្ឌ ឱ្យស្របទៅតាមគោលការណ៍ណែនាំ ស្តីពីប្រព័ន្ធផ្សព្វផ្សាយកសិកម្មកម្ពុជា
- ទទួលភារកិច្ចផ្សេងៗទៀត ដែលប្រធានការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ប្រគល់ជូន។

**៦.មន្ត្រីទទួលបន្ទុកផ្នែកផលិតកម្ម និងបសុព្យាបាល**

- ផ្តល់ព័ត៌មានបច្ចេកទេសប្រឹក្សាយោបល់ និងគាំទ្រជាមូលដ្ឋានចំពោះបញ្ហាផ្នែកសុខភាព និងផលិតកម្មសត្វ ដល់កសិករក្នុងមូលដ្ឋាន
- សម្របសម្រួលដល់ការផ្តល់សេវាកម្មចាក់ថ្នាំការពារ និងព្យាបាលសត្វ
- ការស្រង់ស្ថិតិសត្វ និងត្រួតពិនិត្យជម្ងឺសត្វដោយផ្តល់នូវការបណ្តុះបណ្តាល ឧបករណ៍ សម្ភារនិងការណែនាំដល់ភ្នាក់ងារសុខភាពសត្វភូមិ
- បង្កើតទំនាក់ទំនងការងារឱ្យមានប្រសិទ្ធភាពជាមួយកសិករក្នុងមូលដ្ឋាន និងគណៈកម្មការអភិវឌ្ឍន៍ ឃុំសង្កាត់ និងភូមិ
- ផ្តល់ការសម្របសម្រួល បណ្តុះបណ្តាល និងដឹកនាំការធ្វើបង្ហាញសម្រាប់កសិករក្នុងមូលដ្ឋាន
- រៀបចំបង្កើតកន្លែងសម្រាប់ធ្វើបង្ហាញ ដោយសហការជាមួយកសិករក្នុងមូលដ្ឋាន ដើម្បីជំរុញដល់ការទទួលយកនូវបច្ចេកវិទ្យាកសិកម្មល្អបែបថ្មីៗ និងទំនើប និងការតាមដាន និងវាយតម្លៃនូវប្រសិទ្ធភាពនៃការទទួល យករបស់កសិករ
- សម្របសម្រួលដល់ការឆ្លើយតបផ្នែកបច្ចេកទេស ចំពោះបញ្ហាប្រឈមផ្សេងៗដែលទាក់ទងនឹងផលិតកម្ម សត្វរបស់កសិករដោយមានការជួយគាំទ្រពីមន្ត្រីផលិតកម្ម និងបសុព្យាបាល រាជធានី ខេត្តនៅពេលចាំបាច់

- ប្រមូល និងទុកដាក់ទិន្នន័យស្ថិតិឱ្យបានសមស្របស្តីពីការងារផលិតកម្ម និងបសុព្យាបាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីជួយដល់ការកសាង ផែនការការស្រាវជ្រាវ ការវាយតម្លៃនិង សកម្មភាពប្រឹក្សាផ្តល់យោបល់នៅ តាមថ្នាក់ក្រុង ស្រុក ខណ្ឌ ថ្នាក់រាជធានី ខេត្ត និង ថ្នាក់ជាតិ
- សម្របសម្រួល ដល់ការចូលរួមឱ្យមានប្រសិទ្ធភាពរបស់អ្នកផ្តល់សេវាផ្សព្វផ្សាយនានា នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ក្រុង ស្រុក ខណ្ឌឱ្យសមស្របទៅតាមគោលការណ៍ណែនាំ ស្តីពីប្រព័ន្ធផ្សព្វផ្សាយកសិកម្មកម្ពុជា
- ផ្តល់របាយការណ៍រីកចម្រើនផ្នែកផលិតកម្មសត្វ ប្រចាំខែ ឆមាស និងឆ្នាំដល់ប្រធានការិយាល័យកសិកម្ម ក្រុង ស្រុក ខណ្ឌ
- ចូលរួមត្រួតពិនិត្យការធ្វើចរាចរសត្វ និងផលិតផលដែលមានដើមកំណើតពីសត្វ
- ត្រួតពិនិត្យទីសត្តឃាតដ្ឋាន និងការលក់សាច់សត្វនៅទីផ្សារទៅតាមលិខិតបទដ្ឋានគតិយុត្តិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងៗក្នុងការផ្តល់សេវាសុខភាពសត្វ
- សហការជាមួយភ្នាក់ងារសុខភាពសត្វភូមិក្នុងការផ្តល់សេវាសុខភាពសត្វ
- ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានការិយាល័យកសិកម្ម ក្រុង ស្រុក ខណ្ឌប្រគល់ជូន។

## ៧.មន្ត្រីទទួលបន្ទុកផ្នែកសហគមន៍កសិកម្ម

- សហការជាមួយការិយាល័យសហគមន៍កសិកម្ម ផ្សព្វផ្សាយលិខិតបទដ្ឋាន និងគោលគំនិតសហគមន៍កសិកម្ម ដល់កសិករ និងអ្នកពាក់ព័ន្ធ នៅក្នុង ឃុំ សង្កាត់ ភូមិ
- សម្របសម្រួល និងគាំទ្រដល់កសិករក្នុងការបង្កើត និងការចុះបញ្ជីការសហគមន៍កសិកម្មនៅតាមបណ្តាឃុំ សង្កាត់ ភូមិ
- រក្សាទុកឯកសារចុះបញ្ជីការសហគមន៍កសិកម្ម
- ចូលរួមបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់សហគមន៍កសិកម្ម
- សម្របសម្រួលរវាងសហគមន៍កសិកម្មជាមួយអង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធលើ វិស័យកសិកម្ម
- ជួយស្វែងរកព័ត៌មានទីផ្សារ និងផ្តល់ដល់សហគមន៍កសិកម្ម
- សហការតាមដានការប្រព្រឹត្តទៅ និងប្រតិបត្តិការមុខរបររបស់សហគមន៍កសិកម្ម ដើម្បីតម្រង់ទិសដៅ និង ផ្តល់ប្រឹក្សាបច្ចេកទេស
- ចូលរួមធ្វើបច្ចុប្បន្នភាពទិន្នន័យសហគមន៍កសិកម្មប្រចាំឆ្នាំ
- ចូលរួមសិក្សាវាយតម្លៃ និងសម្របសម្រួលដោះស្រាយបញ្ហាបណ្តឹងតវ៉ា និងវិវាទរបស់សហគមន៍កសិកម្ម
- ចូលរួមសន្និបាតកំណើតដំបូង និងមហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម
- ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ប្រគល់ជូន។

## ៨. មន្ត្រីទទួលបន្ទុកផ្នែករុក្ខាប្រមាញ់

- ផ្សព្វផ្សាយលិខិតបទដ្ឋាន ស្តីពីការបង្កើតសហគមន៍ព្រៃឈើដល់កសិករនិងអ្នកពាក់ព័ន្ធនៅក្នុង ឃុំ សង្កាត់ ភូមិ
- សម្របសម្រួល និងគាំទ្រដល់កសិករក្នុងការបង្កើត និងការចុះបញ្ជីការសហគមន៍ព្រៃឈើនៅតាមបណ្តាឃុំ សង្កាត់ ភូមិ
- រក្សាទុកឯកសារចុះបញ្ជីការសហគមន៍ព្រៃឈើ
- ចូលរួមបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់សហគមន៍ព្រៃឈើ
- សហការតាមដានការប្រព្រឹត្តទៅ និងប្រតិបត្តិការមុខរបររបស់សហគមន៍ព្រៃឈើ ដើម្បីតម្រង់ទិសដៅ និង ផ្តល់ប្រឹក្សាបច្ចេកទេស
- ចូលរួមធ្វើបច្ចុប្បន្នភាពទិន្នន័យសហគមន៍ព្រៃឈើប្រចាំឆ្នាំ
- ចូលរួមសិក្សាវាយតម្លៃ និងសម្របសម្រួលដោះស្រាយបញ្ហាបណ្តឹងតវ៉ា និងវិវាទរបស់សហគមន៍ព្រៃឈើ
- ចូលរួមសន្និបាតកំណើតដំបូង និងមហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍ព្រៃឈើ
- ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ប្រគល់ជូន។

## ៩. មន្ត្រីទទួលបន្ទុកផ្នែកជលផល

- ផ្សព្វផ្សាយលិខិតបទដ្ឋាន ស្តីពីការបង្កើតសហគមន៍នេសាទដល់កសិករនិងអ្នកពាក់ព័ន្ធ នៅក្នុង ឃុំ សង្កាត់ ភូមិ
- សម្របសម្រួល និងគាំទ្រដល់កសិករក្នុងការបង្កើត និងការចុះបញ្ជីការសហគមន៍នេសាទ នៅតាមបណ្តាឃុំ សង្កាត់ ភូមិ
- រក្សាទុកឯកសារចុះបញ្ជីការសហគមន៍នេសាទ
- ចូលរួមបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ
- សហការតាមដានការប្រព្រឹត្តទៅ និងប្រតិបត្តិការមុខរបររបស់សហគមន៍នេសាទ ដើម្បីតម្រង់ទិសដៅ និង ផ្តល់ប្រឹក្សាបច្ចេកទេស
- ចូលរួមធ្វើបច្ចុប្បន្នភាពទិន្នន័យសហគមន៍នេសាទ ប្រចាំឆ្នាំ
- ចូលរួមសិក្សាវាយតម្លៃ និងសម្របសម្រួលដោះស្រាយបញ្ហាបណ្តឹងតវ៉ា និងវិវាទរបស់សហគមន៍នេសាទ
- ចូលរួមសន្និបាតកំណើតដំបូង និងមហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍នេសាទ
- ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ប្រគល់ជូន។

### ១០.ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ

- បង្កើតបណ្តាញព័ត៌មានក្នុងការទំនាក់ទំនងរវាងកសិករ និងមន្ត្រីផ្សព្វផ្សាយកសិកម្ម រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងភ្នាក់ងារផ្តល់សេវាផ្សព្វផ្សាយនានា
- ជួយផ្សព្វផ្សាយបច្ចេកវិទ្យាថ្មីៗដែលពាក់ព័ន្ធទៅនឹងផលិតកម្មកសិកម្ម និងពិពិធកម្មកសិកម្ម
- បណ្តុះបណ្តាលកសិករពីការប្រើប្រាស់ប្រព័ន្ធទទួលព័ត៌មានជាសំឡេងតាមរយៈទូរស័ព្ទ និងជាសារអេឡិចត្រូនិកសម្រាប់រាយការណ៍ព័ត៌មានទាន់ហេតុការណ៍ពាក់ព័ន្ធនឹងកសិកម្ម និងសម្រាប់សេវាសួរឆ្លើយអំពី បញ្ហាកសិកម្ម
- ជាអ្នកសម្របសម្រួលគ្រប់ការងារសហគមន៍កសិកម្ម និងជាទីប្រឹក្សារបស់កសិករ
- ចូលរួមសម្របសម្រួលជាមួយគ្រូបង្គោលថ្នាក់ស្រុក ក្រុង ខណ្ឌ ក្នុងការបណ្តុះបណ្តាលដល់កសិករ
- ជាអ្នកផ្តល់សេវាកម្មផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ព័ត៌មាន និងជាស្ពានចម្លងបច្ចេកទេសកសិកម្មពីអ្នកផ្សព្វផ្សាយកសិកម្មថ្នាក់ក្រុង ស្រុក ខណ្ឌទៅកសិករ និងជាអ្នកផ្តល់ព័ត៌មានពីកសិករឱ្យមកមន្ត្រីផ្សព្វផ្សាយកសិកម្មថ្នាក់ ក្រុង ស្រុក ខណ្ឌវិញ
- ចូលរួមរៀបចំកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងចូលរួមសិក្ខាសាលាផែនការសមាហរណកម្មថ្នាក់ស្រុក
- ទំនាក់ទំនង និងសហការជាមួយអង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជនក្នុងការអភិវឌ្ឍឃុំគោលដៅ
- រៀបចំចងក្រងក្រុមកសិករស្ម័គ្រចិត្ត និងជួយពង្រឹងក្រុមកសិករក្នុងការអភិវឌ្ឍវិស័យកសិកម្ម
- កសាងសមត្ថភាពតាមរយៈវគ្គបណ្តុះបណ្តាល/ ទស្សនកិច្ចសិក្សា/ ការអនុវត្តផ្ទាល់នៅទីវាល និងកសិដ្ឋាន
- ចូលរួមក្នុងការសម្របសម្រួល និងដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើងក្នុងផលិតកម្មកសិកម្មរបស់កសិករ
- គ្រប់គ្រងព័ត៌មានកសិកម្មក្នុងឃុំ និងចែកចាយទៅដល់អ្នកពាក់ព័ន្ធ
- កត់ត្រាជាប្រព័ន្ធព័ត៌មាន សកម្មភាព និងលទ្ធផលនៃការធ្វើបង្ហាញជាគំរូដល់កសិករដទៃទៀត។

### ១១.ភ្នាក់ងារផ្សព្វផ្សាយកសិកម្មថ្នាក់ភូមិ

- ជាគំរូ និងនាំមុខក្នុងការអនុវត្ត និងគ្រប់គ្រងការធ្វើសកម្មភាពបង្ហាញនៅក្នុងកសិដ្ឋាន
- ចូលរួមស្វែងយល់ពីបញ្ហាដែលកើតឡើងលើផ្នែកកសិកម្ម និងផ្តល់ជាយោបល់ក្នុងការដោះស្រាយនៅក្នុង ក្រុម ភូមិ
- ធ្វើជាគំរូ និងផ្ទេរបច្ចេកទេសកសិកម្មដល់កសិករក្នុងភូមិ
- សហការជាមួយភ្នាក់ងារផ្សព្វផ្សាយឃុំក្នុងការបណ្តុះបណ្តាលកសិករពីការប្រើប្រាស់ប្រព័ន្ធទទួលព័ត៌មានជាសំឡេងតាមរយៈទូរស័ព្ទ និងជាសារអេឡិចត្រូនិកសម្រាប់រាយព័ត៌មានទាន់ហេតុការណ៍ពាក់ព័ន្ធនឹងកសិកម្ម និងសម្រាប់សេវាសួរឆ្លើយអំពីបញ្ហាកសិកម្ម
- ជាជនបង្គោលទំនាក់ទំនងរវាងការិយាល័យកសិកម្ម ក្រុង ស្រុក ខណ្ឌ និងក្រុមកសិករ
- ចូលរួមប្រជុំកសាងផែនការអភិវឌ្ឍន៍ភូមិ ឃុំ

- ជួយការងារអ្នកដឹកនាំក្រុម
- ទទួល និងផ្តល់ព័ត៌មានត្រឡប់ដល់កសិករ
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាល ការផ្សព្វផ្សាយកសិកម្មថ្មី និងជួយរៀបចំការងារប្រជុំក្រុមកសិករ
- ជួយសម្របសម្រួលកសិករក្នុងការគ្រប់គ្រងក្រុម
- ជួយសម្រួលដល់ការចងក្រងក្រុម (សហគមន៍) កសិករ
- ចូលរួមដំណើរការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីផ្សព្វផ្សាយកសិកម្មផ្សេងៗ
- ចូលរួមរៀនសូត្រក្នុងវគ្គបណ្តុះបណ្តាល/ ការប្រជុំ/ សិក្ខាសាលា។

## ៦.អត្ថប្រយោជន៍នៃតួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយកសិកម្ម នៅកម្ពុជា

តួនាទីនិងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយកសិកម្មនៅកម្ពុជានេះផ្តល់ប្រយោជន៍ជាសក្តានុពល ដល់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖

- ពង្រឹងការទំនាក់ទំនងរវាងការស្រាវជ្រាវផ្សព្វផ្សាយ និងផ្តល់ការឆ្លើយតបយ៉ាងប្រសើរដល់ការស្រាវជ្រាវជា មូលដ្ឋានរបស់នាយកដ្ឋានបច្ចេកទេសទាំងអស់ធានាថារាល់ការស្រាវជ្រាវទាំងអស់ និងមានទិសដៅ ទៅរក បញ្ហាជាក់លាក់មួយ
- ការអភិវឌ្ឍសំណុំកម្មវិធីផ្សព្វផ្សាយ និងការធ្វើផែនការនៅថ្នាក់ស្រុកដោយការកំណត់បញ្ហានៅមូលដ្ឋាន ជាអាទិភាព និងជួយជាអត្ថប្រយោជន៍ដល់ការិយាល័យផ្សព្វផ្សាយកសិកម្មខេត្តឆ្លើយតប និងតម្រូវការ ទាំង អស់របស់ខេត្ត និងទាក់ទងទៅនឹងមូលដ្ឋាន
- ប្រព័ន្ធនេះនឹងធ្វើឱ្យការប្រើប្រាស់ទុន/ មូលនិធិសម្រាប់ប្រតិបត្តនៅមូលដ្ឋានមានប្រសិទ្ធភាព
- ប្រព័ន្ធនេះទាក់ទាញអារម្មណ៍អ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលទាំងអស់ដោយប្រព័ន្ធនេះ បានបង្ហាញ នូវតម្លាភាពនៃតម្រូវការពិតប្រាកដរបស់កសិករភាគច្រើននៅមូលដ្ឋាន
- ប្រព័ន្ធនេះ ផ្តល់ការភ្ជាប់ទំនាក់ទំនងយ៉ាងរឹងមាំជាមួយកសិករដែលពាក់ព័ន្ធទៅគ្រប់លំដាប់ថ្នាក់ទទួលបាន លទ្ធផលច្រើនពីកសិករក្នុងតំណាក់កាលកសាងផែនការ កំណត់អាទិភាព សាកល្បង និងអនុវត្ត
- គោលការណ៍នេះ និងបំពេញបន្ថែមគាំទ្រដល់គោលនយោបាយផ្សព្វផ្សាយកសិកម្មរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៧. ផែនការជាក់លាក់នៃការផ្សព្វផ្សាយ

ផែនការជាក់លាក់នៃការផ្សព្វផ្សាយសម្រាប់រៀបចំការបណ្តុះបណ្តាល ផ្តល់ការផ្សព្វផ្សាយកសិកម្ម និងការ អប់រំមានចំនួន៥ផ្នែក៖

១. អ្នកស្តាប់ និងតម្រូវការ

២. ដំណោះស្រាយ

៣. សារគន្លឹះ

៤. បែបបទនៃសារគន្លឹះ និងការផ្ដល់ ឱ្យ

៥. ការវាយតម្លៃ

ផែនការជាក់លាក់តម្រូវឱ្យមានអន្តរកម្មគ្នាទៅវិញទៅមក ដោយមានការវាយតម្លៃដំណើរការទាំងស្រុង។

**១. អ្នកស្ដាប់ និងតម្រូវការ៖** ស្ទាបស្ទង់នូវទំនាក់ទំនងនៃតម្រូវការដែលដៃគូរ ក្រុមគោលដៅចង់បាន និង វិធីសាស្ត្រដែលអ្នកពាក់ព័ន្ធប្រើដូចជា៖ ការពិភាក្សាជាក្រុម ការអង្កេតរបស់អ្នកចូលរួមទស្សនៈកិច្ចតាមវាល ការចុះ អង្កេត ការសម្ភាសន៍អ្នកផ្ដល់ព័ត៌មានសំខាន់ៗការយល់ដឹងដោយផ្អែកលើបទពិសោធន៍នៅតាមវាល។

**២.ដំណោះស្រាយ៖** កំណត់នូវដំណោះស្រាយដែលសមរម្យសម្រាប់កសិករ សេដ្ឋកិច្ចសង្គម និងឱកាស ទីផ្សារ។

**៣. សារគន្លឹះ៖** ការកំណត់នូវ " **សារគន្លឹះ**" ដែលទាក់ទងទៅនឹងដំណោះស្រាយ ផ្អែកទាំងនោះតម្រូវការ សម្រាប់ការអនុវត្តទទួលបានជោគជ័យនៃការផ្លាស់ប្ដូរ(ដំណោះស្រាយ)។ សេចក្ដីព្រាងសារគន្លឹះដែលសមស្រប និង ត្រូវការការយល់ដឹងច្បាស់លាស់ចំពោះអ្នកស្ដាប់។

**៤. បែបបទនៃសារគន្លឹះ និងការផ្ដល់ឱ្យ៖** ការផ្ញើរ និងផ្ដល់ជូននូវសាររបស់អ្នក ។ សារគន្លឹះគឺជាមូលដ្ឋានសម្រាប់ការផ្ដល់ជូនដោយឆ្លងកាត់ការបណ្ដុះបណ្ដាល វីដេអូ វិទ្យុ ការសរសេរជាឯកសារដោយផ្ទុកនូវព័ត៌មានសម្រាប់ជា សាធារណៈ (factsheet)ការធ្វើបង្ហាញនៅតាមវាល ព្រឹត្តិការណ៍វគ្គបណ្ដុះបណ្ដាល។ល។ ។

**៥. ការវាយតម្លៃ៖** ការវាយតម្លៃដើម្បីបន្តនូវការសិក្សា និងធ្វើឱ្យប្រសើរឡើងនូវដំណើរការផ្ដល់ជូន (ការទំនាក់ទំនង) ដំណោះស្រាយ និងការកំណត់សេចក្ដីត្រូវការជាបន្ទាន់ ។ ក្នុងវគ្គបណ្ដុះបណ្ដាលការវាយតម្លៃរាប់បញ្ចូលទាំងការ វាយតម្លៃព្រឹត្តិការណ៍ សំណួរសាកល្បងមុន និងក្រោយវគ្គបណ្ដុះបណ្ដាលការតាមដាន និងការវាយតម្លៃផលប៉ះពាល់។

## ៨.ការទំនាក់ទំនងផែនការផ្សព្វផ្សាយ ការស្រាវជ្រាវ និងកសិករ

ការទំនាក់ទំនងត្រូវបង្កើតឡើងនៅគ្រប់កម្រិត និងឋានានុក្រមដែលមានក្នុងប្រព័ន្ធរដ្ឋបាល៖

- ថ្នាក់ជាតិសម្រាប់រៀបចំគោលនយោបាយ និងការធ្វើផែនការទូទៅ
- ថ្នាក់ខេត្តសម្របសម្រួលការធ្វើផែនការប្រតិបត្តិ
- ថ្នាក់ស្រុកអនុវត្តសកម្មភាព។

ថ្នាក់ខេត្ត ធ្វើផែនការយុទ្ធសាស្ត្រ ការកំណត់អាទិភាព និងការស្រាវជ្រាវបន្សាំ និងចូលរួមពីការិយាល័យទាំងអស់របស់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ។ ថ្នាក់ខេត្តរាយការណ៍មកថ្នាក់ជាតិតាមរយៈ អគ្គនាយកដ្ឋានកសិកម្ម។

កម្មវិធីស្រាវជ្រាវបន្សាំនៅលើស្រែកសិករ មានតួនាទីសម្រាប់ការផ្ទេរបច្ចេកវិទ្យាទៅដល់កសិករក្នុងការកំណត់ឱ្យបានច្បាស់លាស់ពីបញ្ហារបស់គ្រួសារកសិករ និងមានតួនាទីក្នុងការកែលម្អព័ត៌មានឆ្លើយតបទៅកាន់បុគ្គលិកស្រាវជ្រាវ និងដើម្បីឱ្យអ្នកស្រាវជ្រាវ កំណត់ពីអនុសាសន៍ ការណែនាំច្បាស់លាស់សម្រាប់លក្ខខណ្ឌជាក់លាក់មួយនៃកេ្សត្រ បរិស្ថាន និងសេដ្ឋកិច្ច និងទទួលបានជោគជ័យត្រូវឱ្យមានការទំនាក់ទំនងរវាងការផ្សព្វផ្សាយការស្រាវជ្រាវ និងកសិករ។

គោលការណ៍ក្នុងការទំនាក់ទំនងរវាងការស្រាវជ្រាវ និងផ្សព្វផ្សាយសម្រាប់កម្មវិធីស្រាវជ្រាវបន្សាំទទួលបានជោគ ជ័យៈ

- ការធ្វើការរួមគ្នាបុគ្គលិកផ្សព្វផ្សាយ និងបុគ្គលិកស្រាវជ្រាវក្នុងកម្មវិធីស្រាវជ្រាវបន្សាំ
- ប្រតិបត្តិការរួមគ្នានៅតាមមូលដ្ឋាន ធ្វើផែនការរួមគ្នា និងការពិនិត្យមើលការងារឡើងវិញ
- កម្មវិធីស្រាវជ្រាវ និងផ្សព្វផ្សាយការផ្ទេរបច្ចេកវិទ្យាដល់ក្រុមកសិករទទួលបានជោគជ័យត្រូវមានលក្ខខណ្ឌដូចជាៈ
    - ការវិនិច្ឆ័យ និងការវិភាគបញ្ហារបស់កសិកររួមគ្នា
    - រាល់បច្ចេកវិទ្យា ដែលទាក់ទងទាំងអស់ត្រូវបានកែលម្អ
    - ក្រុមការងារមានវិជ្ជាជីវៈគ្រប់គ្រាន់ និងតួនាទីច្បាស់លាស់
- បង្កើតទីតាំងបង្ហាញផ្សព្វផ្សាយសម្រាប់ផ្ទៀងផ្ទាត់ ផ្ទេរបច្ចេកវិទ្យាដល់អតិថិជនបន្ទាប់ពីកម្មវិធីស្រាវជ្រាវបន្សាំ
- ក្រុមស្រាវជ្រាវម្ចាស់ការ និងមានទិសដៅតែមួយ
- វិទ្យាស្ថានស្រាវជ្រាវធ្វើទិវាបង្ហាញដល់អ្នកពាក់ព័ន្ធ និងកសិករមុនបង្កើតកម្មវិធីស្រាវជ្រាវ
- បុគ្គលិកកសិកម្មស្រុកត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានបណ្តុះបណ្តាល និងបង្កើនសមត្ថភាព។

## ៩. សារៈសំខាន់នៃ ការផ្ទេរព័ត៌មាន ពីកសិករមួយទៅកសិករមួយទៀតក្នុងដំណើរការផ្សព្វផ្សាយ

- ការផ្ទេរព័ត៌មានពីបុគ្គលិកកសិកម្មស្រុកដល់សហគមន៍ និងត្រូវធ្វើឡើងតាមរយៈការផ្ទេរចំណេះដឹងពីកសិករមួយ ទៅកសិករមួយទៀតតាមរយៈការធ្វើផែនការនៅតាមមូលដ្ឋានសម្រាប់ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ទទួលបានជោគជ័យ
- ការផ្សព្វផ្សាយពីកសិករមួយទៅកសិករមួយទៀត គឺជាដំណើរការដែលកសិករទំនាក់ទំនងសំខាន់ៗនឹងក្លាយជាអ្នកទទួលខុសត្រូវក្នុងការផ្ទេរព័ត៌មានទៅដល់កសិករដទៃទៀត

- បុគ្គលិកកសិកម្មស្រុកទាំងអស់នឹងក្លាយទៅជាអ្នកសម្របសម្រួល សកម្មភាពជាមួយកសិករទំនាក់ទំនង សំខាន់ៗទាំងនោះពីព្រោះកសិករទាំងនោះ និងក្លាយជាអ្នកទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលទៅដល់ កសិករផ្សេងៗទៀត និងការអនុវត្តនៅក្នុងកសិដ្ឋាន និងដើម្បីចែករំលែកនូវចំណេះដឹង និងជំនាញផ្សេងៗទៅដល់កសិករដទៃទៀត ដោយផ្អែកលើការអនុវត្តជាក់ស្តែងនៅសហគមន៍មូលដ្ឋាន
- ដំណើរការនៃការផ្សព្វផ្សាយ ពីកសិករមួយទៅកសិករមួយទៀតតម្រូវឱ្យបុគ្គលិកការិយាល័យកសិកម្មស្រុក រកឱ្យឃើញ ឬកំណត់ឱ្យបាននូវកសិករទំនាក់ទំនងសំខាន់ៗ ហើយគេក៏តម្រូវឱ្យបង្កើតឡើងនូវក្រុមសំខាន់ៗ (ឬក្លឹបកសិករផ្សព្វផ្សាយ) ដើម្បីរៀបចំបង្កើតជាកម្មវិធីបណ្តុះបណ្តាលសម្រាប់កសិករ និងក្រុមទាំងអស់នេះ ។

## ១០.ក្របខណ្ឌអនុវត្ត ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ

ដើម្បីអនុវត្តតួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម អង្គភាពជំនាញពាក់ព័ន្ធ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត និងការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមតួនាទី និងភារកិច្ចក្នុងការផ្សព្វផ្សាយកសិកម្ម។

ត្រូវរៀបចំក្របខណ្ឌអនុវត្ត យន្តការ វិធាន បទប្បញ្ញត្តិ ឧបករណ៍ វិធីសាស្រ្ត បច្ចេកវិទ្យា ការបណ្តុះបណ្តាលធនធានមនុស្ស និងសម្ភារផ្សព្វផ្សាយកសិកម្ម ព្រមទាំងវេទិកា និងយុទ្ធនាការផ្សព្វផ្សាយឱ្យបានគ្រប់គ្រាន់សម្រាប់គ្រប់គ្រងត្រួតពិនិត្យ ធ្វើនិយ័តកម្ម និងប្រតិបត្តិសេវាសេវាផ្សព្វផ្សាយកសិកម្ម។

ការអនុវត្តតួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា នេះត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានាវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងការផ្តល់សេវា ផ្សព្វផ្សាយកសិកម្មទៅតាមតម្រូវការ និងមានការចូលរួមពីអ្នកពាក់ព័ន្ធ ដើម្បីធានាភាពជាដៃគូ និងមានធនធានគ្រប់គ្រាន់ សម្រាប់សេវាផ្សព្វផ្សាយកសិកម្ម។ ឯកសារគោលការណែនាំនេះនឹងត្រូវពិនិត្យឡើងវិញ និងបច្ចុប្បន្នភាពទៅតាមតម្រូវ វិវត្តិនៃវិស័យកសិកម្មនិងសេដ្ឋកិច្ច។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវតាមដានរាល់សកម្មភាពនៃការ ផ្តល់សេវាផ្សព្វផ្សាយកសិកម្មទាំងអស់ ដើម្បីធានាឱ្យមានបច្ចេកវិទ្យាកសិកម្មមានខ្នាតគំរូអាចទទួលយកបាននិងធានា ឱ្យមានការផ្តល់ធាតុចូលមានគុណភាពដោយអ្នកផ្តល់សេវាទាំងអស់រួមមានអ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្មត្រូវរៀបចំនិងអនុវត្តប្រព័ន្ធគណនេយ្យភាពមួយ ដែលមានរួមបញ្ចូលការលើក ទឹកចិត្តឱ្យមានការផ្សព្វផ្សាយកសិកម្មប្រកបដោយគុណភាព ព្រមទាំងមានការដាក់ពិន័យលើសកម្មភាពទាំងឡាយណា មិនអនុវត្តតាមច្បាប់ និងបទដ្ឋានគតិយុត្តនានា ឬមិនគោរពតាមកិច្ចសន្យា។ ការលើកទឹកចិត្តអាចមានដូចជាការចេញវិញ្ញាបនប ័ត្របញ្ជាក់កម្រិតអប់រំដល់អ្នកផ្តល់សេវាផ្សព្វផ្សាយ និងការកំណត់វិធានការគណនេយ្យភាពជាក់លាក់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងអង្គភាពជំនាញពាក់ព័ន្ធ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ត្រូវធ្វើការអង្កេតជាប្រចាំទៅលើការពេញចិត្តរបស់អ្នកទទួលសេវាតាមរយៈការចុះវាយតម្លៃ និងការរៀបចំវេទិកាស្តាប់យោបល់ជាមួយភាគីពាក់ព័ន្ធក្នុងមូលដ្ឋាននៅតាមស្រុកមួយចំនួនដែលជ្រើសរើសដោយចៃដន្យ។

ការិយាល័យកសិកម្មស្រុកត្រូវសហការជាមួយភាគីពាក់ព័ន្ធតាមរយៈបង្កើតវេទិកាជាប្រចាំ ដើម្បីវាយតម្លៃគុណភាពសេវាផ្សព្វផ្សាយដែលផ្តល់ឱ្យដោយអ្នកផ្តល់សេវាផ្សព្វផ្សាយនានា។ ការិយាល័យកសិកម្មស្រុកត្រូវរៀបចំរបាយការណ៍គណនេយ្យភាពប្រចាំឆ្នាំពីរបកគំហើញដាក់ជូនទៅនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងមន្ទីរកសិកម្មរាជធានីខេត្តពិនិត្យ និងវាយតម្លៃ។

## ១១.សេចក្តីសន្និដ្ឋាន

តួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ជាឧបករណ៍ក្នុងការណែនាំក្នុងការគាំទ្រ សម្របសម្រួលការប្រតិបត្តិ និងការពិនិត្យតាមដាន និងវាយតម្លៃសម្រាប់បង្កើនប្រសិទ្ធភាពសេវាផ្សព្វផ្សាយកសិកម្ម និងកសិករ និងសហគមន៍កសិកម្មទទួលបាននូវសេវាផ្សព្វផ្សាយមានគុណភាពខ្ពស់ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជាឱ្យបានល្អប្រសើរ ដើម្បីបង្កើនផលិតភាព ការធ្វើពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយចីរភាព និងឆ្លើយតបតាមបរិបទសមាហរណកម្ម និងការប្រកួតប្រជែងលើបច្ចេកវិទ្យា និងទីផ្សារនៅក្នុងតំបន់ និងលើសាកលលោក។

ក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយកសិកម្មនៅកម្ពុជានេះ គឺចាំបាច់តម្រូវឱ្យគ្រប់ ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងអង្គភាពរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍មូលដ្ឋាន កសិករគំរូ និងអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មទាំងអស់ចូលរួមសហការគាំទ្រ និងប្រតិបត្តិការ ដើម្បីផ្តល់សេវាផ្សព្វផ្សាយកសិកម្មដល់កសិករ និងសហគមន៍កសិករប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ព្រមទាំងមានសេវា និងបច្ចេកទេសគ្រប់គ្រាន់តាមតម្រូវការ ទទួលយកបាន លទ្ធភាពប្រើប្រាស់បាន និងយកទៅអនុវត្តបានដោយកសិករ និងសហគមន៍កសិករ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមលើកទឹកចិត្ត និងបង្កើតឱ្យមានបរិយកាសអំណោយផលដល់គ្រប់អង្គភាពទាំងអស់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នពាក់ព័ន្ធនានានៃរាជរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍មូលដ្ឋាន និងប្រជាកសិករកម្ពុជាទាំងអស់ ដើម្បីចូលរួមចំណែកយ៉ាងសស្រាក់សស្រាំ ក្នុងការអនុវត្តគោលការណ៍ណែនាំស្តីពីផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ដើម្បីលើកកម្ពស់វិស័យកសិកម្ម និង**ទ្រទ្រង់កំណើនសេដ្ឋកិច្ច ធានាសមធម៌ ធានា សន្តិសុខ ស្បៀងនិងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។**

## ឧបសម្ព័ន្ធ ១: រចនាសម្ព័ន្ធនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម



## ឧបសម្ព័ន្ធ ២: រចនាសម្ព័ន្ធមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រាជធានី- ខេត្ត

- **មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រាជធានី- ខេត្ត**
  - ប្រធានការិយាល័យផ្សព្វផ្សាយកសិកម្ម
    - អនុប្រធានការិ.ផ្សព្វផ្សាយកសិកម្ម
      - ផ្នែករដ្ឋបាល ផែនការ គណនេយ្យ
      - ផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស /បណ្ដុះបណ្ដាល
      - ផ្នែកអភិវឌ្ឍន៍ប្រព័ន្ធ កសិកម្ម
      - ផ្នែកយេនឌ័រ

## ឧបសម្ព័ន្ធ៣: រចនាសម្ព័ន្ធ ក្រុមផ្សព្វផ្សាយកសិកម្ម និងទឹក



## ឧបសម្ព័ន្ធ៤: រចនាសម្ព័ន្ធ ការិយាល័យកសិកម្ម ក្រុង-ស្រុក-ខណ្ឌ



# ឧបសម្ព័ន្ធ៥: លំហូរនៃការផ្សព្វផ្សាយ




៥ ជំហាន សម្រាប់ប្រសិទ្ធភាពនៃការផ្សព្វផ្សាយ

**ឧបសម្ព័ន្ធ៦: គំនូសបំព្រួញ តំណាងឲ្យតួនាទីបុគ្គលិកកសិកម្មស្រុកក្នុងការផ្ទេរបច្ចេកវិទ្យា**



## ឧបសម្ព័ន្ធ៧: អង្គការចាត់តាំង និងមុខងារសហប្រតិបត្តការ នៃប្រព័ន្ធផ្សព្វផ្សាយកសិកម្ម



# ឧបសម្ព័ន្ធ៨ : គំនូសបំព្រួញអំពីការរៀបចំស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម



Profile#.....................

# ឧបសម្ព័ន្ធ៩ : ទម្រង់បញ្ជីអ្នកផ្តល់សេវាផ្សព្វផ្សាយ

| | | | |
|---|---|---|---|
| ឈ្មោះស្ថាប័ន | ……………………….. | ប្រភេទស្ថាប័ន | ……………………………. |
| ឈ្មោះទំនាក់ទំនង | ……………………….. | មុខងារ/តួនាទី | ……………………………. |
| លេខទូរស័ព្ទ | ……………………….. | អ៊ីម៉ែល/វ៉េបសាយ | ……………………………. |
| លេខ/កាលបរិច្ឆេទនៃវិញ្ញាបនបត្រដែលបានទទួលស្គាល់ | ……………………….. | សរុបឆ្នាំដែលប្រតិបត្តិការ | ……………………………. |
| ចំនួនមន្ត្រីដែលមានបទពិសោធន៍ក្នុងផ្នែកកសិកម្ម | | សញ្ញាប័ត្រ | ☐ អនុវិទ្យាល័យ/វិទ្យាល័យ ☐ បរិញ្ញា ☐ ក្រោយបរិញ្ញា |

## សកម្មភាពចំបងៗ:

…………………………………………………………………………………………………………………………………………………………

## សកម្មភាពបន្ទាប់:

…………………………………………………………………………………………………………………………………………………………

| | |
|---|---|
| កម្រិត | |
| ឈ្មោះ: រាជធានី | |
| ឈ្មោះ: ខេត្ត | |
| ឈ្មោះ: ក្រុង ស្រុក ខណ្ឌ | |
| ឃុំ/សង្កាត់ | |
| ផលិតផល | |
| សម្ភារៈកសិកម្ម | |
| អាស័យដ្ឋានពេញលេញ | |
| រយៈបណ្តោយ | |
| រយៈទទឹង | |
| សំគាល់ | |

កត់ត្រាដោយ:

កាលបរិច្ឆេទ:………………………………….